ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 23-Jun-2015, 14:59
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី
# ជំនុំជម្រះក្តីនៅដំណាក់កាលពីរ
## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៥**

**ម៉ោង ០៩:០៣នាទី**

**សវនាការលើកទី២៩៧**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ក្លូឌា ហ្វេនស៍ *(Judge Claudia FENZ)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ *(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ម៉ាទីន ខារ៉ុបគីន (បម្រុង) *(Judge Martin KAROPKIN)*

**ក្រឡាបញ្ជីសាលាដំបូង៖**

កញ្ញា ម៉ារី-ជេនី សាដាទិ *(Ms. Marie-Jeannes SARDACHTI)*

លោកស្រី សែ កុលវុឌ្ឍី

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក វីល្លៀម ស្មីត *(Mr. William SMITH)*

លោក ស្រ៊ា រតនៈ

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក លីវ សុវណ្ណា

លោក វ៉ិចទ័រ កូប៉េ *(Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ *(Ms. Anta GUISSE)*

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វរល័ក្ស

លោក ខលវីន សោនដឺស៍ *(Mr. Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោកស្រី ម៉ារី ហ្គីរ៉ូដ៍ *(Ms.Marie GUIRAUD)*

លោកស្រី ជេត វណ្ណលី

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណា

**បញ្ជីឈ្មោះអ្នកនិយាយ៖**

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| ចៅក្រម ក្លូឌា ហ្វេនស៍ | អង់គ្លេស |
| លោក វីល្លៀម ស្មីត | អង់គ្លេស |
| លោក វ៉ិចទ័រ កូប៉េ | អង់គ្លេស |
| លោក គង់ សំអុន | ខ្មែរ |
| កញ្ញា អង់តា ហ្គីសសេ | បារាំង |
| លោកស្រី ម៉ារី ហ្គីរ៉ូដ៍ | បារាំង |
| លោកស្រី ជេត វណ្ណលី | ខ្មែរ |
| លោក កែ លឿ (2-TCW-932) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី៖ លោក កែវ លឿ** (2-TCW-932)

សួរបន្តដោយលោក វីល្លៀម ស្មីត ផ្តើមពី..............................................................ទំព័រ ៣
សួរដោយលោកស្រី ម៉ារី ហ្គីរ៉ូដ៍ ផ្តើមពី ..............................................................ទំព័រ ១០
សួរដោយលោកស្រី ជេត វណ្ណលី ផ្តើមពី..............................................................ទំព័រ ១៥
សួរដោយថៅក្រម ហ្សង់ម៉ាក ឡាវែន៍ ផ្តើមពី ......................................................ទំព័រ ២១
សួរដោយលោក រ៉ិចទ័រ កូប៉េ ផ្តើមពី......................................................................ទំព័រ ៣៣

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០៣:០៧]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ សវនាការនៅថ្ងៃនេះ អង្គជំនុំជម្រះបន្តធ្វើសវនាការស្តាប់សក្ខីកម្មសាក្សី កែវ លឿ បញ្ចប់ ហើយនិងអាចចាប់ផ្តើមសវនាការស្តាប់សក្ខីកម្មសាក្សីបម្រុងដែលអង្គជំនុំជម្រះត្រៀមថ្ងៃនេះចំនួនពីររូបគឺ 2-TCW-901 ហើយនិង 2-TCW-830។ សាក្សីបម្រុងចុងក្រោយនេះ គឺពាក់ព័ន្ធជាមួយអង្គហេតុការដ្ឋានទំនប់១មករា។

ក្រឡាបញ្ជីសវនាការលោកស្រី សែ កុលវុឌ្ឍី ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សម្រាប់សវនាការនៅថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថា គ្រប់ភាគីទាំងអស់នៃរឿងក្តីនេះ មានវត្តមាន។ ដោយឡែកលោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយលោកស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការ។ លិខិតលះបង់សិទ្ធិរបស់លោក នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។ ហើយសាក្សីដែលត្រូវមកផ្តល់សក្ខីកម្មបន្តបញ្ចប់នៅថ្ងៃនេះ គឺលោក កែវ លឿ។ លោកមានវត្តមានរួចហើយនៅក្នុងបន្ទប់សវនាការ។ ហើយថ្ងៃនេះមានសាក្សីបម្រុងចំនួនពីររូប ដែលមានរហស្សនាម 2-TCW-901 និង 2-TCW-830។ សាក្សីទាំងពីរបានបញ្ជាក់ថា តាមសមត្ថភាពដែលគាត់អាចដឹង គឺគាត់មិនមានទំនាក់ទំនងញាតិលោហិត ឬញាតិពន្ធជាមួយនឹងជនជាប់ចោទពីររូប គឺលោក នួន ជា និងលោក ខៀវ សំផន ឬភាគីដើមបណ្តឹងរដ្ឋប្បវេណីណាមួយដែលត្រូវបានទទួលស្គាល់នៅក្នុងរឿងក្តីនេះទេ។ សាក្សីទាំងពីររូបនេះនឹងធ្វើសម្បថជាមុន មុននឹងផ្តល់សក្ខីកម្ម។ សូមអរគុណលោកប្រធាន។

[០៩:០៥:២១]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយជាដំបូងនេះ អង្គជំនុំជម្រះសម្រេចលើសំណើសុំរបស់ជនជាប់ចោទ នួន

ជា ជាមុនសិន។ អង្គជំនុំជម្រះទទួលលិខិតសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ ក្នុងបន្ទប់សវនាការនេះរបស់ជនជាប់ចោទ នួន ជា ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៥ ដែលបានបញ្ជាក់ថា ដោយគាត់មានបញ្ហាសុខភាព ឈឺក្បាល ឈឺចង្កេះ មិនអាចអង្គុយយូរបាន មិនអាចផ្ចង់អារម្មណ៍បានយូរ និងដើម្បីមានលទ្ធភាពចូលរួមសវនាការនាថ្ងៃខាងមុខឲ្យមានប្រសិទ្ធភាព ខ្លួនសុំលះបង់សិទ្ធិចូលរួម និងមានវត្តមានដោយផ្ទាល់ក្នុងបន្ទប់សវនាការ នៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៥។ មេធាវីការពារក្តីរបស់ខ្លួន បានប្រាប់អំពីផលប៉ះពាល់នៃការលះបង់សិទ្ធិនេះថា ការលះបង់សិទ្ធិនេះ មិនអាចបកស្រាយថាជាការលះបង់សិទ្ធិរបស់ខ្លួនក្នុងការកាត់សេចក្តីដោយយុត្តិធម៌ ឬក៏សិទ្ធិក្នុងការជំទាស់ទៅនឹងភស្តុតាងក្នុងការដាក់បង្ហាញ ឬដាក់ជូនតុលាការនេះ គ្រប់ពេលវេលានៃសវនាការលើរូបខ្លួនឡើយ។

បានឃើញកំណត់ហេតុពិនិត្យសុខភាពជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំការ ពិនិត្យព្យាបាល ថែទាំសុខភាពជនជាប់ចោទនៅ អ.វ.ត.ក ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៥ បានកត់សម្គាល់ ស្ថានភាពសុខភាពរបស់លោក នួន ជា ថាមានអាការៈឈឺក្បាល វិលមុខ ហើយនិងឈឺចង្កេះខ្លាំង និងបានផ្តល់អនុសាសន៍ថា សូមអង្គជំនុំជម្រះអនុញ្ញាតឲ្យលោក នួន ជា ចូលរួមតាមដានកិច្ចដំណើរការសវនាការ ពីបន្ទប់ខាងក្រោមសាលសវនាការនេះ។

[០៩:០៦:៥៩]

ផ្អែកលើមូលដ្ឋាននេះ និងយោងបទប្បញ្ញត្តិនៃវិធាន៨១(៥)នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះយល់ព្រម និងអនុញ្ញាតឲ្យជនជាប់ចោទ នួន ជា បន្តចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយ ស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលសវនាការពេញមួយថ្ងៃនេះ។

បង្គាប់ឲ្យបុគ្គលិកផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយ ស្ថិតនៅក្រោមសាលសវនាការនេះក្នុងរយៈពេលនៃកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

ហើយជាបន្តទៅនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅសហព្រះរាជអាជ្ញា – តំណាងសហព្រះរាជអាជ្ញា រួមទាំងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដែលមានពេលវេលាមួយវគ្គសវនាការព្រឹកនេះ ក្នុងការសួរដេញដោលសាក្សីរូបនេះ។

បាទ សូមអញ្ជើញ!

[០៩:០៧:៤០]

**លោក វីណ្ឌៀម ស្មីត៖**

ជម្រាបសួរលោកប្រធាន លោក លោកស្រីចៅក្រម មេធាវីការពារក្តី។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរបន្តដោយលោក វីណ្ឌៀម ស្មីត៖**

**ស៖** ជម្រាបសួរលោកសាក្សី។ លោកសាក្សី កាលពីថ្ងៃសុក្រសប្តាហ៍កន្លងទៅនេះ យើងបាននិយាយគ្នាអំពីបទពិសោធន៍របស់លោកនៅព្រលានយន្តហោះកំពង់ឆ្នាំង។ ហើយយើងក៏បាននិយាយគ្នាអំពីបទពិសោធន៍របស់នៅឃ្លាំញ កប់ស្រូវ។ ខ្ញុំនឹងនិយាយសង្ខេបអំពីបទពិសោធន៍របស់លោក ក្រោយពីលោកចូលមកភ្នំពេញ ហើយលោកស្នាក់នៅជិតមន្ទីរពេទ្យកាល់ម៉ែត។ នៅក្នុងកិច្ចសម្ភាសន៍របស់លោកជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា លោកបានឆ្លើយថា លោកបានឃើញគេធ្វើទារុណកម្មនៅជិតកន្លែងលោកនៅ។ លោកអាចជម្រាបជូនអង្គជំនុំជម្រះបានទេថា អ្នកណាដែលបានទទួលរងការធ្វើទារុណកម្មហ្នឹង?

**លោក កែវ លឿ៖**

**ឆ៖** ខ្ញុំបាទសូមឆ្លើយបំភ្លឺអង្គតុលាការ។ ខ្ញុំបាទមិនបានស្គាល់គេទេ។

**ស៖** ហើយការធ្វើទារុណកម្មហ្នឹងជាការធ្វើទារុណកម្មរបៀបណាដែរ ដែលលោកបានឃើញទៅលើមនុស្សម្នាក់នុ៎ង?

[០៩:០៩:១៦]

**ឆ៖** ខ្ញុំបាទបានឃើញគេចង ចងយួរ ហើយយោលពីដើមឈើមួយទៅដើមឈើមួយ គប់គ្នាបាទ។

**ស៖** ហើយអ្នកណាជាអ្នកធ្វើទារុណកម្មហ្នឹង?

**ឆ៖** ខ្ញុំបាទពុំបានស្គាល់គេទេ។

**ស៖** តើអ្នកធ្វើទារុណកម្មហ្នឹងជាកងទ័ពខ្មែរក្រហម ឬក៏មិនមែនទេ?

**ឆ៖** គឺនៅក្នុងកងទ័ពខ្មែរក្រហម។

**ស៖** ហើយតើលោកឃើញការធ្វើទារុណកម្មបែបហ្នឹង ទៅលើអ្នកដទៃទៀតក្រៅពីមនុស្សម្នាក់នេះទេ លោកធ្លាប់បានឃើញទេ?

**ឆ៖** ធ្លាប់បានឃើញ។

**ស៖** តើលោកធ្លាប់បានគេធ្វើទារុណកម្មប្រហែលជាប៉ុន្មានដងដែរ គិតត្រួសៗទៅ?

**ឆ៖** តាមដែលខ្ញុំបាទឃើញ គឺមាន៣០ដងបាទ។

[០៩:១១:១៣]

**ស៖** លោកដឹងទេថា ហេតុអ្វីបានជាអ្នកទាំងនោះត្រូវបានគេធ្វើទារុណកម្ម?

**ឆ៖** តាមខ្ញុំបាទឮគេនិយាយថា ពួកនោះជាខ្សែខ្មាំង។

**ស៖** ហើយក្នុងចម្លើយរបស់លោក ឆ្លើយទៅនឹងមជ្ឈមណ្ឌលឯកសារកម្ពុជាថា កងទ័ពជាអ្នកដែលបានធ្វើទារុណកម្មហ្នឹង គឺកងទ័ពខ្មែរក្រហម។ តើលោកបានឆ្លើយអ៊ីចឹងមែន ឬក៏អត់ទេ?

**ឆ៖** បាទ ខ្ញុំបាទបានឆ្លើយយ៉ាងនេះមែន។

**ស៖** ហើយថាតើការធ្វើទារុណកម្មនៅម្ដុំកាល់ម៉ែតហ្នឹង វាកើតឡើងមុនពេលលោកទៅធ្វើការនៅឃ្លាំង កប់ស្រូវជាបណ្ដោះអាសន្ន ឬក៏ៗនៅពេលណាដែរ?

**ឆ៖** ខ្ញុំបាទសូមឆ្លើយជូនអង្គតុលាការ។ នៅពេលនោះខ្ញុំបាទ ជាជនពិការដែលនៅក្នុងមន្ទីរកងពល។

**ស៖** តើនៅក្នុងឆ្នាំ១៩៧៥, ១៩៧៦ ឬក៏១៩៧៧ លោកចាំឆ្នាំណាមួយច្បាស់លាស់ទេ?

**ឆ៖** ខ្ញុំបាទនៅចាំបានថាឆ្នាំ១៩៧៥។

[០៩:១៣:៣១]

**ស៖** សូមអរគុណ។ តើលោកធ្លាប់បានដឹងក្នុងពេលលោកធ្វើជាកងទ័ពហ្នឹង លោកធ្លាប់បានដឹងសេចក្ដីសម្រេចរបស់គណៈកម្មាធិការមជ្ឈិមនៅថ្ងៃទី១៣ ខែមីនា ១៩៧៦ ដែលផ្ដល់សិទ្ធិអំណាចទៅដល់ក្រុមជាក់លាក់មួយចំនួន គឺផ្ដល់សិទ្ធិក្នុងការកម្ទេច ផ្ដល់សិទ្ធិក្នុងការសម្លាប់ទាំងក្នុងជួរ ទាំងក្រៅជួរខ្មែរក្រហម។ តើលោកធ្លាប់បានដឹងអំពីសេចក្ដីសម្រេចបែបនេះទេ នៅក្នុងឆ្នាំ១៩៧៦នោះ?

**ឆ៖** ខ្ញុំបាទ សូមបញ្ជាក់ម្ដងទៀត ស្ដាប់មិនទាន់បានទេ។

**ស៖** តើលោកធ្លាប់បានដឹងអំពីសេចក្ដីសម្រេចមួយ ចេញពីគណៈកម្មាធិការមជ្ឈិមនៃបក្សកុម្មុយនីស្តកម្ពុជាដែលផ្ដល់សិទ្ធិអំណាចទៅដល់ក្រុមមួយចំនួននៅក្នុងជួរខ្មែរក្រហម គឺផ្ដល់សិទ្ធិឲ្យអ្នកទាំងនោះ មានសិទ្ធិសម្លាប់ កម្ទេចទាំងក្នុង និងទាំងក្រៅជួរកងទ័ព? តើលោកធ្លាប់ដែលបានដឹងបានឮថាមានសេចក្ដីសម្រេចនេះទេ?

**ធ៖** ខ្ញុំបាទមិនដែលបានឮទេ។

**ស៖** ហើយមនុស្សដែលលោកបានឃើញគេធ្វើទារុណកម្ម គឺថាលោកបានឆ្លើយថាបានឃើញ ៣០ដង ទៅលើមនុស្ស៣០នាក់ផ្សេងៗគ្នា។ តើអ្នកទាំងអស់នេះមកពីកងពល៣១០ ឬក៏មកពីកន្លែងផ្សេង?

**ធ៖** ខ្ញុំបាទសូមឆ្លើយជូនអង្គតុលាការឲ្យបានជ្រាប។ អ្នកខ្លះគឺនៅក្នុងកងពល៣១០ អ្នកខ្លះជាទាហានចាស់ បាទ។

[០៩:១៦:២០]

**ស៖** លោកបានឆ្លើយថាគឺនៅក្នុងឆ្នាំ១៩៧៥។ នៅពេលនោះ លោកដឹងទេថា ហេតុអ្វីបានជាអ្នកទាំងនេះត្រូវបានគេចោទថាជាជនក្បត់?

**ធ៖** ខ្ញុំបាទសូមឆ្លើយជូនអង្គតុលាការ។ នៅពេលនោះខ្ញុំបាទពុំបានដឹងទេ ព្រោះខ្ញុំបាទជាជនពិការ គ្រាន់តែផ្ញើជីវិតនៅនឹងគេ អត់បានដឹងផ្ទៃក្នុងរបស់គេទេទានប្រុស។

**ស៖** លោកបានផ្តល់សក្ខីកម្មថា ប្រហែលជាក្នុងឆ្នាំ១៩៧៧ នៅមុនពេលត្រូវបានគេបញ្ជូនលោកទៅឲ្យលត់ដំយ៉ាងតឹងតែង។ លោកត្រូវបានគេនាំខ្លួនយកមកចូលក្នុងកិច្ចប្រជុំមួយ គឺចម្លើយរបស់លោកគឺ E3/3565។ ខ្មែរ និងភាសាបារាំងគឺ E3/3560 -- 03 ហើយបារាំង 00812791។ ខ្ញុំនឹងផ្តល់ជូនឲ្យបានត្រឹមត្រូវម្តងទៀតនូវឯកសារនេះគឺ ERN E3/3565, អង់គ្លេស 00863263, ខ្មែរ 00020646, បារាំង 00812790។ នៅក្នុងចម្លើយរបស់លោក លោកបានឆ្លើយថា៖ "អឿន នៅពេលដែល អឿន មេកងពលត្រូវបានចាប់ខ្លួននោះ មានការកោះហៅប្រជុំ ហើយគេចាក់ខ្សែអាត់។ ហើយខ្សែអាត់ដែលគេបានថតហ្នឹង គឺជាការរៀបរាប់អំពីប្រវត្តិរបស់ អឿន ហើយនិង តាគឹម គិតពីពេលតស៊ូជាមួយនឹងបដិវត្តន៍មក រហូតមកដល់ពេលគាត់ចាប់ផ្តើមធ្វើសកម្មភាពក្បត់។" លោកនៅចាំទេថា ពេលដែលលោកចូលក្នុងកិច្ចប្រជុំមួយហ្នឹង គេមានចាក់សំឡេងខ្សែអាត់ហ្នឹងឲ្យលោកស្តាប់? លោកចាំដែរឬក៏អត់ទេ?

[០៩:១៩:១២]

**ធ៖** ខ្ញុំបាទសូមឆ្លើយជូនអង្គតុលាការសូមឲ្យបានជ្រាប។ នៅពេលដែលគេចាប់ តាអឿន, តាគឹម ជាកងពលទៅ រួចគេនឹងហៅទ័ព ព្រមទាំងយើងខ្ញុំជាជនពិការទៅចូលរៀន ហើយបានស្តាប់ខ្សែអាត់ពិតមែន។

**ស៖** ហើយតាមដែលលោកដឹង នៅពេលដែលលោកស្តាប់ខ្សែអាត់ហ្នឹងទៅ តើសកម្មភាពរបស់ជនក្បត់ហ្នឹង ដែលគេចាក់ឲ្យលោកស្តាប់ហ្នឹង វាពិតជាសកម្មភាពក្បត់មែន ឬក៏អត់ទេ?

**ឆ៖** បើតាមខ្សែអាត់ដែលចាក់ឲ្យស្តាប់ គឺគាត់ឆ្លើយថា ក្បត់ខ្លួនគាត់ពិតប្រាកដ។

**ស៖** តាមដែលលោកដឹង នៅពេលនោះ ឬក៏ថានៅមុនការចាប់ខ្លួនរបស់ អឿន នេះ តើលោកដែលមានដែលបានដឹងថា អឿន នេះមានបំណងផ្តួលរំលំខ្មែរក្រហមដែរឬអត់ទេ?

**ឆ៖** បើតាមខ្ញុំបាទដឹង គឺកងពល៣១០ដែលមាន តាអឿន, តាគឹម នេះប្រុងផ្តួលរំលំខ្មែរក្រហម។

**ស៖** ចុះធ្វើម៉េចបានជាលោកដឹងថា តាអឿន, តាគឹម មានបំណងរំលំខ្មែរក្រហម?

[០៩:២១:៣៩]

**ឆ៖** ដោយខ្ញុំបាទបានឃើញគេដឹកកាំភ្លើង ហើយខ្ញុំបាទសួរគេថា "ដឹកកាំភ្លើងទៅណា?" គេថា "កុំចេះ!"។

**ស៖** ហើយនៅក្នុងចម្លើយរបស់លោកដែលខ្ញុំបានផ្តល់ ERN ពីមុនបន្តិចនេះហើយ តើលោកមានបានចូលរួម -- លោកបានឆ្លើយថា លោកចូលរួមរៀបចំវេចខ្ចប់ចំណីអាហារ។ លោកជួយរៀបចំបាយទឹកទៅឲ្យកងទ័ពសម្រាប់អ្នករៀបចំផែនការផ្តួលរំលំហ្នឹង លោកបានឆ្លើយថាអ៊ីចឹង។ អ៊ីចឹងមែនឬក៏អត់ទេ?

**ឆ៖** នៅពេលនោះ គេបានប្រើខ្ញុំឲ្យជួយវេចខ្ចប់បាយឲ្យគេ ពិតប្រាកដមែន។

**ស៖** តើលោកអាចជម្រាបជូនអង្គជំនុំជម្រះបាទទេ ដំបូងតើផែនការហ្នឹងបានអនុវត្តទេ? ផែនការដែលបាននិយាយគ្នា ផែនការដែលលោកបានរៀបចំ តើផែនការហ្នឹងបានធ្វើទៅបានសម្រេចទេ?

**ឆ៖** សូមជម្រាបជូនអង្គតុលាការ សូមបានជ្រាប--

[០៩:២៣:១៤]

**ប្រធានអង្គជំនុំ៖**

កុំទាន់អាលឆ្លើយតប! សូមអញ្ជើញលោកមេធាវី គង់ សំអុន!

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំសូមធ្វើការកត់សម្គាល់មួយទាក់ទងនឹងសំណួរចុងក្រោយរបស់តំណាងសហព្រះរាជអាជ្ញារង។ ការចោទសួរទៅលើសាក្សីឲ្យបញ្ជាក់អំពីថាផែនការបានសម្រេចឬយ៉ាងណានោះ ឬក៏ចាប់ផ្តើមធ្វើ ឬអត់នោះ ខ្ញុំគិតថា វាមានការលំបាកសម្រាប់សាក្សីធ្វើការវិនិច្ឆ័យទៅ

លើអំពើទាំងអស់នេះ។ សាក្សីបានបញ្ជាក់រួចហើយថា គាត់បានចូលរួមរៀបចំវេចបាយ ហើយម៉្យាងទៀតគាត់បានឃើញការដឹកកាំភ្លើងទៅទៀត។ អ៊ីចឹងនេះវាជាអង្គហេតុអាចបញ្ជាក់អំពីសកម្មភាពនោះបានហើយបាទ។ ក៏ប៉ុន្តែនៅពេលដែលសួរថា គាត់ឃើញអំពើហ្នឹងបានសម្រេច ឬអត់ វាអាចពិបាកនឹងយល់ថា អ្វីទៅដែលជាការសម្រេចនោះ? បាទ សូមអរគុណ។

**លោក វីណ្ណៀម ស្មីត៖**

ខ្ញុំដឹងថា យើងមិនដឹងថាបានសម្រេចរបៀបណា។ អ៊ីចឹងបានខ្ញុំសួរសំណួរហ្នឹង បើគាត់ឆ្លើយថា មិនដឹងទេ ឬក៏មិនបានសម្រេចទេ ខ្ញុំនឹងចូលប្រធានបទផ្សេងហើយ។

[០៩:២៤:៤០]

**សួរដោយលោក វីណ្ណៀម ស្មីត៖**

**ស៖** ពាក់ព័ន្ធទៅនឹងការចូលរួមរបស់លោកក្នុងការវេចខ្ចប់ចំណីអាហារបាយទឹក។ តើលោកដឹងទេថា មានផែនការចង់ផ្តួលរំលំទេ? ដូចជាការប្រើប្រាស់អាវុធ តើមានឈានដល់ការប្រើប្រាស់អាវុធហើយឬនៅ តាមដែលលោកដឹង?

**លោក កែវ លឿ៖**

**ឆ៖** ពុំទាន់បានប្រើប្រាស់នៅឡើយទេ។ នៅពេលនោះ ដោយគេបានចាប់មេៗក្នុងខណៈនោះបាទ។

**ស៖** ពាក់ព័ន្ធទៅនឹងការចាប់ខ្លួនទាំងអស់ ការចាប់ខ្លួនមេដឹកនាំកងពលគឺ អឿន អនុរបស់ អឿន មេកងវរសេនាតូច មេកងវរសេនាធំ មេកងរបស់លោក មេកងវរសេនាតូច៣១០។ តាមដែលលោកកត់សម្គាល់ តើអ្នកទាំងអស់នេះ មានតដៃជាមួយនឹងការមកចាប់ខ្លួនពីសំណាក់កងទ័ពដទៃទេ? មានការតវ៉ាណាមួយ ការប្រឆាំងណាមួយ ឬក៏ការងើបឡើងបះបោរដោយប្រើអាវុធអីទេ ពាក់ព័ន្ធទៅនឹងដំណើរការចូលមកចាប់ខ្លួនអ្នកទាំងនេះ?

**ឆ៖** ខ្ញុំបាទ សូមឆ្លើយជូនអង្គតុលាការ។ នៅពេលនោះ ខ្ញុំបាទ ពុំបានដឹងទេ។

[០៩:២៦:២៧]

**ស៖** តាមរយៈការចាប់ខ្លួនទាំងអស់ដែលលោកបានឃើញនៅក្នុងពេលប្រជុំនៅឃ្លាំង កប់ស្រូវ អំពើទារុណកម្មដែលលោកបានឃើញនៅមន្ទីរពេទ្យកាល់ម៉ែត ការចាប់ខ្លួននៅការដ្ឋានការងារដែលលោកបានឃើញនៅព្រលានយន្តហោះកំពង់ឆ្នាំង តាមរយៈការចាប់ខ្លួន និងការធ្វើទារុណកម្មដែលលោក

បានឃើញនេះ លោកបានឃើញថា អ្នកទាំងអស់នោះមានការតដៃ ឬក៏មានការប្រយុទ្ធតបតទៅវិញណាមួយដែរទេ?

**ឆ៖** ខ្ញុំបាទ សូមឆ្លើយជូនអង្គតុលាការ។ នៅពេលនោះ មិនដែលឃើញមានអ្នកណាតដៃចំពោះគេទេ ព្រោះយើងអត់មានអាវុធកាន់នឹងដៃ។

**ស៖** សូមអរគុណ។ ហើយការចាប់ខ្លួនទាំងអស់ដែលលោកបានឃើញ ការចាប់ខ្លួនទាំងអស់ដែលលោកបានឮ តើលោកធ្លាប់បានឮអ្នកណាម្នាក់ក្នុងចំណោមអ្នកដែលគេបានចាប់ខ្លួននេះ ត្រូវបានគេនាំខ្លួនយកទៅជំនុំជម្រះជាសាធារណៈក្នុងប្រព័ន្ធតុលាការមួយជាសាធារណៈ ដើម្បីឈានដល់ការធ្វើសេចក្ដីសម្រេចណាមួយទេ?

**ឆ៖** ខ្ញុំបាទ សូមឆ្លើយជូនអង្គតុលាការ មិនដែលឃើញទេ។

**ស៖** ហើយថា តើលោកដឹងទេថា ហេតុ -- មូលហេតុអ្វីបានជាអ្នកទាំងនេះរៀបចំផែនការក្បាលម៉ាស៊ីនដឹកនាំ? ហេតុអីក៏មានផែនការរៀបចំ ដើម្បីត្រៀមអនុវត្ត? ហេតុអ្វីក៏អ្នកទាំងនោះ មានបំណងចង់ផ្ដួលរំលំក្បាលម៉ាស៊ីនដឹកនាំរបស់ខ្មែរក្រហម?

[០៩:២៨:៤០]

**ឆ៖** ខ្ញុំបាទ សូមឆ្លើយជូនអង្គតុលាការ។ នៅពេលនោះ ខ្ញុំបាទពុំបានដឹងអ្វីទេបាទ។

**ស៖** ការអនុវត្តរបៀបធ្វើទារុណកម្ម ដែលលោកបានឃើញនៅមន្ទីរពេទ្យកាល់ម៉ែត ក្នុងឆ្នាំ ១៩៧៥ តើកងទ័ពដែលនៅជាមួយលោកនោះ គេយល់ថាម៉េចដែរ? តើការធ្វើទារុណកម្មបែបនេះ គឺថាកងទ័ពដែលនៅជាមួយលោកទាំងអស់ គេស្ម័គ្រចិត្តទទួលទេ ថាជាការអនុវត្តធម្មតាទៅលើមនុស្សបែបហ្នឹង ឬក៏គេមានការភ័យខ្លាច?

**ឆ៖** ខ្ញុំបាទ សូមជម្រាបជូនអង្គតុលាការ។ នៅពេលនោះ ខ្ញុំបាទជាជនពិការ តែងតែសួរគេថាហេតុអីបានជាគេយកមនុស្សមកវ៉ៃសំពងបែបនេះ? ពួកទ័ពទាំងនោះ គេបានឆ្លើយថា “ឯងកុំចេះ ឯងពិការ នៅឲ្យស្ងៀម”។ ខ្ញុំបាទ ក៏មិនប៊ានតបតនឹងគេ ព្រោះឯងជាជនពិការ នៅធ្វើខ្លួននឹងគេបាទ។

**ស៖** នៅពេលមានការចាប់ខ្លួនពីទាហាននៅកងពល៣១០ នៅពេលដែលមានការចាប់ខ្លួនជាលើកដំបូង លោកដឹងនៅពេលណា? តើលោកមានដឹងថាមានការចាប់ខ្លួនកងទ័ពបក្សកុម្មុយនីស្តកម្ពុជានៅទីកន្លែងផ្សេងៗទៀតនៅទូទាំងផ្ទៃប្រទេសទេនៅពេលហ្នឹង?

**ឆ៖** ខ្ញុំបាទបានដឹងតាមរយៈគេនិយាយថា ចាប់ភូមិភាគនិរតីមុន បន្ទាប់មកចាប់ភូមិភាគឧត្តរ។

**ស៖** ខ្ញុំនឹងបញ្ចប់ប្រធានបទខ្លីៗពីរបីទៀតទេ។ នៅក្នុងចម្លើយរបស់លោក ដែលលោកឆ្លើយជូនអ្នកស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញនោះ លោកថា លោកបានឃើញ នួន ជា, អៀង សារី និង កែ ពក នៅព្រលានយន្តហោះកំពង់ឆ្នាំង។ តើលោកបានឃើញ នួន ជា នៅព្រលានយន្តហោះកំពង់ឆ្នាំងប៉ុន្មានដងដែរ?

**ឆ៖** ខ្ញុំបាទដូចមិនដែលបានឃើញលោក នួន ជា, ខៀវ សំផន ទេ បាទ។

[០៩:៣២:១៣]

**ស៖** តាមរយៈចម្លើយរបស់លោក គឺលោកមិនបានឆ្លើយថាលោកបានឃើញ ខៀវ សំផន ទេ។ ប៉ុន្តែលោកពិតជាបាននិយាយ និងពិតជាបានឆ្លើយទៅនឹងសំណួរទៅលើឯកសារ E3/467 អង់គ្លេស -- ខ្មែរ 00170620, បារាំង 00205078។ សំណួរសួរថា៖ “តើលោកមានបានឃើញមេដឹកនាំណាខ្លះនៅព្រលានយន្តហោះទេ?” លោកបានឆ្លើយថា៖ “ខ្ញុំបានឃើញ អៀង សារី, នួន ជា និង កែ ពក មកពិនិត្យមើលកន្លែងវាលយន្តហោះ។” ឥឡូវនេះលោកឆ្លើយបដិសេធថា លោកមិនបានឃើញ នួន ជា ឬក៏យ៉ាងម៉េចដែរតាមរយៈចម្លើយរបស់លោកនេះ?

**ឆ៖** ខ្ញុំបាទសូមឆ្លើយជូនអង្គតុលាការ។ ខ្ញុំបាទ មានការភ្លេចភ្លាំង ព្រោះយូរពេកបាទ មិនអាចចាំបាន។

**ស៖** ពីរសំណួរចុងក្រោយ និយាយអំពីរចនាសម្ព័ន្ធរបស់កងពល៣១០។ នៅក្នុងឯកសារមួយដែលតុលាការបានទទួលគឺ E3/1585 យើងខ្ញុំមិនត្រូវការបង្ហាញទេ គឺថានៅថ្ងៃទី២០ តុលា ១៩៧៦ នៅពេលនោះ នៅខែតុលា ១៩៧១ ថាសមមិត្តអឿន ជាលេខាកងពល និងសមមិត្តរឿង អនុកងពល។ លោកបានឆ្លើយពីខាងដើមថា តាគឹម ជាអនុកងពល៣១០។ តើ តាគឹម ត្រូវបានអ្នកណាជំនួសដែរឬក៏អត់ទេ? តើ តាគឹម ត្រូវបានគេដាក់ជំនួសដោយសមមិត្ត រឿង ដើម្បីឲ្យក្លាយជាអនុកងពល៣១០ នៅខែតុលា ១៩៧៦ លោកបានដឹងរឿងនេះទេ?

**ឆ៖** ខ្ញុំបាទមានការភ្លេចភ្លាំង ពុំបានចាំទេ។

**លោក វីណ្សៀម ស្មីត៖**

សូមអរគុណ។ លោកប្រធាន ខ្ញុំអស់សំណួរហើយ។

[០៩:៣៥:១៩]

**ប្រធានអង្គជំនុំ៖**

បាទ ជាបន្តទៅនេះអង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី។

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។ សូមគោរពលោក លោកស្រីចៅក្រម។ ជម្រាបសួរលោកសាក្សី ខ្ញុំឈ្មោះ ម៉ារី ហ្គីរ៉ូដ៍ ខ្ញុំជាមេធាវីអន្តរជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណី។ ខ្ញុំមានសំណួរមួយចំនួនខ្លីទេ បន្ទាប់មកខ្ញុំប្រគល់វេទិកានេះជូនមេធាវី ជេត វណ្ណលី នៅពេលចុងក្រោយ។

**ការតាំងសំណួរដោយសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

**សួរដោយលោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

**ស៖** សំណួររបស់ខ្ញុំ គឺពាក់ព័ន្ធទៅនឹងបទពិសោធន៍របស់លោក នៅការដ្ឋានសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំង។ ខ្ញុំចង់ចាប់ផ្តើមដោយសួរសំណួរពាក់ព័ន្ធទៅនឹងពេលដែលលោកទៅដល់ព្រលានយន្តហោះ។ កាលពីថ្ងៃសុក្រលោកបានឆ្លើយថា លោកបានទៅដល់នៅថ្ងៃទី១៥ មេសា ឆ្នាំ១៩៧៨ ហើយលោកចាំកាលបរិច្ឆេទនេះច្បាស់លាស់។ អ៊ីចឹងខ្ញុំចង់ដឹងថា នៅពេលដែលទៅដល់ទីនោះៗ គឺមានតែក្រុមរបស់លោកទេ ឬក៏លោកទៅដល់ហ្នឹង មានក្រុមផ្សេងៗទៀតគេមកចូលរួមជាមួយនឹងលោកដែរ?

[០៩:៣៦:៤២]

**លោក កែវ លឿ៖**

**ឆ៖** នៅពេលដែលខ្ញុំបាទ ទៅដល់កំពង់ឆ្នាំង មិនមែនជាក្រុមរបស់ខ្លួនទេ គឺចម្រុះគ្នាបាទ។

**ស៖** នៅពេលដែលអ្នកស៊ើបអង្កេតរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាសួរលោក គឺឯកសារ E3/5658 ERN ជាភាសាអង់គ្លេស 00863291, ជាភាសាខ្មែរ 00020667, ជាភាសាបារាំង 00812781។ លោកបានឆ្លើយដូចតទៅ ពាក់ព័ន្ធនឹងថ្ងៃដែលលោកទៅដល់ ថ្ងៃទី១៥ មករា ៧៨ លោកបានឆ្លើយដូចតទៅ ខ្ញុំសូមដកស្រង់៖ “មានមនុស្សជាច្រើនដែលមកពីកងផ្សេងៗ គឺមានរាប់ពាន់នាក់ សុទ្ធតែចាស់ៗទាំងអស់។” តើចម្លើយនេះធ្វើឲ្យលោកនឹកឃើញឡើងវិញទេ?

**ឆ៖** ខ្ញុំបាទនៅចាំបានថា នៅពេលនោះគឺគេយកទ័ពចាស់ៗ ទ័ពដែលជាប់និន្នាការពីកងពលចាស់រៀងខ្លួន ទៅធ្វើការនៅកន្លែងនោះ។

**ស៖** តើលោកដឹងទេថា នៅសម័យនុ៎ងមានកងពលផ្សេងៗទៀតហ្នឹងទៅដល់ថ្ងៃតែមួយជាមួយលោកទេ គឺ១៥ មករា ៧៨នោះ?

**ឆ៖** ខ្ញុំបាទពុំបានដឹងទេ។ ដឹងតែខ្លួនឯងដែលទៅដល់ថ្ងៃនោះ។

[០៩:៣៨:៥៤]

**ស៖** នៅពេលដែលលោកទៅដល់ការដ្ឋានភ្លាមហ្នឹង គេមានរៀបចំប្រជុំអីណែនាំទេ?

**ឆ៖** បាទ គេណែនាំអំពីការធ្វើព្រលានយន្តហោះ មានការជីកស្មៅ និងតាមរើសជាដើម។

**ស៖** ខ្ញុំសូមអានឃ្លាមួយ នៃចម្លើយរបស់លោកនៅចំពោះមុខអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេត គឺឯកសារ E3/467 ERN ជាភាសាអង់គ្លេស 00205084, ជាភាសាខ្មែរ 00170620, បារាំង 00205078។ លោកបានលើកឡើងអំពីការប្រជុំមួយ ហើយខ្ញុំនឹងអានឲ្យលោកស្តាប់ បន្ទាប់មកខ្ញុំនឹងសួរសំណួរលោក។ លោកបាននិយាយនៅពេលនោះថា “នៅពេលប្រជុំ គេប្រាប់ថាឲ្យយើងលត់ដំ ពីព្រោះមេៗរបស់យើងជាជនក្បត់។ បើយើងមិនលត់ដំទេ គេនឹងចាប់យើង។ តាល្វៃមកពីភូមិភាគពាយ័ព្យ ជាអ្នកកាន់កាប់វាលយន្តហោះ។” លោកសាក្សី នៅពេលដែលលោកទៅដល់ភ្លាម ឬក៏ប៉ុន្មានថ្ងៃក្រោយមកនោះ តើគេមានប្រជុំហើយដែលមាន ល្វៃ ជាអ្នកដឹកនាំ ហើយដែលលោកបានចូលរួមហ្នឹងទេ?

**ឆ៖** នៅពេលដែលទៅដល់ គេប្រជុំឲ្យយើងលត់ដំ ហើយចំពោះ តាល្វៃ កម្រដែលឃើញ។ ឃើញតែគាត់ជិះឡានមួយភ្លែតៗ មិនដែលបានជួបគ្នាទេបាទ។

**ស៖** នៅពេលដែលលោកនិយាយថាការប្រជុំអប់រំហ្នឹង តើលោកអាចពន្យល់បានទេថា នៅពេលគេប្រជុំហ្នឹង គេនិយាយអំពីអ្វីខ្លះ? នៅក្នុងឯកសាររបស់លោកនោះ លោកបាននិយាយថា គេប្រាប់ថាឲ្យលត់ដំ ពីព្រោះថាមេៗរបស់យើងហ្នឹងជាជនក្បត់។ អ៊ីចឹងតើលោកមាននៅចាំទេថានៅពេលប្រជុំហ្នឹង គេនិយាយអីខ្លះទៅ?

[០៩:៤១:៤៦]

**ឆ៖** គេបាននិយាយថា “មិត្តទាំងអស់គ្នាជាទ័ពចាស់ដែលជាប់និន្នាការ ហើយមកពេលនេះគឺត្រូវតែលត់ដំ។ កិច្ចការងារទាំងអស់មិនត្រូវត្អូញត្អែរ ទោះមានជំងឺឈឺថ្កាត់យ៉ាងណា វៀរលែងតែដួលទៅមិនរួច ត្រូវតែអត់ធ្មត់ ព្រោះមេៗរបស់មិត្តឯងរាល់គ្នា ក្បត់អស់ហើយៗពួកមិត្តឯងទាំងអស់គ្នានេះសុទ្ធតែជាអ្នកជាប់និន្នាការពីមេៗរបស់មិត្តឯង។ ដូច្នេះត្រូវតែខំប្រឹងធ្វើការ បើមិត្តណាមួយ មិនប្រឹង

ធ្វើការ ទម្រន់ គេនឹងចាប់យកទៅធ្វើទារុណកម្ម"។

**ស៖** នៅពេលប្រជុំណែនាំដែលលោកបាននិយាយហ្នឹង តើមានតែកងរបស់លោកទេ ដែលចូលរួម ឬក៏មានទាហានមកពីកងផ្សេងៗទៀតដែរបានចូលរួម?

**ឆ៖** បាទ មកពីគ្រប់អង្គភាពដែលទៅធ្វើការនៅកន្លែងនោះ បាទ។

**ស៖** តើលោកអាចប៉ាន់ប្រមាណអំពីចំនួនអ្នកចូលរួមហ្នឹងបានទេ ១០នាក់ជាង ២០នាក់ជាង ៣០នាក់ជាង ឬក៏១០០នាក់ជាង លោកចាំពីចំនួនហ្នឹងទេ?

**ឆ៖** ខ្ញុំបាទ ពុំបានចាំច្បាស់ទេ។ មនុស្សដែលប្រជុំនៅកន្លែងមួយៗមានរាប់រយបាទ។

**ស៖** នៅពេលដែលលោកនិយាយអំពីកិច្ចប្រជុំផ្សេងៗ អ៊ីចឹងនៅពេលដែលលោកធ្វើការនៅទីនោះ លោកធ្លាប់ចូលរួមកិច្ចប្រជុំផ្សេងទៀតទេ? ហើយប្រសិនបើធ្លាប់នោះ តើលោកអាចចាំទេថា បើសរុបទៅលោកបានចូលរួមប្រជុំហ្នឹងប្រហែលប៉ុន្មានដងដែរ?

[០៩:៤៤:២១]

**ឆ៖** ខ្ញុំបាទ បានចូលរួមប្រជុំគេ ដែលគេហៅទៅប្រជុំហ្នឹង ពីរបីដងហ្នឹង។

**ស៖** នៅពេលដែលលោកចូលប្រជុំហ្នឹង តើអ្នកណាជាអ្នកដឹកនាំអង្គប្រជុំ?

**ឆ៖** ខ្ញុំបាទពុំបានស្គាល់ឈ្មោះមេៗទេ ព្រោះពួកអ្នកមេដឹកនាំ គេមកពីភូមិភាគនិរតី។ មិនប៊ានមើលមុខគេផង។

**ស៖** ក្នុងពេលប្រជុំលោកមានធ្លាប់ឃើញគេចាប់ខ្លួនមនុស្ស ហើយនាំយកចេញទៅទេ?

**ឆ៖** បាទ ធ្លាប់ឃើញ ហើយនាំចេញទៅ។

**ស៖** ចុះពេលដែលចាប់យកទៅហើយ ក្រោយមកលោកមានឃើញអ្នកដែលចាប់ខ្លួនហ្នឹងត្រឡប់មកវិញទេ?

**ឆ៖** មិនដែលឃើញវិលវិញទេ អ្នកដែលចាប់ខ្លួនទៅ។

**ស៖** កាលពីថ្ងៃសុក្រ លោកធ្លាប់បានស្នាក់នៅជាមួយនឹងក្រុមទាហានពិការ ហើយក្រោយមកទៀត ពេលដែលបណ្តុះបណ្តាលនៅភ្នំពេញហើយ លោកបានស្នាក់នៅកន្លែងមួយទៀត។ អ៊ីចឹងខ្ញុំចង់ដឹងអំពីខែដំបូងដែលលោកបានបោចស្មៅ ជម្រះស្មៅ តើលោកអាចជម្រាបបានទេ ថានៅក្នុងអង្គភាពរបស់លោកនៅក្នុងខែដំបូងដែលលោកទៅដល់កំពង់ឆ្នាំងហ្នឹង លោកមានគ្នាប៉ុន្មាននាក់ដែរ? កាលពីថ្ងៃសុក្រ លោកនិយាយដូចជាមិនសូវច្បាស់ លោកចង់ដឹងថាតើមានគ្នាប្រហែលជាប៉ុន្មាន ដប់ប្លាយ មួយរយប្លាយ

ឬក៏រាប់ពាន់?

**ឆ៖** នៅពេលដែលខ្ញុំជីកស្មៅ តាមរើស អង្គភាពដែលខ្ញុំរស់នៅ គឺមានគ្នា៣០នាក់។ តែនៅធ្វើការក្នុងនោះ ផ្នែកផ្សេងៗទៀតមានច្រើន រាប់ពាន់នាក់។

[០៩:៤៧:១២]

**សៈ** ដូច្នេះនៅពេលដែលលោកបោចស្មៅ គឺលោកធ្វើការនៅក្នុងអង្គភាពមានគ្នា៣០នាក់ គឺនៅរួមគ្នា ជាមួយនឹងទាហានរាប់ពាន់នាក់ផ្សេងទៀត។ លោកចង់និយាយអ៊ីចឹងមែនទេ អម្បាញ់មិញនេះ?

**ឆ៖** បាទ ការងារនៅព្រលានយន្តហោះគឺ ជួបមនុស្សច្រើន ប៉ុន្តែដល់ពេលសម្រាក ក៏យើងសម្រាកបែកជាក្រុមៗ នៅដោយឡែកៗពីគ្នាបាទ មិនបានស្គាល់គ្នាទេ។

**សៈ** តើទាហានរាប់ពាន់នាក់ដែលធ្វើការហ្នឹង ស្លៀកសម្លៀកបំពាក់ៗខ្មៅមែនទេ?

**ឆ៖** បាទ គឺមានខោអាវខ្មៅស្លៀក។

**សៈ** លោកទើបតែឆ្លើយថា លោកឃើញអ្នកធ្វើការជាច្រើននៅពេលថ្ងៃ ព្រោះថាលោកធ្វើការនៅជិតៗពួកគេ ក៏ប៉ុន្តែពេលយប់ឡើង គឺសម្រាករៀងៗខ្លួន។ តើលោកអាចជម្រាបបានទេ ថាលោកពេលយប់ឡើងសម្រាកនៅកន្លែងណាដែរ?

**ឆ៖** ខ្ញុំបាទ ពុំបានចាំភូមិគេទេ មិនស្គាល់ទេ តែសម្រាកនៅខាងលិចព្រលានយន្តហោះ។ គេឲ្យនៅតាមក្រុមនីមួយៗ រៀងៗខ្លួនបាទ។

[០៩:៤៩:០១]

**សៈ** ខ្ញុំចង់ដឹងថាលោកសម្រាកពេលយប់ហ្នឹងនៅក្នុងការដ្ឋានហ្នឹង ឬក៏នៅខាងក្រៅការដ្ឋានទេ?

**ឆ៖** ខ្ញុំបាទ សូមជម្រាបជូនអង្គសវនាការ គឺនៅក្រៅការដ្ឋាន ឆ្ងាយពីការដ្ឋាន។

**សៈ** តើកន្លែងដែលលោកសម្រាក និងកន្លែងដែលលោកធ្វើការហ្នឹង មានចម្ងាយពីគ្នាប្រហែលប៉ុន្មានម៉ែត្រដែរ?

**ឆ៖** ចម្ងាយពីក្រុមមួយទៅក្រុមមួយ ប្រហែលជា២០ ឬ ៣០ម៉ែត្រពីក្រុមមួយទៅក្រុមមួយ។

**សៈ** ខ្ញុំមិនមែនចង់ដឹងអ៊ីចឹងទេ។ លោកសាក្សីខ្ញុំចង់ដឹងថា ពេលដែលលោកភ្ញាក់ឡើងពេលព្រឹកលោកទៅធ្វើការនោះ តើលោកប្រើពេលប៉ុន្មាន ហើយចម្ងាយប៉ុន្មានពីកន្លែងដែលលោកសម្រាកពេលយប់មកកន្លែងធ្វើការមកការដ្ឋាននេះ? ខ្ញុំចង់ដឹងថាប្រហែលជាប៉ុន្មានម៉ែត្រដែរ? ជិត ឬក៏ឆ្ងាយ? ហើយលោកប្រើពេលប៉ុន្មានទើបទៅដល់កន្លែងធ្វើការក្រោយពីភ្ញាក់ពីគេងហើយនោះ?

**ឆ៖** ខ្ញុំបាទសូមជម្រាបជូនអង្គតុលាការ នៅកន្លែងសម្រាកឆ្ងាយពីការដ្ឋានប្រហែលជា១គីឡូ។

**ស៖** តើលោកអាចរៀបរាប់កន្លែងលោកសម្រាកបានទេ? មានជញ្ជាំង មានដំបូល មានមុង មានអង្រឹងអីទេ?

**ឆ៖** ខ្ញុំបាទសូមជម្រាបជូនអង្គតុលាការ គេធ្វើកូនផ្ទះប្រក់ស្លឹក ជញ្ជាំងស្លឹក តែគ្មានមុង គ្មានអង្រឹង ឬក៏ភួយដណ្ដប់ គឺអត់មានទេ។

[០៩:៥១:៤៩]

**ស៖** តើលោកសម្រាកនៅក្នុងផ្ទះហ្នឹងមានគ្នាប៉ុន្មាននាក់ដែរ?

**ឆ៖** ក្នុងមួយផ្ទះគេដាក់១៥នាក់។

**ស៖** សូមអរគុណ។ កាលពីថ្ងៃសុក លោកបាននិយាយអំពីកងអង្គភាពពេទ្យ នេះតាមរយៈខ្ញុំស្ដាប់ឮពីការបកប្រែជាភាសាបារាំងមកគឺអ៊ីចឹង។ តើលោកអាចបញ្ជាក់បានទេថា តើអង្គភាពពេទ្យហ្នឹងយ៉ាងម៉េចដែរ?

**ឆ៖** អង្គភាពពេទ្យគេដើរតាមមើល បើអ្នកណាដួលគេឲ្យថ្នាំលេបតែប៉ុណ្ណោះ។

**ស៖** លោកនៅចាំទេ តើថ្នាំដែលគេឲ្យហ្នឹងជាថ្នាំប្រភេទណាដែរ?

**ឆ៖** ខ្ញុំបាទសូមជម្រាបជូនអង្គតុលាការ ថ្នាំប្រភេទថ្នាំសួន មិនមែនថ្នាំពេទ្យមកពីនាយទេ សូមមេត្តាទានជ្រាប។

**ស៖** តើលោកដឹងថា នៅកំពង់ឆ្នាំងនៅពេលនុំងមានមន្ទីរពេទ្យទេ?

**ឆ៖** នៅកន្លែងក្រុងគេមាន តែនៅកន្លែងខ្ញុំបាទពុំមានទេ។

**ស៖** តើលោកចាំទេថានៅពេលដែលគ្នារបស់លោកឈឺនោះ គេមានធ្លាប់បញ្ជូនទៅមន្ទីរពេទ្យទេពេលដែលឈឺធ្ងន់?

**ឆ៖** ខ្ញុំបាទនៅចាំបាន នៅពេលដែលមានមិត្តផងគ្នាឈឺធ្ងន់ គេយកឡានដឹក គេថាយកទៅក្រុងបាទ។

[០៩:៥៤:៤៩]

**ស៖** ចុះលោកមានឃើញមិត្តផងគ្នាហ្នឹងត្រឡប់មកវិញទេ ក្រោយពីគេដឹកតាមឡានយកទៅក្រុងហើយនោះ?

**ឆ៖** មិត្តដែលមានជំងឺ ដែលគេដឹកទៅក្រុង ពីរឬបីថ្ងៃឃើញវិលមកវិញ ធ្វើការធម្មតា។

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកសាក្សី។ លោកប្រធាន ខ្ញុំសូមអនុញ្ញាតប្រគល់វេទិកាជូនសហភាតារបស់ខ្ញុំ។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត។សូមអញ្ជើញ!

**លោកស្រី ជេត វណ្ណលី៖**

សូមគោរពលោកប្រធាន។ សូមគោរពលោក លោកស្រីចៅក្រម និងសូមគោរពអង្គសវនាការទាំងមូល។

[០៩:៥៥:៤៩]

**សួរដោយលោកស្រី ជេត វណ្ណលី៖**

**ស៖** ជម្រាបសួរលោកសាក្សី ខ្ញុំឈ្មោះមេធាវី ជេត វណ្ណលី ជាមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី។ ចាប់ពីថ្ងៃសុក្រមក ខ្ញុំបានសង្កេតឃើញថាលោកបានឆ្លើយបំភ្លឺចំពោះអង្គសវនាការនៅចំណុចមួយចំនួន។ ហើយឥឡូវនេះ ខ្ញុំចង់ឲ្យលោកបញ្ជាក់នូវចំណុចមួយចំនួនបន្ថែមទៀត ដើម្បីជាពន្លឺដល់អង្គសវនាការ។ ខ្ញុំចង់ឲ្យលោកបញ្ជាក់ដែរថា ពេលដែលលោកចេញពី ក-៤ នៅឃ្លាញ និងកប់ស្រូវ ហើយត្រូវគេបញ្ជូនទៅព្រលានយន្តហោះកំពង់ឆ្នាំង។ ដូចលោកបញ្ជាក់នៅមុខសវនាការរួចហើយថា នៅថ្ងៃទី១៥ ខែ០១ ឆ្នាំ៧៨ ខ្ញុំចង់ឲ្យលោកបញ្ជាក់ដែរថា តើពេលដែលគេបញ្ជូនលោកទៅ តើគេប្រាប់លោកថាម៉េច?

**លោក កែវ លឿ៖**

**ឆ៖** ខ្ញុំបាទសូមជម្រាបអង្គសវនាការ។ នៅពេលនោះគេថា "ឲ្យពួកអ្នែងទៅធ្វើព្រលានយន្តហោះនៅកំពង់ឆ្នាំង"។

**ស៖** អរគុណលោក។ តើអ្នកណាជាអ្នកប្រាប់លោកពេលនុ៎ង?

[០៩:៥៧:៣១]

**ឆ៖** ខ្ញុំបាទ នៅចាំបានថា នៅពេលនោះគឺឈ្មោះ សមមិត្តដឹន ដែលមកពីភូមិភាគនិរតី ហើយមកទទួលគ្រប់គ្រងជំនួស គេបានប្រាប់យ៉ាងនេះមែនបាទ។

**ស៖** អរគុណលោក។ នៅពេលនោះ លោកមានឈ្មោះ -- លោកបានបញ្ជាក់នៅមុខតុលាការរួចហើយថា លោកមិនមែនជាកងទ័ពដូចមុនទេ មិនអ៊ីចឹងលោក? ហើយគេដកកាំភ្លើងលោកតាំងពីពេលណាមក ពេលនុ៎ង មុននឹងបញ្ជូនលោកទៅ?

**ឆ៖** ខ្ញុំបាទសូមជម្រាបជូនអង្គតុលាការ ខ្ញុំបាទពុំមានសិទ្ធិកាន់កាំភ្លើងតាំងពីធ្លាក់ខ្លួនពិការដែលទៅនៅផ្ញើខ្លួននឹងគេ មុននឹងទៅ ក-៤។

**សៈ** អរគុណលោក។ ពេលដែលលោកទៅដល់ តើទៅជាក្រុម ឬក៏ទៅតែក្រុមកងពលរបស់លោក ឬមួយមានក្រុមផ្សេងៗទៀតទៅជាមួយគ្នា? ហើយពេលទៅដល់ហ្នឹង គេប្រគល់លោកឲ្យអ្នកណា? អ្នកណាដែលជាមកទទួលក្រុមរបស់លោកហ្នឹង ពេលដែលទៅដល់ការដ្ឋានហ្នឹង?

[០៩:៥៨:៥៩]

**ឆ៖** ខ្ញុំបាទសូមជម្រាបជូនអង្គតុលាការ នៅពេលដែលខ្ញុំបាទទៅនេះ គឺមានសមមិត្តទន់ ហើយនៅភូមិភាគនិរតីជាអ្នកទទួលនៅកំពង់ឆ្នាំង។

**សៈ** អរគុណ។ តើលោកពេលដែលលោកទៅដល់ភ្លាម លោកបានជួប តាល្វៃ ទេ?

**ឆ៖** ខ្ញុំបាទសូមជម្រាបជូនអង្គតុលាការ នៅពេលទៅដល់ភ្លាម ពុំបានឃើញទេ តាល្វៃ។

**សៈ** អរគុណ។ តើក្រោយប៉ុន្មានថ្ងៃ ក្រោយប៉ុន្មានពេលមកទើបលោកបានជួប តាល្វៃ ឬមួយក៏លោកធ្លាប់ប្រជុំជាមួយ តាល្វៃ ហ្នឹង?

**ឆ៖** ខ្ញុំបាទនៅចាំបានថា ក្នុងរយៈពេល២ខែក្រោយមកបានជួប តាល្វៃ។

**សៈ** តើ តាល្វៃ ជាអ្នកទទួលខុសត្រូវការដ្ឋានព្រលានយន្តហោះហ្នឹងមែនទេលោក?

**ឆ៖** បាទ តាល្វៃ ជាអ្នកទទួលខុសត្រូវនៅព្រលានយន្តហោះ។

**សៈ** អរគុណលោក។ ក្រៅពី តាល្វៃ តើលោកមានដែលឃើញថ្នាក់ដឹកនាំណាផ្សេងទៀតទេ? អ្នកបន្ទាប់ តាល្វៃ ឬក៏មេរបស់ តាល្វៃ លោកដែរឃើញអ្នកណាផ្សេងទៀតទេ ដែលចុះទៅការដ្ឋានហ្នឹង?

**ឆ៖** បន្ទាប់អំពី តាល្វៃ គឺមានឈ្មោះ តាម៉េត។

[១០:០១:១១]

**សៈ** អរគុណលោក។ តើ តាម៉េត ដែលទៅញឹកញាប់ទេ លោក?

**ឆ៖** ឈ្មោះ តាម៉េត នេះគាត់ទៅមើលម្តងៗ ប្រហែលជាមួយអាទិត្យម្តង។

**សៈ** ពេលដែលគាត់ទៅម្តងៗតើគាត់ជិះអីទៅ ហើយមានអង្គរក្សអីហែហាមគាត់ទៅច្រើនទៅទេ ឬក៏គាត់ដើរធម្មតាទៅការដ្ឋានហ្នឹង?

**ឆ៖** ពេលដែលគាត់ទៅមើលការដ្ឋាន តែងតែជិះឡានអាហ្ស៊ីបម៉ាស៊័រ ហើយមានអ្នកការពារពីរបីនាក់។

**ស៖** អរគុណលោក។ ក្រោយពី តាល្វៃ -- ក្រោយពី តាម៉េត ចុះមើលការដ្ឋានហើយ ពេលដែលចប់ទស្សនកិច្ចរបស់គាត់ហើយ គាត់ត្រឡប់មកបន្ទប់ធ្វើការជាមួយ តាល្វៃ វិញ ឬក៏គាត់ត្រឡប់ទៅវិញតែម្តង?

**ផ៖** ខ្ញុំបាទសូមជម្រាបជូនអង្គតុលាការថា ត្រង់ចំណុចនេះ ខ្ញុំបាទពុំបានដឹងទេថាគាត់ចេញទៅវិញនេះទៅខាងណា មកណា ព្រោះយើងអត់ប៉ានមើលមុខគេផង។

**ស៖** អរគុណ។ ខ្ញុំចង់ឲ្យលោកបញ្ជាក់ដែរថា ពីថ្ងៃមុនលោកបានបញ្ជាក់នៅមុខអង្គសវនាការថា មេៗរបស់ពួកភូមិភាគឧត្តរត្រូវចាប់អស់ ហើយយកពួកនិរតីមកជំនួស។ តើក្នុងចំណោមពួកនិរតីដែលមកជំនួសហ្នឹង លោកមាននៅចាំឈ្មោះអ្នកណាទេ? ហើយពេលនុ៎ងលោកដែលឃើញ តាម៉ុក ទៅកន្លែងការដ្ឋានហ្នឹងទេ?

[១០:០៣:១៨]

**ផ៖** ខ្ញុំបាទសូមជម្រាបជូនអង្គតុលាការ នៅពេលនោះគេយកភូមិភាគនិរតីមកក្តោបក្តាប់ជំនួសហើយពុំបានស្គាល់ឈ្មោះគេទេ ថ្នាក់ដឹកនាំរបស់គេ ប៉ុន្តែចំពោះ តាម៉ុក គឺមិនដែលឃើញបាទ។

**ស៖** លោកអត់ដែលចាំឈ្មោះដឹកនាំណាម្នាក់ ដែលជាខាងភូមិភាគនិរតីទេលោក?

**ផ៖** ខ្ញុំបាទនៅចាំបានថា អ្នកដែលទៅក្តាប់ ក-៤ ជំនួសភូមិភាគឧត្តរ ដែលគេចាប់ទាំងអស់ទៅនោះ គឺសមមិត្ត ដឺន។

**ស៖** អរគុណ។ ឥឡូវខ្ញុំបកទៅកន្លែងការដ្ឋានព្រលានយន្តហោះវិញ នៅពេលដែលលោកធ្វើការនៅការដ្ឋានព្រលានយន្តហោះ តើលោកដែលឃើញមានហេតុការណ៍អីកើតឡើងទេ? មានគ្រោះថ្នាក់ការងារអីទេ ឬក៏មានអត្តឃាតអីទេនៅកន្លែងព្រលានយន្តហោះហ្នឹង?

**ផ៖** ខ្ញុំបាទនៅធ្វើការព្រលានយន្តហោះ ធ្លាប់ឃើញមិត្តផងគ្នាដែលធ្វើការ ខ្លះក៏ដួលសន្លប់បាត់ស្មារតីក្នុងពេលដែលធ្វើការធ្ងន់។

**ស៖** អរគុណលោក។ នៅក្នុងចំណោមពលករដែលធ្វើការនៅការដ្ឋានព្រលានយន្តហោះហ្នឹង លោកបានបញ្ជាក់ហើយថា មានស្រី មានប្រុស។ តើចំនួនស្រី លោកសង្កេតឃើញ ចំនួនស្រីច្រើនជាងប្រុស ឬប្រុសច្រើនជាងស្រី? ហើយស្រីៗភាគច្រើនត្រូវទទួលកិច្ចការអីដែរ លោក?

[១០:០៥:២៦]

**ផ៖** ខ្ញុំបាទសូមជម្រាបអង្គតុលាការ ប្រុសច្រើនជាង ស្រីឃើញតិច តែគេធ្វើការដោយឡែកៗ

ពីគ្នា មិនអាចដឹងបានថាគេធ្វើអី គ្រាន់តែឃើញនៅពេលដែលធ្វើដំណើរចេញទៅធ្វើការតាមមុខសញ្ញា។

**ស៖** អរគុណ។ តាមការបញ្ជាក់របស់លោក យើងឃើញថា នៅក្នុងការដ្ឋានព្រលានយន្តហោះហ្នឹងមានមនុស្សច្រើន ច្រើនកងពលនៅទីហ្នឹង។ អ៊ីចឹងខ្ញុំចង់ជម្រាបសួរលោកដែរថា នៅពេលហូបតើគេហូបជារួម ឬក៏មុននឹងហូបហ្នឹងគេវៃជួងប្រមូលគ្នា គេចែករបប ឬគេឲ្យនៅអង្គុយនឹងតុ ហើយគេចែក? សូមឲ្យលោកបញ្ជាក់ពីពេលការហូបចុក។

**ឆ៖** ខ្ញុំបាទ សូមបញ្ជាក់អំពីការហូបចុក។ ហូបនេះ គេហូបទៅតាមកងធំ។ ពេលដែលយើងទៅពីការដ្ឋាន ទៅអង្គុយចាំ គេចែករបប។ បានសេចក្ដីថា បាយវាល់ចែកគ្នា។

**ស៖** លោកអាចប៉ាន់ស្មានបានទេ ដែលចំពោះរបបដែលឲ្យមួយចាន ឬក៏ហូបសេរីតែម្ដង ឬមួយមួយចានចង្អឹះ ឬមួយមួយចានធំ ហើយមានសម្ល ឬយ៉ាងម៉េច? សូមលោកបញ្ជាក់ឲ្យច្បាស់ពីបញ្ហាហ្នឹងបន្តិចចាស។

**ឆ៖** បាទ សូមបញ្ជាក់ជូនអង្គតុលាការ។ សម្លមាន ហើយបាយហ្នឹងមួយចានភាជន៍ ប៉ុន្តែមិនគ្រប់គ្រាន់ក្នុងការហូបចុករបស់យើងទេ។

[១០:០៧:២៣]

**ស៖** អរគុណលោក។ អ៊ីចឹងបើប៉ាន់ស្មានទៅទំហំការងារដែលលោកធ្វើ ប្រៀបធៀបនឹងការហូបចុកដែលផ្ដល់ឲ្យ តើគ្រប់គ្រាន់ទេលោក?

**ឆ៖** ខ្ញុំបាទ សូមជម្រាបជូនអង្គតុលាការ។ មិនអាចគ្រប់គ្រាន់ ដែលយើងធ្វើការធ្ងន់ហើយហូបតិច។

**ស៖** ខ្ញុំចង់ឲ្យលោកបញ្ជាក់ដែលថា ពីការរបៀបបែងចែកការងារ។ តើគេបែងចែកការងារវាមានការងារធ្ងន់ស្រាល គេបែងចែកតាមក្រុម ឬក៏យ៉ាងម៉េចលោក? ឬមួយក៏មនុស្សទាំងអស់ទៅធ្វើការងារតែមួយដូចគ្នា? ឬទៅតាមផ្នែកមួយៗ គេមានចែកតាមផ្នែកទេ? ហើយមនុស្សម្នាក់ៗទៅតាមផ្នែកមួយៗ ទទួលខុសត្រូវ មានមេទទួលខុសត្រូវ?

**ឆ៖** មនុស្សដែលធ្វើការនៅព្រលានយន្តហោះ គឺគេចែកតាមក្រុមនីមួយៗ ផ្នែកដោយខ្លួនៗ ទៅតាមទិសដៅ និងមុខសញ្ញាដែលខ្លួនត្រូវធ្វើ។

**ស៖** អរគុណលោក។ ក្នុងការធ្វើការដ្ឋាននៅព្រលានយន្តហោះនេះ តើភាគច្រើនគេប្រើសម្ភារៈផ្ទាល់ដៃ ឬក៏មានគ្រឿងចក្រជាម៉ាស៊ីនអីដែរ លោក? ដូចការវៃថ្មអី គេវៃដៃ ឬក៏ប្រើម៉ាស៊ីន?

**ឆ៖** ខ្ញុំបាទសូមបញ្ជាក់ជូនអង្គសវនាការ តាមមុខសញ្ញារៀងខ្លួន មុខសញ្ញាខ្លះគឺកាន់ចប ដូចជាអ្នកជីកស្មៅ តាមរើស ជីករណ្ដៅតាមឫស ហ្នឹងគឺចប។ រីឯអ្នកថ្ម គឺវៃនឹងញញួរ។

**ស៖** អរគុណលោក។ ចម្លើយរបស់លោកពីថ្ងៃមុន លោកបានបញ្ជាក់នៅមុខអង្គតុលាការថា លោកបានត្រូវគេបញ្ជូនឲ្យទៅរៀនសូត្រផ្នែកបច្ចេកទេសចំនួន៣ខែ។ ខ្ញុំចង់ឲ្យលោកបញ្ជាក់ដែលថា តើអ្នកដែលបញ្ជូន អ្នកដែលសុំឲ្យលោកបានទៅរៀនហ្នឹងឈ្មោះ ផាន ឬឈ្មោះ ហាន? ហើយគាត់មានតួនាទីអីដែរនៅទីនុ៎ង?

**ឆ៖** ខ្ញុំបាទសូម--

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញលោកស្រីមេធាវី អង់តា ហ្គីសសេ!

[១០:១០:២៧]

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមឲ្យបំភ្លឺនូវកំណត់ត្រាប្រតិចារឹកទេ។ នៅជាភាសាបារាំងនោះយើងមិនបានឮនិយាយថា សាក្សីនេះទៅទទួលការអប់រំរយៈពេល៣ខែទេ។ គាត់ដូចទំនងជានិយាយអំពីការបណ្ដុះបណ្ដាលផ្នែកស្ទង់ដីនោះទេ លោកប្រធាន។ អ៊ីចឹងឃើញថាមានភាពលម្អៀងមិនត្រឹមត្រូវ។

**សួរដោយលោកស្រី ជេត វណ្ណលី៖**

**ស៖** ខ្ញុំគ្រាន់តែចង់ឲ្យសាក្សីបញ្ជាក់ថា គេមានបញ្ជូនលោកឲ្យទៅរៀនបណ្ដុះបណ្ដាលខាងផ្នែកស្ទង់ដី។ អ៊ីចឹងបានថា ហើយលោកបានបញ្ជាក់ដែរថា លោកបានទៅរៀនដោយសារឈ្មោះ ហាន ឬ ខ្ញុំមិនដឹងថាឈ្មោះ ហាន ឬ ផាន ដែលបញ្ជូន -- ដែលជួយសុំឲ្យលោកបានទៅរៀនហ្នឹង?

**លោក កែវ លឿ៖**

**ឆ៖** ខ្ញុំបាទសូមជម្រាបជូនអង្គសវនាការ មានឈ្មោះ ហាន ជាអ្នកសុំឲ្យខ្ញុំទៅរៀនខាងបច្ចេកទេសថ្លឹងដី គឺគាត់ឈ្មោះ ហាន។

**ស៖** អរគុណលោក។ សូមលោកជួយបញ្ជាក់ជូនអង្គសវនាការ តើបច្ចេកទេសថ្លឹងដីហ្នឹងយ៉ាងម៉េចដែរលោក? រៀនយ៉ាងម៉េចដែរចាស៎?

[១០:១២:០៧]

**ឆ៖** ខ្ញុំបាទសូមឆ្លើយអង្គ -- ជូនអង្គតុលាការបានជ្រាប។ ខ្ញុំបាទឆ្លើយនេះរាងវែងបន្តិច ដើម្បីឲ្យអង្គតុលាការបានលោកបានជ្រាប។ របៀបថ្លឹងដី របៀបថ្លឹងដីនេះគឺមុនដំបូងឲ្យរ៉ូឡូកិន គម្រប់ហាប់ទើបបំបែកសព្វ។ រួចហើយមានកែវមួយយកទៅវ៉ៃ វ៉ៃពន្លិចនឹងដី។ ហើយយកមក យកកាំបិតចិតរួចហើយ ខែយកដីនោះបញ្ចូលដាក់ក្នុងផ្តិល រួចដាក់ទៅក្នុងកែវ។ ពេលណាទម្ងន់ដីកម្រិតហាប់បាន៩០ភាគរយ អាចសន្មតថានឹងធ្វើការ -- នឹងធានាបាន១ទូវទម្ងន់។ បើត្រឹម៧០ភាគរយ គឺឲ្យរ៉ូឡូគេកិនមួយសាទៀត។ នេះខ្ញុំបាទសូមជម្រាបជូនអង្គតុលាការ សូមមេត្តាជ្រាប។

**ស៖** អរគុណលោក។ តើរៀនបច្ចេកទេសថ្លឹងដីហ្នឹង លោកបានបញ្ជាក់នៅអង្គសវនាការពីថ្ងៃសុក្រហើយ ថាលោករៀននៅភ្នំពេញ។ តើនៅពេលដែលលោករៀននៅភ្នំពេញ តើគ្រូបរទេស ឬគ្រូខ្មែរដែលបង្រៀនលោក? ហើយលោករៀននៅកន្លែងណានៅភ្នំពេញ?

**ឆ៖** ខ្ញុំបាទសូមជម្រាបជូន។ រៀននេះនៅភ្នំពេញ តែខ្ញុំបាទពុំបានស្គាល់ថា កន្លែងនោះជាកន្លែងអ្វី។ តាមខ្ញុំបាទស្មានគឺនៅខាងកើតវាលវង់យន្តហោះពោធិ៍ចិនតុង។

[១០:១៤:០៣]

**ស៖** ហើយអ្នកដែលបង្រៀនលោកហ្នឹងជាគ្រូខ្មែរ ឬជាគ្រូបរទេសលោក?

**ឆ៖** នៅពេលដែលខ្ញុំបាទចូលរៀនសូត្រ គ្រូបង្ហាត់ចិន តែបកប្រែជាភាសាខ្មែរគេមានចឹបក។

**ស៖** អរគុណលោក។ ក្រៅពីការរៀនបច្ចេកទេសដែលលោកទៅរៀននៅភ្នំពេញ តើលោកមានរៀនការបំពាក់បំប៉នខាងគោលនយោបាយអីទេ ពេលដែលលោកទៅរៀនហ្នឹង?

**ឆ៖** ក្រៅពីការរៀនបច្ចេកទេស គេបានបំពាក់បំប៉នថា ឲ្យខ្ញុំប្រឹងប្រែងកិច្ចការងារដែលត្រូវធ្វើទៅតាមមុខសញ្ញានីមួយៗ។ ឧទាហរណ៍ មិត្តឯងនៅខាងថ្លឹងដី ប្រសិនណាបើជាមិត្តឯងថ្លឹងហើយភ្លាត់ ដីមិនគ្រប់កម្រិតហាប់ ថ្ងៃក្រោយគេតាមដាន គេនឹងបញ្ជូនមិត្តឯងទៅដាក់គុកហើយ។ នេះខ្ញុំបាទសូមជម្រាបជូនអង្គសវនាការបានជ្រាប។

**ប្រធានអង្គជំនុំ៖**

បាទ អស់ពេលហើយលោកស្រីមេធាវី។ បាទឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះទៅរហូតដល់ម៉ោងដប់កន្លះ សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរ-ការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី និងអ្នក

ជំនាញដល់សាក្សីរូបនេះ នៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញ នៅវេលាម៉ោងដប់កន្លះ។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១០:១៦នាទី ដល់ម៉ោង ១០:៣៤ នាទី)*

[១០:៣៤:២២]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

បាទ អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយមុននឹងផ្តល់វេទិកាជូនទៅក្នុងសហមេធាវីការពារក្តី ហើយទំនងជាអស់លោក លោកស្រីចៅក្រម មានសំណួរចំពោះសាក្សីនេះ ហើយប្រសិនបើមានសូមអញ្ជើញបាទ។

បាទសូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

សូមអរគុណលោកប្រធាន។

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** ជម្រាបសួរលោកសាក្សី។ ខ្ញុំមានសំណួរមួយចំនួនតូចដើម្បីបញ្ជាក់ទៅលើចម្លើយរបស់លោក ដែលលោកបានឆ្លើយរហូតមកទល់នឹងពេលនេះ។ លោកសាក្សី តើលោកអាចរៀបរាប់ឲ្យបានច្បាស់បន្តិចទេ ថាតើនៅព្រលានយន្តហោះពោធិ៍ចិនតុងហ្នឹងមានសម្ភារៈ និងមានអគារអីយ៉ាងម៉េចខ្លះដែរ? លោកអាចរៀបរាប់បានទេ? មានវាលយន្តហោះ មានផ្លូវចុះចត ឬក៏មានអីយ៉ាងម៉េច មានទំហំប៉ុនណាអី លោកអាចរៀបរាប់បានទេ?

[១០:៣៥:៣៧]

**លោក កែវ លឿ៖**

**ឆ៖** ខ្ញុំបាទសូមជម្រាប នៅព្រលានយន្តហោះពោធិ៍ចិនតុងដែលខ្ញុំបាទបានមករៀនសូត្រនេះ ខ្ញុំបាទពុំបាន -- ពុំអាចនឹងស្មានបានថាទំហំប៉ុនណាទេ តែគ្រាន់តែកន្លែងស្នាក់នៅគឺនៅផ្ទះថ្មធម្មតា។

**ស៖** ប្រហែលជាមានបញ្ហាយល់គ្នា។ ខ្ញុំអម្បាញ់មិញនេះ មិននិយាយអំពីពោធិ៍ចិនតុងទេ គឺខ្ញុំ

និយាយអំពីកំពង់ផ្ទាំង។ តើលោកអាចជម្រាបបានទេថា នៅកំពង់ផ្ទាំងហ្នឹងមានផ្លូវយន្តហោះទេ? មានផ្លូវចុះហោះឡើងទេ? ហើយលោកអាចរៀបរាប់ពីទំហំផ្លូវហ្នឹងបានទេ?

**ឆ៖** នៅព្រលានយន្តហោះកំពង់ផ្ទាំង ផ្លូវមានបណ្តោយ១៨០០ សម្រាប់យន្តហោះចុះចត ហើយផ្លូវនេះ ទាំងសងខាងផ្លូវ ផ្លូវពីរ ហើយទាំងសងខាងផ្លូវគឺក្នុងមួយទទឹង៥០ម៉ែត្រ ផ្លូវមួយ។

**ស៖** ប្រសិនបើយើងធៀបជាមួយនឹងផ្លូវហោះនៅពោធិ៍ចិនតុង តើនៅកំពង់ផ្ទាំងហ្នឹងតូចជាងធំជាង ឬក៏ស្មើនឹងផ្លូវហោះនៅពោធិ៍ចិនតុង?

**ឆ៖** ខ្ញុំបាទសូមជម្រាបជូន នៅពោធិ៍ចិនតុង ខ្ញុំបាទពុំបានដឹងទេ ដឹងតែកំពង់ផ្ទាំង ហើយទទឹងគឺមាន៥០ម៉ែត្រ ហើយព័ទ្ធជុំវិញព្រលានហ្នឹង។

**ស៖** តើលោកអាចរៀបរាប់ថាតើមានរូងភ្នំគេជីកនៅទេ?

**ឆ៖** មានក្រុមគេជីករូងសម្រាប់លាក់យន្តហោះ។

[១០:៣៨:៤០]

**ស៖** តើលោកដឹងទេថា យន្តហោះប្រភេទណាដែលគេយកទៅលាក់ក្នុងរូងភ្នំដែលគេជីកហ្នឹង?

**ឆ៖** ខ្ញុំបាទពុំបានដឹងថាយន្តហោះប្រភេទណាទេ។ គ្រាន់តែគេប្រាប់ថា រូងលាក់យន្តហោះ។

**ស៖** គេលាក់យន្តហោះហ្នឹងជាយន្តស៊ីវិល ឬក៏យន្តហោះយោធា?

**ឆ៖** បើតាមខ្ញុំបាទដឹងគឺយន្តហោះយោធា។

**ស៖** ខ្ញុំចង់ត្រឡប់មកក្រោយបន្តិច គឺនៅសម័យដែលលោកចូលបដិវត្តន៍។ កាលពីថ្ងៃសុក្រលោកបានបញ្ជាក់ថាលោកបានចូលបដិវត្តន៍នៅពេលអាយុ១៨ឆ្នាំ។ តើលោកអាចជម្រាបបានទេថាលោកចូលបដិវត្តន៍ហ្នឹងចូលដោយស្ម័គ្រចិត្ត ឬក៏ដោយគេបង្ខំ?

**ឆ៖** ខ្ញុំបាទសូមជម្រាបជូនអង្គតុលាការ ខ្ញុំបាទពុំបានស្ម័គ្រចិត្តចូលទ័ពទេ គឺគេបង្ខំឲ្យចូល។

**ស៖** គេបង្ខំលោកបែបណាដែរ នៅពេលនោះ?

**ឆ៖** ខ្ញុំបាទសូមជម្រាបជូនអង្គតុលាការ នៅពេលនោះគេហៅឪពុកយកទៅប្រជុំ ហើយគេប្រាប់ថា អ្នកណាមិនព្រមលះបង់កូនចៅឲ្យទៅសមរភូមិទេនោះ គឺគេនឹងធ្វើទុក្ខទោសដល់ម៉ែឪ ដូច្នេះត្រូវតែជំរុញកូនចៅឲ្យទៅ។

**ស៖** ដូច្នេះ លោកបានចូលបដិវត្តន៍ដោយសារតែគេគំរាមកំហែងថានឹងធ្វើបាបឪពុករបស់លោកបើសិនជាលោកមិនចូលធ្វើយោធានោះ។ អ៊ីចឹងមែនទេ?

[១០:៤១:៤៤]

**ឆ៖** ខ្ញុំបាទសូមជម្រាបថា ពិតប្រាកដមែន។

**ស៖** ចាប់ពីពេលដែលលោកចូលធ្វើកងទ័ពមក តើលោកមានចូលរួមក្នុងវគ្គបំពាក់បំប៉នមនោគមន៍វិជ្ជាទេ? គេមានបង្រៀនលោកអំពីលទ្ធិបដិវត្តន៍ទេ? ហើយបើមាន តើគេធ្វើអ្វីខ្លះនៅក្នុងពេលលោករៀនសូត្រនុំង?

**ឆ៖** គេបង្រៀនឲ្យយល់អំពីមាគ៌ាបដិវត្តន៍ ឲ្យយល់អំពីសក្តិភូមិ នាយទុន ប្រតិកិរិយា។

**ស៖** តើគេមានប្រាប់ឲ្យលោកចងកំហឹងជាមួយនឹងក្រុមនាយទុន ប្រតិកិរិយាហ្នឹងទេ?

**ឆ៖** គេបានបំពាក់បំប៉នឲ្យយើងម្នាក់ៗមានកំហឹងឈឺចាប់ចំពោះនាយទុន ប្រតិកិរិយា និងសក្តិភូមិ។

**ស៖** ហើយនៅពេលដែលគេប្រាប់ថា ឲ្យសងសឹកនាយទុន ប្រតិកិរិយា សក្តិភូមិហ្នឹង តើមានន័យថាម៉េច? គឺត្រូវសម្លាប់ពួកហ្នឹងចោលឲ្យអស់ ឬក៏យ៉ាងម៉េច? គេប្រាប់លោកយ៉ាងម៉េចដែរ នៅពេលនុំងដែលថា ឲ្យចងកំហឹងពួកនាយទុន ប្រតិកិរិយា សក្តិភូមិនោះ?

**ឆ៖** គេឲ្យយើងចងកំហឹងចំពោះនាយទុន ប្រតិកិរិយា គេឲ្យយើងមានការឈឺចាប់បាទ ហើយនិងរំដោះវណ្ណៈក្រីក្រ។

[១០:៤៤:២៤]

**ស៖** តើគេត្រូវចងកំហឹងហ្នឹងដោយរបៀបណា? ត្រូវសងសឹកយ៉ាងម៉េចអីទេ? គេមានប្រាប់ថាត្រូវធ្វើយ៉ាងម៉េចចំពោះពួកដែលមានវណ្ណៈទាំងអស់ហ្នឹងទេ? គេមាននិយាយថា ត្រូវតែលុបបំបាត់ចោលវណ្ណៈនាយទុន ប្រតិកិរិយា សក្តិភូមិហ្នឹងទេ?

**ឆ៖** គេបានបំពាក់បំប៉នថា កម្ទេចចោលនូវរបបនាយទុន ប្រតិកិរិយាឲ្យអស់ពីទឹកដីកម្ពុជា។

**ស៖** មុនពេលលោកចូលបដិវត្តន៍ លោកជាព្រះសង្ឃហើយរៀននៅសាលាមែនទេ -- រៀននៅវត្តមែនទេ?

**ឆ៖** ខ្ញុំបាទសូមឆ្លើយជូនអង្គតុលាការសូមមេត្តាជ្រាប។ ខ្ញុំបាទនៅវត្តតាំងពីអាយុ៦ឆ្នាំ រហូតដល់បានបួសបានរៀននៅសាលាពុទ្ធិកបឋមសិក្សា និងបានទទួលសញ្ញាប័ត្របាលីរងពិតប្រាកដមែន។

**ស៖** តើនៅពេលវគ្គបំពាក់បំប៉នហ្នឹង គេមានបង្រៀនអ្វីខ្លះពាក់ព័ន្ធទៅនឹងសាសនា ព្រះពុទ្ធសាសនា ឬក៏សាសនាផ្សេងទៀតដូចជាសាសនាគ្រិស្ត សាសនាអ៊ិស្លាមជាដើម? តើគេមានប្រាប់លោក

អំពីអ្វីខ្លះពាក់ព័ន្ធនឹងបញ្ហាសាសនានេះ?

[១០:៤៦:២៧]

**ឆ៖** នៅពេលដែលខ្ញុំបាទត្រូវគេបង្រៀនឲ្យមានការឈឺចាប់ សូម្បីតែព្រះពុទ្ធសាសនាក៏គេថា សាសនាជិះជាន់ ដូចជាសមមិត្តឯងដែលធ្លាប់បួស គឺជាអនុធនសង្ឃ – អនុធនសិស្សជាសង្ឃ ធ្លាប់ជិះជាន់ពលកម្មគេ។

**ស៖** តើលោកធ្លាប់ឃើញគេធ្វើបាបព្រះសង្ឃទេ ឬក៏លោកធ្លាប់ឃើញខ្មែរក្រហមបំផ្លាញរបស់របរផ្សេងៗនៅតាមវត្តទេ?

**ឆ៖** ខ្ញុំបាទសូមជម្រាបជូនអង្គតុលាការ។ នៅឆ្នាំ៧០រហូតដល់៧៣ មិនទាន់ឃើញមានអ្វីទេ ព្រះសង្ឃនៅជាព្រះសង្ឃដដែល។

**ស៖** ចុះក្រោយឆ្នាំ១៩៧៣ ឬក៏មកដល់ឆ្នាំ១៩៧៥នោះ លោកធ្លាប់ឃើញរឿងរ៉ាវដែលខ្ញុំបាននិយាយអម្បាញ់មិញហ្នឹងទេ?

**ឆ៖** ក្រោយឆ្នាំ១៩៧៣ គេឲ្យលោកសង្ឃចុះធ្វើស្រែខ្លួនឯង និងឲ្យទៅធ្វើស្ពានទៅតាមការដ្ឋានតាមទីកន្លែង ហើយដល់៧៥ គឺគេផ្សឹកព្រះសង្ឃចេញអស់។

**ស៖** លោកឃើញរឿងហ្នឹងដោយផ្ទាល់ភ្នែក ឬក៏លោកគ្រាន់តែស្ដាប់ឮពីគេនិយាយមកតៗគ្នាទេ?

[១០:៤៨:៥៨]

**ឆ៖** ខ្ញុំបាទពុំបានឃើញផ្ទាល់ភ្នែកទេ គឺដឹងតាមរយៈមិត្តៗដែលគេចូលទៅក្រោយៗ ព្រោះខ្ញុំបាទនៅជួរមុខ។

**ស៖** តើលោកធ្លាប់ឃើញមានការកម្ទេចគ្រឹះស្ថានសាសនាទេ ដូចជាវត្ត ឬក៏ព្រះវិហារសាសនាគ្រិស្តជាដើមនោះ?

**ឆ៖** ខ្ញុំបាទសូមជម្រាបជូនអង្គតុលាការ នេះវាទៅក្រោយ ខ្ញុំបាទឃើញទ័ពគេវ៉ៃព្រះវិហារកាតូលិក កាលដែលខ្ញុំបាទនៅជាជនពិការនៅជាមួយកងពល។

**ស៖** គេកម្ទេចព្រះវិហារកាតូលិកនេះនៅកន្លែងណាដែរលោក?

**ឆ៖** គេកម្ទេចព្រះវិហារកាតូលិក គឺនៅខាងលិចវត្តភ្នំ។

**ស៖** ចុះលោកដឹងថា គេមានកម្ទេចវត្តទេ ឬក៏គេកម្ទេចព្រះពុទ្ធរូបអីទេ?

**ឆ៖** នៅពេលនោះ ខ្ញុំបាទពុំទាន់បានដឹងថា គេកម្ទេចវត្ត និងព្រះពុទ្ធរូបទេ បាទ។

**ស៖** ចុះពេលក្រោយ លោកឃើញ ឬក៏យ៉ាងម៉េច? ហើយបើឃើញ ឃើញគេធ្វើយ៉ាងម៉េចខ្លះ?

**ឆ៖** ខ្ញុំបាទសូមជម្រាបជូនអង្គតុលាការ។ ថ្ងៃក្រោយក៏ខ្ញុំបាទពុំបានឃើញគេកម្ទេចវត្តនោះទេ ឃើញតែមួយនោះឯងបាទ។

[១០:៥១:៥៦]

**ស៖** តើលោកមានមិត្តភក្តិដែលធ្លាប់ជាព្រះសង្ឃទេ? ហើយមិត្តភក្តិជាព្រះសង្ឃហ្នឹងមានបានមកជួបលោក រៀបរាប់ប្រាប់លោកអំពីរឿងរ៉ាវដែលពួកគាត់បានជួបប្រទះទេ? មានរឿងអ៊ីចឹងទេ?

**ឆ៖** ខ្ញុំបាទមានមិត្តភក្តិដែលបួសជាសង្ឃដូចគ្នា ហើយគេបានរៀបរាប់ប្រាប់ខ្ញុំបាទថា យើងនៅសមរភូមិក្រោយ គេកម្ទេចវត្តអារាមហើយ ហើយវត្តមួយៗ គេយកដាក់ធ្វើជាកន្លែងសិប្បកម្ម។

**ស៖** ឥឡូវនេះខ្ញុំចូលទៅប្រធានបទផ្សេង។ ខ្ញុំចង់សួរសំណួរលោកមួយចំនួនដើម្បីបំពេញបន្ថែមទៅលើសំណួររបស់សហព្រះរាជអាជ្ញាពាក់ព័ន្ធទៅនឹងកិច្ចប្រជុំ ដែលនៅក្នុងពេលនោះគេចាក់ផ្សាយខ្សែអាត់សំឡេងមួយ ដែលនិយាយអំពីចម្លើយសារភាពរបស់ តាអឿន និង តាគឹម ដែលជាមេរបស់លោក។ តើលោកដឹងទេ ថាគេបានខ្សែអាត់ហ្នឹងមកពីណាដែរ? គេមានប្រាប់លោកទេក្នុងពេលប្រជុំហ្នឹង ថាគេបានមកពីណា ហើយគេចាក់ហ្នឹងដើម្បីអីទេ?

**ឆ៖** ខ្ញុំបាទសូមឆ្លើយអង្គតុលាការសូមបានជ្រាប។ នៅពេលដែលគេហៅទ័ព ទាំងអ្នកពិការទាំងអស់ទៅរៀន នៅពេលនោះគេបានប្រាប់ថា "អ្នកទាំងអស់គ្នាចង់ដឹងទេ ជីវប្រវត្តិរបស់មេៗពួកអស់ឯង"។

[១០:៥៤:៤៤]

**ស៖** ហើយគេពេលដែលនិយាយថា មេៗហ្នឹងគេសំដៅលើអ្នកណាដែរ ទៅលើកម្មាភិបាលណា? ព្រោះព្រឹកមិញនេះយើងនិយាយអំពី តាអឿន និង តាគឹម អ៊ីចឹងតើគេមានសំដៅលើកម្មាភិបាលណាផ្សេងទៀតទេ?

**ឆ៖** គេនិយាយសំដៅទៅលើ តាអឿន និង តាគឹម ដែលចោទថាក្បត់។

**ស៖** គេមានបានប្រាប់ទេថា គេយកចម្លើយសារភាពហ្នឹងមកពីណា ហើយគេថតពីកន្លែងណា?

**ឆ៖** នៅពេលនោះ គេពុំបានប្រាប់ថា គេយកចម្លើយមកពីណាទេ គ្រាន់តែប្រាប់ថា "នេះជាចម្លើយរបស់មេៗ ពួកអស់ឯង។ ចាំស្តាប់"។ អ៊ីចឹងយើងខ្ញុំទាំងអស់គ្នាក៏ប្រុងចាំស្តាប់ បានទើបក្រោយ

មកទើបដឹងថា អូ! នេះសំឡេងរបស់ថ្នាក់ដឹកនាំរបស់ខ្លួន។

**ស៖** លោកនៅពេលនោះមានធ្លាប់ឮគេនិយាយអំពី ស-២១ ទេ?

**ឆ៖** ខ្ញុំបាទ បានដឹងតាមរយៈដែលស្តាប់សំឡេងខ្មែរអាត់រួចហើយ ពួកគេបានប្រកាសថា "មិត្តទាំងអស់គ្នា មេៗរបស់មិត្តឯងគឺយកទៅ ស-២១"។

**ស៖** ដូច្នេះផ្អែកតាមចម្លើយសារភាពដែលទទួលបានពី ស-២១ គេបានចោទប្រកាន់មេៗរបស់លោកជាសាធារណៈ ថាជាជនក្បត់។ តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ ពិតប្រាកដមែន។

[១០:៥៧:៣១]

**ស៖** យើងនឹងមិនពិភាក្សាអំពីខ្លឹមសារនៃចម្លើយសារភាពជាខ្មែរអាត់នេះទេ ក៏ប៉ុន្តែលោកបានឆ្លើយកាលពីព្រឹកមិញនេះ ទៅនឹងសំណួររបស់សហព្រះរាជអាជ្ញាថា បើតាមគំនិតរបស់លោក គឺមានផែនការដើម្បីផ្តួលរំលំរបបខ្មែរក្រហម។ លើកលែងតែខ្ញុំស្តាប់ច្រឡំ លោកបានឆ្លើយថា លោកកត់សម្គាល់ឃើញថា មានការដឹកអាវុធ និងគ្រាប់រំសេវ។ តើលោកអាចរៀបរាប់ឲ្យបានច្បាស់អំពីអ្វីដែលលោកឃើញផ្ទាល់ភ្នែកទេ ថាគេដឹកយ៉ាងម៉េច? គេដឹកអ្វីខ្លះ? ហើយហេតុអ្វីបានជាលោកប៊ានសន្និដ្ឋាន ឬក៏ប៊ានអះអាងថា មានផែនការផ្តួលរំលំរបបខ្មែរក្រហមនោះ?

**ឆ៖** នៅពេលនោះ ខ្ញុំបាទឃើញគេដឹកកាំភ្លើង ហើយខ្ញុំបានសួរគេថា ចុះគេដឹកកាំភ្លើងមកដាក់ធ្វើអីនៅក្បែរៗនេះ។

**ស៖** លោកអាចឆ្លើយឲ្យបានច្បាស់ជាងហ្នឹងបន្តិចបានទេ? គេដឹកកាំភ្លើងហ្នឹងពីណាទៅណា? ហើយគេយកទៅទុកនៅកន្លែងណា? ហើយហេតុអីបានជាលោកគិតថា កាំភ្លើងហ្នឹងគេទុកសម្រាប់ផ្តួលរំលំរបបខ្មែរក្រហមនោះ?

**ឆ៖** កាំភ្លើងដែលគេដឹកទៅ គឺគេដាក់ឆ្ពោះតម្រង់ទៅទីក្រុងភ្នំពេញ។ ហើយពួកមេៗ គេបាននិយាយគ្នាថា នៅពេលដែលយើងទុកកាំភ្លើង គឺចង់ឲ្យទ័ពមានប្រាក់ខែ និងរស់នៅស្រួល កុំឲ្យពិបាក។

[១១:០០:១០]

**ស៖** មេណាដែលលោកនិយាយហ្នឹង តាអឿន និង តាគីម មែនទេ? ឬក៏លោកសំដៅទៅលើមេណាផ្សេងទៀត?

**ឆ៖** គឺ តាអឿន ជាអ្នកនិយាយបាទ។

**ស៖** ដូច្នេះ តាអឿន គាត់និយាយទៅកាន់កូនក្រុម កូនចៅរបស់គាត់ -- កូនទាហានរបស់គាត់ មែនទេ? គាត់និយាយថា ចង់ឲ្យកងទ័ពមានជីវភាពប្រសើរ មានប្រាក់ខែអ៊ីចឹងមែនទេ គាត់និយាយអ៊ីចឹង មែនទេ?

**ឆ៖** បាទ គឺគាត់និយាយបែបនេះឯងបាទ។

**ស៖** តើគាត់មានបាននិយាយដោយផ្ទាល់ថា ត្រូវតែផ្ដួលរំលំរដ្ឋអំណាចហ្នឹងទេ ដើម្បីឲ្យទាហាន រស់នៅស្រួលនោះ? គាត់បាននិយាយ -- មានបាននិយាយអំពីការដណ្ដើមអំណាចតាមរយៈការធ្វើរដ្ឋ-ប្រហារទេ?

**ឆ៖** គាត់បាននិយាយថា ដើម្បីឲ្យទ័ពមានប្រាក់ខែ ទ័ពដែលតស៊ូទាំងប៉ុន្មានបានសុខស្រួល ទាល់តែយើងវាយបកទៅលើកម្ពុជាប្រជាធិបតេយ្យ។

**ស៖** លោកស្ដាប់ឮសម្ដីហ្នឹងដោយផ្ទាល់ត្រចៀកលោក ឬក៏លោកស្ដាប់ឮនៅពេលដែលគេចាក់ ផ្សាយចម្លើយសារភាពរបស់គាត់ហ្នឹងទេ គឺប្រហែលជាមកពី ស-២១ នោះ?

**ឆ៖** ខ្ញុំបាទ បានស្ដាប់តាមចម្លើយសារភាពចេញពី ស-២១។

[១១:០២:៤២]

**ស៖** ឥឡូវសូមទុកចម្លើយសារភាព ស-២១ ហ្នឹងចោលសិន។ នេះជាបញ្ហាដែលអង្គជំនុំជម្រះ នឹងពិនិត្យនៅពេលក្រោយ។ ខ្ញុំមិននិយាយអំពីការស្ដាប់ខ្សែអាត់ទេ ខ្ញុំចង់សំដៅលោកផ្ទាល់នេះ ព្រោះ លោក លោកធ្លាប់បានចូលរួមនៅក្នុងកិច្ចប្រជុំដែល តាអឿន គាត់បាននិយាយដោយផ្ទាល់ថា ត្រូវតែផ្ដួល រំលំរដ្ឋអំណាចខ្មែរក្រហម។ លោកមានបានស្ដាប់ឮអ៊ីចឹងផ្ទាល់ពី តាអឿន ទេ?

**ឆ៖** គឺបានស្ដាប់ពិតមែន។

**ស៖** លោកអាចជម្រាបបានទេ លោកស្ដាប់ហ្នឹងស្ដាប់ឮនៅពេលណា? ហើយគាត់បាននិយាយ អ្វីខ្លះ?

**ឆ៖** ខ្ញុំបាទបានស្ដាប់នៅពេលដែលគាត់ប្រជុំ គាត់ថា "ទ័ពដែលមានកម្លាំងខ្លាំងជួរមុខ ហើយ ពួកពិការគេឲ្យត្រៀមបាយទឹកសម្រាប់ទ័ព រៀបចំដើម្បី -- រៀបចំធ្វើសកម្មភាពវាយទីក្រុងភ្នំពេញដើម្បី ផ្ដួលរំលំរបបកម្ពុជាប្រជាធិបតេយ្យ"។

**ស៖** លោកចាំកាលបរិច្ឆេទនៃការធ្វើកិច្ចប្រជុំហ្នឹងទេ?

**ឆ៖** ខ្ញុំបាទពុំបានចាំខែថ្ងៃទេ។

**សៈ** នៅពេលប្រជុំហ្នឹងលោកនៅអង្គភាព ក-៤ ដដែល លោកនៅភ្នំពេញខាងជើងពោធិ៍ចិនតុង ឬក៏នៅកន្លែងណា?

**ឆៈ** នៅពេលនោះគឺខ្ញុំ ខ្ញុំបាទនៅក្នុងវរៈ នៅក្នុងអង្គភាពវរៈ ក-៤ នៅខាងជើងពោធិ៍ចិនតុង។

[១១:០៥:៣០]

**សៈ** លោកបានរៀបរាប់អំពីលក្ខខណ្ឌការងារនៅកន្លែងនោះ។ អ៊ីចឹងតើនៅពេលនោះគេធ្វើបាបលោករួចទៅហើយមែនទេ? គេអប់រំកសាងលត់ដំលោករួចទៅហើយ មែនទេនៅពេលនុ៎ង ឬក៏តាំងពីមុនហ្នឹងទៀត?

**ឆៈ** ខ្ញុំសូមបញ្ជាក់ជូនអង្គតុលាការបានជ្រាប នៅពេលនោះមិនទាន់យកទៅលត់ដំទេ គឺទ័ពពិការនៅធ្វើស្រែធម្មតា និងធ្វើទៅតាមកម្លាំងដែលខ្លួនធ្វើបាន។

**សៈ** អ៊ីចឹងការលត់ដំហ្នឹងធ្វើឡើងនៅក្រោយពេលគេចាប់ខ្លួន តាអឿន និង តាគឹម មែនទេ? ប្រហែលជាចាប់ខ្លួនហើយប៉ុន្មានដែរ បានលោកគេបញ្ជូនទៅអប់រំលត់ដំហ្នឹង?

**ឆៈ** ខ្ញុំបាទសូមជម្រាបជូនអង្គតុលាការ។ ក្រោយពេលគេចាប់ តាអឿន, តាគឹម មេៗអស់ទៅ គេមានភូមិភាគនិរតីមកគ្រប់គ្រងនៅអង្គភាពនេះ ចម្រុះ។ រួចហើយ ក្រោយមកគេបញ្ជូនឲ្យយើងខ្ញុំទៅលត់ដំនៅវរៈ៣១៧ គឺនៅឃ្លាំង កប់ស្រូវ។

**សៈ** តើគេមានប្រជុំច្រើនដងទេ? ហើយពេលប្រជុំហ្នឹង តាអឿន គាត់មានបាននិយាយអំពីការផ្តួលរំលំរបបខ្មែរក្រហមនោះ ឬក៏មានការប្រជុំតែម្តងទេ?

**ឆៈ** ចំពោះរឿងនេះ ខ្ញុំបាទដឹងតែម្តងទេ។

[១១:០៨:០៤]

**សៈ** ហើយនៅពេលប្រជុំម្តងហ្នឹង តើមានអ្នកចូលរួមប៉ុន្មាននាក់ដែរ?

**ឆៈ** គឺគេប្រជុំកម្មាភិបាលយុទ្ធជនទាំងអស់ រួមទាំងយើងខ្ញុំដែលនៅអង្គភាពពិការទាំងអស់គ្នាជាសមាជិកនៅក្នុងកងពលទាំងមូល។

**សៈ** គឺមួយកងពលទាំងមូលហ្នឹងប៉ុន្មាននាក់ដែរ? បើខ្ញុំយល់មិនច្រឡំទេ គឺអង្គភាពជនពិការរបស់លោកហ្នឹងគឺថាមានគ្នាប្រហែលជា៦០០នាក់។ ដូច្នេះមួយកងពលហ្នឹងគឺ ទាំងអស់ហ្នឹងប៉ុន្មាននាក់ដែរដែលបានចូលរួមក្នុងកិច្ចប្រជុំហ្នឹង?

**ឆៈ** ខ្ញុំបាទពុំបានចាំបានថាមនុស្សមានចំនួនប៉ុន្មានទេ គ្រាន់តែគេហៅទៅទ័ព ទាំងទ័ពទាំង

ពិការ ទៅទាំងអស់គ្នាប្រជុំ។

**ស៖** តើការប្រជុំហ្នឹងប្រព្រឹត្តទៅនៅកន្លែងណា?

**ឆ៖** ខ្ញុំបាទនៅចាំបានថា ការដែលគេយកទៅប្រជុំគឺនៅចុងខាងជើងវត្តភ្នំ។

**ស៖** អ៊ីចឹងមានន័យថា ការប្រជុំហ្នឹងគឺនៅភ្នំពេញ មែនទេ?

**ឆ៖** បាទ។

[១១:១០:២៩]

**ស៖** ហើយកាំភ្លើងហ្នឹងគេដឹកយកមកភ្នំពេញហ្នឹងមែនទេ? នៅពេលដែលប្រជុំហ្នឹង គឺកាំភ្លើងគេដឹកយកមកដល់ហើយ រួចស្រេចបាច់ហើយ ឬក៏យ៉ាងម៉េច?

**ឆ៖** នៅពេលប្រជុំ កាំភ្លើងគេត្រៀមនៅខាងក្រៅ។

**ស៖** ដូច្នេះកាំភ្លើងហ្នឹងគេដឹកយកមកដាក់នៅកន្លែងប្រជុំហ្នឹងតែម្តង ឬក៏ដឹកយកទៅទុកនៅកន្លែងណាផ្សេងសិន?

**ឆ៖** កាំភ្លើងនេះ គេដឹកទៅទុកកន្លែងផ្សេងសិន។

**ស៖** លោកដឹងថា គេទុកអាវុធហ្នឹងនៅកន្លែងណាទេ ទុកកាំភ្លើងទាំងអស់ហ្នឹង?

**ឆ៖** គេពុំបានឲ្យខ្ញុំបាទអ្នកពិការនេះឃើញទេ។

**ស៖** ក៏ប៉ុន្តែលោកឃើញផ្ទាល់ភ្នែកថា អាវុធហ្នឹងនៅភ្នំពេញហើយ ឬក៏លោកគ្រាន់តែឮគេប្រាប់ថា ឥឡូវគេដឹកកាំភ្លើងទាំងអស់ហ្នឹងមកដល់ភ្នំពេញហើយទេ?

**ឆ៖** ខ្ញុំបាទពុំបានឃើញផ្ទាល់នឹងភ្នែកទេ គឺគ្រាន់តែឮមេៗថា កាំភ្លើងគេដឹកមកហើយ រៀបចំ។

[១១:១២:៤៦]

**ស៖** ដូច្នេះគឺ តាអឿន ជាអ្នកប្រាប់លោកថាកាំភ្លើងហ្នឹងគេដឹកមកដល់ភ្នំពេញហើយ អ៊ីចឹងមែនទេ?

**ឆ៖** បាទ។

**ស៖** តើគាត់មានបាននិយាយថាត្រូវធ្វើរដ្ឋប្រហារផ្តួលរំលំរបបខ្មែរក្រហមហ្នឹងនៅពេលណាទេ?

**ឆ៖** គាត់បាននិយាយថា "មិត្តទាំងអស់គ្នាចាំតែមើលទៅ នៅពេលណាដែលយើងអាចធ្វើទៅបាន"។

**ស៖** ដូច្នេះគាត់មិនបានបញ្ជាក់ថា ត្រូវចាប់ផ្តើមធ្វើរដ្ឋប្រហារនៅថ្ងៃណាៗទេ គាត់គ្រាន់តែ

និយាយថា នឹងចាប់ផ្តើមក្នុងពេលឆាប់ៗនេះ។ គាត់មានបាននិយាយអីលម្អិតទេ ពាក់ព័ន្ធនឹងថ្ងៃចាប់ផ្តើមធ្វើរដ្ឋប្រហារផ្តួលរំលំរដ្ឋអំណាចខ្មែរក្រហមនោះ?

**ឆ៖** បើតាមខ្ញុំបាទដឹងពុំបានលម្អិតទេ គ្រាន់តែប្រាប់ថា ដើម្បីចង់ឲ្យទ័ពមានប្រាក់ខែ ហើយទ័ពរស់នៅស្រួល និងបានទៅលេងឪពុកម្តាយ។

[១១:១៤:៤០]

**ស៖** តើក្នុងចំណោមអ្នកដែលចូលរួមប្រជុំហ្នឹង មានអ្នកណាប្រកែកតវ៉ាទេ ឬក៏ទាំងអស់គ្នាឯកភាពទាំងអស់គ្នាតែម្តង ថាត្រូវធ្វើរដ្ឋប្រហារ?

**ឆ៖** នៅក្នុងពេលប្រជុំ ខ្ញុំបាទពុំមានឃើញអ្នកណាម្នាក់តវ៉ា។

**ស៖** តើលោកអាចជម្រាបបានទេថា ក្រោយពីកិច្ចប្រជុំហ្នឹងប៉ុន្មានថ្ងៃ ឬប៉ុន្មានខែដែរ ដែល តាអឿន និង តាគឹម ត្រូវបានគេចាប់ខ្លួន? ខ្ញុំដឹងថាវាស្មុគស្មាញ ក៏ប៉ុន្តែលោកអាចនឹកឃើញកាលបរិច្ឆេទទេ?

**ឆ៖** ខ្ញុំបាទពុំបានចាំខែថ្ងៃ តែក្រោយប្រជុំគឺយប់នោះ គឺត្រូវគេចាប់កងពលនៅថ្ងៃនោះបាទ។

**ស៖** តើលោកគិតថា តាអឿន និង តាគឹម ហ្នឹងគាត់ក្បត់មែនទេ?

**ឆ៖** តាមទស្សនៈរបស់ខ្ញុំបាទ តាអឿន និង តាគឹម គឺក្បត់កម្ពុជាប្រជាធិបតេយ្យ។

**ស៖** បើគាត់ក្បត់ អ៊ីចឹងខ្ញុំចង់ដឹងថា តើមានអ្នកណាក្បត់គាត់ទេ? អ្នកណាទៅរាយការណ៍ប្រាប់ខ្មែរក្រហមថា គាត់បម្រុងក្បត់ហ្នឹងទេ?

[១១:១៧:០៨]

**ឆ៖** ខ្ញុំបាទពុំបានដឹងទេ។

**ស៖** ហេតុអ្វីបានជាលោកដឹងថា គេចាប់ខ្លួនគាត់ក្រោយពីប្រជុំហើយនោះ? លោកឃើញផ្ទាល់នឹងភ្នែកនូវការចាប់ខ្លួននេះ ឬក៏គេគ្រាន់តែប្រាប់លោកទេ? ហើយលោកដឹងទេថា អ្នកណាអ្នកដែលមកចាប់ខ្លួន តាគឹម ហើយនិង តាអឿន នេះ?

**ឆ៖** ខ្ញុំបាទពុំបានស្គាល់អ្នកចាប់ខ្លួនទេ ព្រោះនៅពេលនោះគេហៅ តាអឿន និង តាគឹម ទៅភ្នំពេញ។

**ស៖** អ៊ីចឹងម៉េចក៏លោកដឹងថា ក្រោយពីប្រជុំហើយក្រោយមួយថ្ងៃគេចាប់ខ្លួនពួកគាត់?

**ឆ៖** កាលថ្ងៃដែលគាត់ប្រជុំហើយបានមួយថ្ងៃគេចាប់ខ្លួនគាត់។ ដល់ក្រោយមក ថ្ងៃក្រោយមួយ

ទៀត គឺគេហៅយើងខ្ញុំទៅរៀន ហើយនិងស្ដាប់នូវចម្លើយសារភាពនោះឯងបាទ។

**ស៖** ហើយពេលប្រជុំរៀនសូត្រ ដែលគេហៅទៅចាក់ឲ្យស្ដាប់ចម្លើយសារភាពគាត់ហ្នឹង ប្រហែលប៉ុន្មានថ្ងៃក្រោយមកដែរ?

**ឆ៖** បើតាមខ្ញុំបាទនៅចាំបាន គឺក្រោយពេលដែលគេចាប់បាន២ថ្ងៃ។

[១១:១៩:៣៩]

**ស៖** ដូច្នេះ ប្រសិនបើខ្ញុំសង្ខេបឡើងវិញ គឺថាលោកបានចូលរួមនៅក្នុងកិច្ចប្រជុំមួយដែល តាអឿន គាត់ជាអ្នកដឹកនាំ។ កិច្ចប្រជុំនោះមានទាហានពិការនៅក្នុងអង្គភាពរបស់លោក និងមានអ្នក -- និងមានទាហានផ្សេងទៀតមកពីកងពលទាំងមូល។ កិច្ចប្រជុំហ្នឹងគឺធ្វើឡើងនៅភ្នំពេញនៅជិតវត្តភ្នំ។ ក្នុងពេលប្រជុំ តាអឿន បានប្រាប់អ្នកចូលរួមថា ទាហានត្រូវតែមានជីវភាពល្អប្រសើរ ត្រូវទទួលបានប្រាក់ខែ អាចសួរសុខទុក្ខគ្រួសារបាន ហើយគាត់ប្រកាសថា ត្រូវតែផ្ដួលរំលំរបបខ្មែរក្រហម។ គាត់ក៏បានប្រកាសថែមទៀតថា អាវុធនិងកាំភ្លើងផ្សេងៗត្រូវបានដឹកមកដល់ក្រុងភ្នំពេញអស់ហើយ។ ក្រោយពីប្រជុំចប់ គេចាប់ខ្លួន តាអឿន និងតាគឹម គឺក្រោយពីប្រជុំចប់មួយថ្ងៃ។ ហើយពីរថ្ងៃក្រោយពេលគេចាប់ខ្លួន តាអឿន និងតាគឹម មានកិច្ចប្រជុំអប់រំមួយ។ ក្នុងពេលប្រជុំនោះ គេបានចាក់ផ្សាយចម្លើយសារភាពរបស់ តាអឿន និងតាគឹម។ ខ្ញុំសង្ខេបអ៊ីចឹង តើត្រឹមត្រូវទៅនឹងចម្លើយរបស់លោកទេ?

**ឆ៖** បាទ ត្រឹមត្រូវ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

សូមអរគុណលោកសាក្សី។ លោកប្រធាន ខ្ញុំអស់សំណួរហើយ។

[១១:២១:៤៧]

**ប្រធានអង្គជំនុំ៖**

បាទឥឡូវនេះ ដល់ពេលសមស្របសម្រាកដែរហើយ អង្គជំនុំជម្រះប្រកាសសម្រាកថ្ងៃត្រង់ចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងមួយកន្លះ សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្ដល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី និង -- ដល់សាក្សីរូបនេះ នៅបន្ទប់សម្រាកសម្រាប់សាក្សី និងអ្នកជំនាញនៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្ដល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះ នៅវេលាម៉ោងមួយកន្លះរសៀលនេះ។

ហើយអង្គជំនុំជម្រះសូមជម្រាបជូនភាគី និងសាធារណជនជ្រាបផងដែរថា នៅរសៀលនេះ អង្គជំនុំជម្រះនឹងដំណើរការនីតិវិធីសម្បថសម្រាប់អ្នកស៊ើបអង្កេតថ្មីមួយរូបនៃការិយាល័យសហចៅក្រមស៊ើបអង្កេត ដែលទើបបានជ្រើសរើស និងផ្តល់សម្បទាដោយប្រកាសរបស់ក្រសួងយុត្តិធម៌ ហើយនីតិវិធីសម្បថនឹងប្រព្រឹត្តទៅនៅរសៀលនេះ ចាប់ផ្តើមពីម៉ោងមួយរសៀលនៅបន្ទប់សវនាការនេះ។ ហើយភាគីដែលអង្គជំនុំជម្រះអញ្ជើញចូលរួម គឺសហព្រះរាជអាជ្ញា ឬតំណាងសហព្រះរាជអាជ្ញា ហើយនិងក្រឡាបញ្ជីអញ្ជើញអ្នកស៊ើបអង្កេតថ្មី ដែលនឹងត្រូវធ្វើសម្បថឲ្យមានវត្តមាននៅក្នុងបន្ទប់សវនាការនេះឲ្យបានមុនម៉ោងមួយ។

ហើយដោយឡែកភាគីដទៃទៀត ប្រសិនបើមានបំណងចូលរួមជាភ្ញៀវក៏អាចចូលរួមនៅវេលាម៉ោងមួយរសៀលនេះ តែបើមិនមានបំណងចូលរួមទេ គឺសូមពន្យារពេលក្នុងការចូលមកកាន់ទីកន្លែងរៀងៗខ្លួននៅក្នុងបន្ទប់សវនាការនេះ នៅក្រោយអង្គជំនុំជម្រះធ្វើនីតិវិធីសម្បថចប់ ដែលទំនងជាអាចប្រព្រឹត្តរហូតត្រឹមម៉ោងមួយ និងម្ភៃនាទី។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ទៅកាន់បន្ទប់រង់ចាំខាងក្រោមសាលសវនាការនេះ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់ចូលរួមសវនាការនៅក្នុងបន្ទប់សវនាការនេះវិញនៅរសៀលនេះ ឲ្យបានមុនម៉ោងមួយកន្លះរសៀល និងបន្ទាប់ពីអង្គជំនុំជម្រះបានធ្វើនីតិវិធីសម្បថចំពោះអ្នកស៊ើបអង្កេតចប់សព្វគ្រប់។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១១:២៤ នាទី ដល់ម៉ោង ១៣:៣៣ នាទី)*

[១៣:៣៣:០៤]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយជាបន្តទៅនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមសហមេធាវីការពារក្តីជនជាប់ចោទ ដែលដំបូងនេះផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក នួន ជា ដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះសាក្សីនេះ។ សូមអញ្ជើញ!

**លោក វ៉ិចទ័រ កូប៉េះ**

សូមអរគុណលោកប្រធាន។

**ការតាំងសំណួរដោយសហមេធាវីការពារក្ដី**

**សួរដោយលោក វ៉ិចទ័រ កូប៉េះ**

**ស៖** ជម្រាបសួរលោកសាក្សី។ ខ្ញុំមានសំណួរមួយចំនួនតូចសួរទាក់ទងទៅនឹងអាជីពរបស់លោកជាកងទ័ព។ ខ្ញុំដឹងថា លោកបានចូលក្នុងជួរកងទ័ពវាយប្រយុទ្ធជាមួយនឹងកងទ័ព លន់ នល់ នៅក្នុងឆ្នាំ១៩៧០។ នៅពេលនោះ គឺលោកនិយាយថា ត្រូវបានអំពាវនាវដោយសម្ដេច នរោត្តម សីហនុ។ តើលោកមានបានទទួលការអំពាវនាវពីសម្ដេច នរោត្តម សីហនុ ដើម្បីឱ្យទៅវ៉ៃជាមួយទាហាន លន់ នល់ ទេ?

[១៣:៣៤:៣៤]

**លោក កែវ លឿ៖**

**ឆ៖** នៅក្នុងឆ្នាំ១៩៧០ គឺមានសេចក្ដីអំពាវនាវអំពីសម្ដេចតា ឱ្យកូនចៅចូលព្រៃម៉ាគី ដើម្បីតស៊ូវាយកម្ចាត់របបចក្រពត្តិអាមេរិក។

**ស៖** តើការអំពាវនាវនេះ គឺជាមូលហេតុដែលនាំឱ្យលោកចូលរួមនៅក្នុងកងកម្លាំងប្រដាប់អាវុធ ឬក៏អត់ទេ គឺការអំពាវនាវដោយអតីតព្រះមហាក្សត្រ សម្ដេចនរោត្តម សីហនុ?

**ឆ៖** ការអំពាវនាវដោយសម្ដេចព្រះនរោត្តម សីហនុ នេះខ្ញុំបាទពុំមានចង់ចូលជួរក្នុងកងទ័ពទេ។

**ស៖** បន្ទាប់មក តើលោកមានបានទទួលការបណ្ដុះបណ្ដាលអាជីពឱ្យទៅជាកងទ័ពរយៈពេល ២ខែ ដើម្បីវាយប្រយុទ្ធដែរឬទេ?

**ឆ៖** ក្រោយពេលដែលខ្ញុំបាទចូលជួរទ័ព ខ្ញុំបាទបានហ្វឹកហាត់រៀនយុទ្ធសាស្ត្រក្នុងវិធីវ៉ៃខ្លាំងពិតមែន។

[១៣:៣៦:១៩]

**ស៖** ហើយនៅពេលនោះ លោកនៅជំរំទី១១, ១២ នៅជិតសមរភូមិមុខមែនឬទេ?

**ឆ៖** បាទ។

**ស៖** តើលោកនៅចាំថា តើការវាយបក ឬការវាយប្រយុទ្ធជាមួយកងទ័ព លន់ នល់ លោកចូលរួមប្រយុទ្ធបានប៉ុន្មានដងដែរ?

**ឆ៖** កាលនៅប្រយុទ្ធជាមួយរបប លន់ នល់ ខ្ញុំបាទពុំបានចាំថាប៉ុន្មានដងទេ ព្រោះវាច្រើនដែរ។

**ស៖** តើលោកអាចផ្តល់តួលេខត្រួសៗ ថាលោកបានចូលប្រយុទ្ធយ៉ាងសកម្មជាមួយទាហាន លន់ នល់ ហ្នឹងបានប៉ុន្មានដង ម្តង ពីរដង ១០ដង?

**ឆ៖** ក្នុងការចូលទៅប្រយុទ្ធជាមួយទាហាន លន់ នល់ ខ្ញុំបាទពុំបានចាំច្បាស់ទេ។

**ស៖** តើលោកនៅចាំ នៅឆ្នាំ១៩៧៣ នៅពេលអតីតព្រះមហាក្សត្រ នរោត្តម សីហនុ បានយាងមកត្រួតពិនិត្យកងទ័ពនៅភាគខាងជើងនៃប្រទេសកម្ពុជា ដែលលោកនៅទីនោះដែរ តើលោកនៅចាំដំណើរទស្សនកិច្ចរបស់ព្រះអង្គទេ?

**ឆ៖** ខ្ញុំបាទនៅចាំបាន។

[១៣:៣៨:៥៣]

**ស៖** ហើយថាត្រឹមត្រូវទេ ដែលថាព្រះអង្គនោះបានជំរុញទឹកចិត្តលោក ក៏ដូចជាសមមិត្តរបស់លោក ឲ្យធ្វើការងារឲ្យបានខ្លាំងក្លាដើម្បីប្រឆាំងជាមួយនឹងចក្រពត្តិអាមេរិក ហើយនិងរបប លន់ នល់?

**ឆ៖** ខ្ញុំបាទនៅចាំបានថា ព្រះអង្គមានព្រះបន្ទូលថា សុំឲ្យកូនចៅទាំងអស់ខិតខំតស៊ូដើម្បីរំដោះជាតិមាតុភូមិ ដើម្បីឲ្យបានសុខសាន្តទៅអនាគត។

**ស៖** ក្រៅពីនេះ តើលោកមាននៅចាំអ្វីទៀត ចេញពីដំណើរទស្សនកិច្ចរបស់ព្រះអង្គនេះ?

**ឆ៖** ក្រៅពីនេះ ខ្ញុំបាទពុំបានដឹងទេ។

**ស៖** តើលោកមាននៅចាំថា តាមរយៈអំពាវនាវ តាមរយៈការជំរុញទឹកចិត្តហ្នឹង លោកត្រូវបានគេតាមដានអីដែរ ឬក៏អត់ទេ?

**ឆ៖** ក្រោយពេលនោះមក នៅក្នុងជួរទ័ពមិនមាននរណាតាមដាននរណាទេ គឺមកពីកន្លែងវិញក៏ចូលបម្រើការធម្មតានៅសមរភូមិ។

**ស៖** សំណួរខ្ញុំសួរថា លោកចាំទេ តើលោកចាំថាតើតាមរយៈការជំរុញទឹកចិត្តនេះ លោកធ្វើតាម លោកដើរតាមព្រះអង្គដែរឬក៏អត់? ធ្វើការប្រឹងប្រែងធ្វើការដើម្បីវាយប្រយុទ្ធនេះឬក៏អត់?

[១៣:៤១:១៧]

**ឆ៖** ក្រោយពេលដែលមកពីទទួលវិញ ការប្រឹងប្រែងគឺជាធម្មតារបស់ទ័ព ព្រោះចាត់តាំងទៅពេលណាក៏ទៅ មិនចាត់តាំងក៏សម្រាកនៅក្រោយទៅ។

**ស៖** តើលោកអាចជម្រាបជូនអង្គជំនុំជម្រះ អំពីការដំឡើងបុណ្យសក្តិរបស់លោកនៅក្នុងជួរ

កងទ័ព គិតរហូតមកដល់ឆ្នាំ១៩៧៤ ដោយសារលោកចាប់ផ្តើមនោះ គឺលោកជាយុទ្ធជនសុទ្ធសាធ ហើយក្រោយមកលោកក៏បានដំឡើងឋានន្តរសក្តិ គិតមកដល់ឆ្នាំ៧៤? តើលោកចាំទេ? សូមរៀបរាប់បន្តិច។

**ឆ៖** ខ្ញុំបាទសូមជម្រាបជូនអង្គតុលាការឲ្យបានជ្រាប។ ក្រោយពេលដែលមកពីសៀមរាបវិញ នៅពេលនោះខ្ញុំបាទទទួលជាអនុប្រធានក្រុម តែថ្ងៃខែខ្ញុំបាទអត់បានចំណាំទេ។ ធ្វើការបម្រើទ័ពរហូតដល់ដើមឆ្នាំ៧៤ ខ្ញុំបាទបានទទួលជាអនុកងតូច។ ហើយរហូតដល់ចុងឆ្នាំ៧៤ ខ្ញុំបាទបានទទួលជាអនុប្រធានកងវរសេនាតូច។ សូមអង្គតុលាការមេត្តាជ្រាប។

**ស៖** ខ្ញុំអានចម្លើយរបស់លោកដែលឆ្លើយជាមួយ ឌី.ស៊ី.ខេម។ នៅថ្ងៃទី១៥ ឆ្នាំ១៩៧៤ លោកក្លាយទៅជាអនុប្រធានកងវរសេនាតូច។ តើនៅក្នុងកងវរសេនាតូចរបស់លោកនេះ មានកងទ័ពប៉ុន្មាននាក់? ២០០នាក់ ឬក៏ច្រើនជាងនេះ?

**ឆ៖** នៅក្នុងកងវរសេនាតូចគឺមាន៥០០នាក់។

[១៣:៤៣:៥១]

**ស៖** ដូច្នេះតើលោកអាចជម្រាបជូនអង្គជំនុំជម្រះនេះ ចន្លោះពីឆ្នាំ១៩៧០ ដល់ថ្ងៃទី១៥ ធ្នូ ៧៤ នៅពេលដែលលោកក្លាយទៅជាអនុកងវរសេនាតូចនេះ។ ថាខ្ញុំសួរបែបនេះ គឺដោយសារថាយុទ្ធជនទាំងអស់ គឺមិនបានឡើងបុណ្យសក្តិដូចលោកលឿនយ៉ាងដូច្នេះទេ។ អ៊ីចឹងឯងបានជាសួរថា តើការដំឡើងបុណ្យសក្តិរបស់លោកនេះ គិតចាប់ពីពេលណា? ហើយមូលហេតុអី?

**ឆ៖** ខ្ញុំបាទសូមជម្រាបអង្គតុលាការ សូមមេត្តាជ្រាប។ នៅពេលដែលខ្ញុំបាទឡើងបុណ្យរហ័ស គឺដោយសារខ្ញុំបាទជួបការលំបាកក្នុងការត្រៀម ទាហានព័ទ្ធច្រើនដង តែដោះខ្លួនរួច។ ហើយរហូតដល់មេៗទុកចិត្ត ក៏ដំឡើងឋានៈឲ្យជាអនុប្រធានកងវរសេនាតូច។ បាទ នេះសូមអង្គតុលាការមេត្តាជ្រាប។

**ស៖** ប្រហែលជាដោយសារបញ្ហាបកប្រែ។ តើវាមានលក្ខណៈខុសគ្នាដែរឬទេ រវាងកងអនុសេនាតូច និងកង -- បាទៗគឺកងអនុសេនាតូច និងកងវរសេនាតូចវាខុសគ្នាយ៉ាងម៉េច? នៅខែធ្នូ ឆ្នាំ៧៤ តើលោកក្លាយទៅជាអនុបញ្ជាការកងអនុសេនាតូច ឬក៏អនុបញ្ជាការកងវរសេនាតូច?

**ឆ៖** ខ្ញុំបាទស្តាប់អត់ទាន់បាន សូមមេត្តាបញ្ជាក់ម្តងទៀត។

**ស៖** លោកបានឆ្លើយទៅប្រាប់អ្នកស៊ើបអង្កេតមជ្ឈមណ្ឌលឯកសារកម្ពុជាថា លោកឡើងជាអនុកងអនុសេនា -- វរសេនាតូចនៅថ្ងៃទី១៥ ខែធ្នូ ៧៤ ហើយម្តងទៀតនោះ គឺលោកថាជាគឺជាអនុ

បញ្ជាការកងអនុសេនាតូច។ វាខុសគ្នាឆ្ងាយ។ អ៊ីចឹងហើយបានជាខ្ញុំសួរ ទាក់ទងទៅនឹងឋានន្តរសក្តិដែលលោកឡើងនៅថ្ងៃទី០៥ ខែធ្នូ ៧៤ លោកឡើងជាអនុបញ្ជាការកងអនុសេនាតូច ឬក៏អនុបញ្ជាការកងវរសេនាតូច?

[១៣:៤៦:៥២]

**ឆ៖** នៅថ្ងៃនោះខ្ញុំបាទឡើងជាអនុសេនាតូច។

**ស៖** ដូច្នេះបើខ្ញុំយល់មិនច្រឡំទេ គឺថាការដំឡើងឋានន្តរសក្តិបន្តបន្ទាប់មកទៀត លោកក៏ក្លាយទៅជាប្រធានកងអនុសេនាធំវិញម្តង គឺនៅក្នុងឆ្នាំ១៩៧៥។ តើអ៊ីចឹងមែនឬក៏អត់ទេ?

**ឆ៖** នៅពេលដែលខ្ញុំបាទនៅក្នុងអង្គភាព ក-៤ ខ្ញុំបាទបានទទួលឋានៈជាកងអនុសេនាធំ។

**ស៖** លោកសាក្សីលោកប្រាប់មជ្ឈមណ្ឌលឯកសារកម្ពុជាថា លោកក្លាយទៅជាមេបញ្ជាការកងអនុសេនាធំ ឬក៏កងវរសេនាធំ។ បាទ អាចជាអនុបញ្ជាការកងអនុសេនាធំ និងក៏ជាអនុបញ្ជាការកងវរសេនាធំផងដែរ។ សូមលោកបញ្ជាក់ចំណុចនេះ។

**ឆ៖** ខ្ញុំបាទសូមបញ្ជាក់ជូនអង្គតុលាការមេត្តាជ្រាប។ នៅក្នុងអង្គភាព ក-៤ គ្មានវរសេនាធំទេ គឺខ្ញុំបាទបានទទួលជាអនុសេនាធំ។

**ស៖** លោកបានឆ្លើយថាពេលនៅសម្រាកនៅមន្ទីរពេទ្យដល់ឆ្នាំ១៩៧៥ គឺថាតួនាទីរបស់លោកហ្នឹងគឺជា គឺឯកសារ E3/5685 ERN 00812785។ គឺថានៅក្នុងចម្លើយហ្នឹង នៅក្នុងឆ្នាំ៧៥ លោកក្លាយទៅជាប្រធានកងវរសេនាតូច/កងវរសេនាធំ។ លោកអាចជាមេបញ្ជាការកងវរសេនាតូចផង អាចជាមេបញ្ជាការកងវរសេនាធំផង។ សូមបញ្ជាក់ចំណុចនេះ។

**ឆ៖** ខ្ញុំបាទសូមបញ្ជាក់អំពីតួនាទី។ នៅក្នុងអង្គភាព ក-៤ មិនមែនជាវរសេនាធំទេ។ នៅនោះខ្ញុំបាទបានទទួលជាអនុសេនាធំ ក្រោមបញ្ជារបស់កងវរសេនាតូច។

[១៣:៥០:២៦]

**ស៖** ខ្ញុំមិនដឹងថា ក្នុងឆ្នាំ៧៥ហ្នឹង ក-៤ ហ្នឹងបង្កើតហើយឬនៅទេ។ តើលោក -- លោកបានឆ្លើយថា លោកគឺជាមេបញ្ជាការកងវរសេនាធំឆ្នាំ៧៥ ហើយឥឡូវវិញ តើលោកឆ្លើយថាម៉េច?

**ឆ៖** ខ្ញុំបាទសូមជម្រាបជូនមេធាវី សូមមេត្តាផ្ទៀងផ្ទាត់នៅក្នុងអង្គភាព ក-៤ នេះគ្មានវរសេនាធំ។ ហើយខ្ញុំបាទបានទទួលជាអនុសេនាធំនេះ គឺក្រោមបញ្ជាកងវរសេនាតូច។ នេះសូមលោកបញ្ជាក់ ក្រែងឯកសារនេះ អ្នកសរសេរមុនអាចនឹងភ័ន្តច្រឡំ។

**ស៖** ខ្ញុំនឹងត្រឡប់មកនិយាយអំពីអង្គភាព ក-៤ នៅបន្តិចទៀតនេះ។ ហើយលោកក៏បានឆ្លើយជូនអ្នកស៊ើបអង្កេតរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាថា នៅពាក់កណ្ដាលឆ្នាំ១៩៧៧ លោកក្លាយទៅជាអនុបញ្ជាការកងវរសេនាធំ។ ត្រឹមត្រូវដែរទេ?

**ឆ៖** មិនត្រឹមត្រូវទេ។

**ស៖** លោកដឹងទេថា កងវរសេនាធំមួយណាដែលស្ថិតនៅចំណុះឲ្យកងពលតូច៣១០?

[១៣:៥២:៣៦]

**ឆ៖** នៅចំណុះកងពល៣១០ ខ្ញុំបាទបានដឹងតែវរសេនាតូចលេខ៧២៩ និងវរសេនាធំលេខ២៩ តែប៉ុណ្ណោះ។ ត្រង់វរសេនាធំដទៃ ខ្ញុំបាទអត់បានដឹងលេខរបស់គេទេ។

**ស៖** តើលេខ១១, ១២, ១៣ គឺកងវរសេនាធំលេខ១១, ១២, ១៣ ចំណុះឲ្យកងពលតូច៣១០ដែរទេ?

**ឆ៖** ខ្ញុំបាទមិនបានដឹងទេ។

**ស៖** លោកប្រធាន ខ្ញុំយោងឯកសារ E3/1180 ERN ភាសាអង់គ្លេស 00655683, បារាំង 00593507, ខ្មែរ 00033133។ លោកសាក្សីខ្ញុំយោងទៅលើស្ថិតិកងទ័ពនៅក្នុងកងពល៣១០ ចុះថ្ងៃទី១៣ ខែមិថុនា ១៩៧៧។ វរៈ -- កងពលតូច៣១០ហ្នឹង គឺមានកងទ័ពទាំងអស់៤៤៩ ហើយកងវរសេនាធំ គឺមានជាង៦០០នាក់។ ក-៤ ក៏ជាអង្គភាពមួយដែរ គឺមាន២៨០ -- យុទ្ធជន២៨៨នាក់ និងក្មេងប្រុសម្នាក់។ ឧទាហរណ៍ថា លោកបានឆ្លើយថា -- លោកជូនមជ្ឈមណ្ឌលឯកសារថា លោកជាអនុកងវរសេនាធំ។ តើលោកជាអនុបញ្ជាការកងវរសេនាធំ ១១, ១២, ឬក៏១៣?

[១៣:៥៥:២១]

**ឆ៖** ខ្ញុំបាទសូមបញ្ជាក់ជូនអង្គតុលាការ។ ក្រែងអ្នកសរសេរឯកសារខុសពីចម្លើយរបស់ខ្ញុំក៏មិនដឹង ប៉ុន្តែខ្ញុំនៅក្នុងអង្គភាព ក-៤។ ក-៤ នេះគឺស្ថិតក្រោមការគ្រប់គ្រងរបស់កងពលផ្ទាល់ អត់មានវរសេនាធំទេ ដូចខ្ញុំបាទបានជម្រាបខាងដើមហើយ។

**ស៖** ចម្លើយជូនមជ្ឈមណ្ឌលឯកសារកម្ពុជា លោកថា លោកត្រូវបានដំឡើងឋានន្តរសក្តិទៅជាអនុបញ្ជាការកងវរសេនាធំដើម្បីគ្រប់គ្រង។ ERN ជាភាសាអង់គ្លេស 0086388 -- 00863288។ តើត្រឹមត្រូវទេដែលថាក្នុងឆ្នាំ៧៧ លោកក្លាយទៅជាអនុប្រធានកងពល -- អនុប្រធានកងពលតូច និងក៏ជាប្រធាន ក-៤ ផងដែរ ត្រឹមត្រូវដែរឬក៏អត់ទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប។ សូមអញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ!

**លោក វីណ្ឌៀម ស្មីត៖**

មិនមែនជាការជំទាស់ទេ។ ខ្ញុំយល់ឃើញថាគាត់បានឆ្លើយថា ជាអនុបញ្ជាការកងវរសេនាធំ មិនមែនជាអនុបញ្ជាការកងពលទេ។ គាត់មិនដែលបានឆ្លើយថា គាត់បានឡើងបុណ្យស័ក្តិទៅដល់ជាអនុបញ្ជាការកងពលតូច ឬក៏អនុបញ្ជាការកងពលធំអីទេ។

[១៣:៥៧:១០]

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំសូមទោស លោកសហព្រះរាជអាជ្ញារងអន្តរជាតិ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** តើលោកពិតជាបានក្លាយទៅអនុប្រធានកងវរសេនាធំ ហើយក្នុងពេលជាមួយគ្នា ក៏ជាប្រធានអង្គភាព ក-៤ ដែរនៅពាក់កណ្តាលឆ្នាំ១៩៧៧ អ៊ីចឹងទេ ដែលលោកមានតំណែងទាំងពីរនេះ?

**លោក កែវ លឿ៖**

**ឆ៖** ខ្ញុំបាទសូមជម្រាបជូនអង្គតុលាការ។ នៅពាក់កណ្តាលឆ្នាំ១៩៧៧ ខ្ញុំបាទមិនដែលបានទទួលឋានៈ នាទីជាវរសេនាធំទេ ដូចខ្ញុំបាទបានជម្រាបខាងដើមហើយ ថាអង្គភាពនៅ ក-៤ គឺមានតែត្រឹមឋានៈវរសេនាតូច ហើយខ្ញុំបាទទទួលជាអនុសេនាធំ មិនមែនដូចមេធាវីចុងចោទបានចោទសួរខ្ញុំបាទនោះទេ។ សូមអង្គតុលាការមេត្តាជ្រាប។

**ស៖** ឥឡូវខ្ញុំរៀបសំណួរតាមរបៀបផ្សេងវិញ។ នៅពាក់កណ្តាលខែមិថុនា ឬក៏ពាក់កណ្តាលឆ្នាំ១៩៧៧ តើលោកជាមេបញ្ជាការដែលត្រួតទ័ពពីរ – ប្រហែលជា២៨៨នាក់នៅ ក-៤ អ៊ីចឹង ឬក៏មិនមែនទេ?

**ឆ៖** ខ្ញុំបាទនៅចាំបានថា នៅក្នុងពាក់កណ្តាលឆ្នាំ១៩៧៧ ខ្ញុំបាទមានឋានៈជាស្នងការអនុសេនាធំ មិនមែនវរសេនាធំ ដូចលោកចោទសួរនោះទេបាទ។

[១៣:៥៩:២១]

**ស៖** គឺខ្ញុំសួរថាលោកគឺជាមេបញ្ជាការបញ្ជាទ័ព២៨៨នាក់នៅក-៤ នៅពាក់កណ្តាលឆ្នាំ១៩៧៧ តើអ៊ីចឹងឬក៏អត់ទេ?

**ឆ៖** នៅពាក់កណ្ដាលឆ្នាំ១៩៧៧ លោកចោទសួរនេះ មិនពិតប្រាកដ។

**ស៖** អានចម្លើយរបស់លោកឆ្លើយជូនមជ្ឈមណ្ឌលឯកសារកម្ពុជា ខ្ញុំមិនមែនចោទសួរទេ អ៊ីចឹងហើយបានជាខ្ញុំព្យាយាមស្វែងយល់ ថាតើនៅក្នុងជួរកងទ័ពនេះលោកមានឋានៈប៉ុន្មាន? ដូចដែលលោកឆ្លើយនេះ លោកថាជាកងទ័ពពិការ ឬក៏លោកគឺជាមេបញ្ជាការម្នាក់មានឋានន្តរសក្តិខ្ពង់ខ្ពស់នៅក្នុងកងពល៣១០។ លោកអាចមានតួនាទីទាំងពីរក៏ថាបាន អ៊ីចឹងបានខ្ញុំសួរ ថាតើលោកគឺជាមេបញ្ជាការម្នាក់ក្នុងចំណោមមេបញ្ជាការដែលក្ដោបក្ដាប់កងពល៣១០ ឬក៏អត់ទេ?

**ឆ៖** ខ្ញុំបាទសូមឆ្លើយជូនអង្គតុលាការ។ នៅក្នុងអង្គភាពក-៤ ខ្ញុំបាទក៏មានឋានៈជាមេបញ្ជាការមួយរូបនៅក្នុងអង្គភាពនេះ។

[១៤:០១:១១]

**ស៖** តើត្រឹមត្រូវទេ លោកក៏ជាមេបញ្ជាការដែលគ្រប់គ្រងយុទ្ធជន២៨៨នាក់ និងទាហានក្មេងប្រុសម្នាក់។ តើអ៊ីចឹងឬក៏អត់ទេ?

**ឆ៖** បាទ ពិតមែន។

**ស៖** សូមអរគុណលោកសាក្សី។ តើពេលបញ្ហាហ្នឹង លោកទទួលបានជោគជ័យទេនៅកងវរសេនា -- នៅកងអនុសេនាធំ? តើសមមិត្តធី គឺជាអតីតមេបញ្ជាការអង្គភាពក-៤ មុនឈ្មោះ ទី មុនលោក តើអ៊ីចឹង -- តី ឈ្មោះ តី អ៊ីចឹងក៏អត់ទេ?

**ឆ៖** ខ្ញុំបាទសូមជម្រាបជូនអង្គតុលាការ។ មេបញ្ជាការមុនមិនមែនឈ្មោះ ទី ទេគឺឈ្មោះ ទី។

**ស៖** ខ្ញុំអានខ្មែរវាមិនសូវបានច្បាស់ ប៉ុន្តែខ្ញុំយោងទៅលើឯកសារ E3/1585 ERN ជាភាសាអង់គ្លេស 00897652, ខ្មែរ 0095534 (*ស៊ីក*), បារាំង 00611639។ គឺឯកសារដែលខ្ញុំមាននៅចំពោះមុខខ្ញុំនេះ លោកសាក្សី។ ជាបញ្ជីអ្នកចូលរួមនៅក្នុងការបណ្ដុះបណ្ដាលរបស់អគ្គសេនាធិការលើកទី១នៃកងទ័ពបដិវត្តន៍ប្រជាជនកម្ពុជានៅថ្ងៃទី២០ តុលា ១៩៧៦។ សមាជិកនៃកងពល និងវរសេនាធំទាំងអស់មានវត្តមាននៅក្នុងកិច្ចប្រជុំរៀនសូត្រនេះ ហើយនិងកងពល៣១០ នៅក្នុងនោះគឺមានសមមិត្តអឿន និងសមមិត្តលេខា អនុលេខាកងវរសេនាធំឈ្មោះ ទី និងឈ្មោះ គីន ក៏មានវត្តមាន។ ដូច្នេះសំណួររបស់ខ្ញុំ សមមិត្ត ទី ឬក៏សមមិត្ត ទី នេះគឺអ្នកដែលទទួល -- អ្នកដែលមានតំណែងនៅក-៤មុនលោកឈ្មោះ ទី ហ្នឹងតើអ៊ីចឹងមែនទេ?

[១៤:០៤:០៨]

**ឆ៖** ខ្ញុំបាទសូមជម្រាបជូនអង្គតុលាការសូមមេត្តាជ្រាប។ មិនមែនឈ្មោះ តឺ ទេគឺឈ្មោះ ទឹ។ ទ-ឹ បាទ។

**ស៖** តើមេបញ្ជាការនៅ ក-៤ ហ្នឹងគឺជាមនុស្សម្នាក់ឈ្មោះ ទឹ ហ្នឹង ឬក៏មិនមែនទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

អញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ!

**លោក វីណ្សៀម ស្មីត៖**

សូមអរគុណលោកប្រធាន។ មិនមែនជាការជំទាស់ទេ ក្នុងស្ថានភាពនេះគឺជួនកាលអានឈ្មោះវាពិបាកស្តាប់បន្តិច គួរណាស់តែផ្តល់ឯកសារនេះមួយច្បាប់ទៅឲ្យសាក្សី ដើម្បីផ្ទៀងផ្ទាត់ចំពោះអំណានឈ្មោះមនុស្សនេះ។

[១៤:០៥:១៨]

**លោក វ៉ិចទ័រ កូប៉េះ៖**

ខ្ញុំមិនមានការជំទាស់អីទេ ជាគំនិតយោបល់ល្អហើយ។

**សួរដោយលោក វ៉ិចទ័រ កូប៉េះ៖**

**ស៖** ការបង្ហាញឯកសារនេះ រួមជាមួយនឹងឯកសារដទៃទៀតផងដែរ។ ឯកសារ E3/2592 ERN ជាភាសាអង់គ្លេស 00887709, បារាំង 009232056 (*ស៊ីក*), ខ្មែរ 0023080 (*ស៊ីក*)។ នេះគឺជាបញ្ជីឈ្មោះកងទ័ពមកពីកងពល៣១០ លេខរៀងទី១៣ គឺជាប្រធានមន្ទីរក-៤ ឈ្មោះដាក់ឈ្មោះមកថាឈ្មោះ តឺ -- ឈ្មោះ ទឹ។ អាចបង្ហាញជូនសាក្សីនូវឈ្មោះនេះ ដើម្បីបញ្ជាក់ថា តើឈ្មោះ ទឹ ឬក៏ឈ្មោះ ទឺ ឬក៏មួយណាដែលជាអតីតប្រធាន ក -- មេបញ្ជាការអង្គភាព ក-៤ មុនលោករូបនេះ?

**លោក វីណ្សៀម ស្មីត៖**

ខ្ញុំមានឯកសារនេះដល់តែពីរច្បាប់។ ខ្ញុំអាចផ្តល់មួយច្បាប់ជូនសាក្សីបាន លោកប្រធាន អាចផ្តល់ជំនួសមេធាវីការពារក្តី។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត!

[១៤:០៦:៥៥]

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី ឯកសារ E3/1585 គឺលេខរៀងទី៤៥។ ឯកសារ 2592 នេះគឺមើលទៅលេខរៀងទី១៣ បាទ។ ឯកសារ E3/1585 គឺមើលលេខរៀង៤៥។ ឯ E3/2592 មើលត្រង់លេខរៀងទី១៣។ លោកសាក្សី លោកឃើញលេខរៀងហ្នឹងទេ ឈ្មោះ ទី ហ្នឹងដែលលោកថាមិនមែន តឺ ទេគឺឈ្មោះ ទី ហ្នឹង តើលោកឃើញឈ្មោះហ្នឹងនៅ?

**លោក កែវ លឿ៖**

**ឆ៖** ខ្ញុំបាទមើលអក្សរមិនឃើញទេ អក្សរនេះតូចៗពេកបាទ។

**លោក វីណ្ស៊ៀម ស្មីត៖**

យើងអាចដាក់ឯកសារពង្រីកឱ្យធំបន្តិចនៅលើអេក្រង់កុំព្យូទ័រ។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណ។ ជាការប្រសើរណាស់ បើសិនណាជាអាចធ្វើយ៉ាងដូច្នេះបាន។

[១៤:០៩:២២]

**លោក វីណ្ស៊ៀម ស្មីត៖**

ខ្ញុំជឿជាក់ថាយើងអាចធ្វើបាន ប៉ុន្តែមន្ត្រីខាងសំណុំរឿងយើងខ្ញុំមិននៅទីនេះទេ។ អ៊ីចឹងយើងអាចបង្ហាញនៅពេលក្រោយបាន។ ឥឡូវនេះគឺថាមន្ត្រីគ្រប់គ្រងសំណុំរឿង គាត់អត់នៅទីនេះ។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកសហព្រះរាជអាជ្ញា។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** សំណួររបស់ខ្ញុំលោកសាក្សី គឺដូចតទៅនេះ មេញ្ញាការ ទី ត្រូវបានដកខ្លួន និងចាប់ខ្លួនយោងទៅលើឯកសារ E3/2592 នេះគឺត្រូវចាប់ខ្លួននៅខែមីនា បាទនៅថ្ងៃទី០៤ ខែមីនា ១៩៧៧ លែងនៅជាមេបញ្ជាការ ក-៤ ទៀតហើយ។ ហើយក្រោយមកលោកក៏បានឡើងជំនួសគាត់ ក្លាយទៅប្រធាន ក-៤។ តើលោកក្លាយទៅប្រធាន ក-៤ នេះភ្លាមៗក្រោយការចាប់ខ្លួនឈ្មោះ ទី នេះឬក៏រយៈពេលប៉ុន្មានខែក្រោយមក ឬក៏រយៈពេលមួយរយៈណាក្រោយមក?

**លោក កែវ លឿ៖**

**ឆ៖** ក្រោយពេលដែលចាប់ តាទី បានប្រហែលជាមួយអាទិត្យ គឺគេចាត់តាំងឱ្យខ្ញុំជាប្រធាន

ក-៤។ តែខ្ញុំបាទមិនបានចាំថ្ងៃខែទេ។

**ស៖** បាទ ខ្ញុំយល់ហើយ។ ហើយទាក់ទងទៅនឹងសំណួរខ្ញុំខាងដើម ក្រោយពីលោកក្លាយទៅជាប្រធាន ក-៤ តើនៅពេលណាមួយនោះ លោកមានបានក្លាយទៅជាអនុប្រធានកងវរសេនាធំដែរឬទេ?

**ឆ៖** ខ្ញុំបាទសុំឆ្លើយបំភ្លឺជូនអង្គតុលាការ។ ដូចខ្ញុំបាទបានឆ្លើយខាងដើមហើយថា អង្គភាព ក-៤ គ្មានវរសេនាធំទេ គឺវរសេនាតូចឯករាជ្យស្ថិតក្រោមការគ្រប់គ្រងរបស់កងពល។

**ស៖** ខ្ញុំយល់ហើយ ប៉ុន្តែមានភស្តុតាងខ្លះបញ្ជាក់ថា មេបញ្ជាការកងវរសេនាធំ -- មេបញ្ជាការកងវរសេនាតូចមួយ ពេលខ្លះក៏បំពេញតួនាទីជាមេបញ្ជាការកងវរសេនាធំបានដែរ។ អ៊ីចឹងហើយបានជាខ្ញុំសួរ ថានៅពេលដែលលោកជាមេបញ្ជាការនៅ ក-៤ នេះ តើលោកក៏ត្រូវបានដំឡើងឋានន្តរសក្តិឱ្យទៅជាមេបញ្ជាការកងវរសេនាធំដែរឬទេ -- ជាអនុកងវរសេនាធំដែរទេ?

**ឆ៖** ខ្ញុំបាទជម្រាបជូនលោកមេធាវី នៅក្នុងអង្គភាព ក-៤ ដូចខ្ញុំបាទបានជម្រាបហើយថា គ្មានវរសេនាធំទេ គឺមានតែវរសេនាតូចដែលគ្រប់គ្រងដោយកងពលផ្ទាល់បាទ។

[១៤:១២:៥០]

**ស៖** ឯកសារនេះ គឺបញ្ជីអ្នកទោសមកពីកងពល៣១០, E3/2592។ ERN គឺដដែលដូចខ្ញុំបានផ្តល់រួចមកហើយ។ នៅចន្លោះពាក់កណ្តាលខែកុម្ភៈ ១៩៧៧ ដល់ដើមខែមិថុនា ១៩៧៧ កម្មាភិបាល ៧៧នាក់មកពីកងពល៣១០ ត្រូវបានចាប់ខ្លួន។ លេខរៀងទី១ នៅក្នុងបញ្ជី៧៧នាក់ហ្នឹង គឺជាលេខាមកពីកងវរសេនាធំលេខ១៣ និងមានយុទ្ធជនដែលមកពីកងតូច១៣ផងដែរ។ រយៈពេលបួនប្រាំខែនេះ គឺថាមាន -- លោកដឹងទេ មានមនុស្ស៧៧នាក់ត្រូវបានចាប់ខ្លួនពីកងពល៣១០?

**ឆ៖** សូមបញ្ជាក់សំណួរនេះឡើងវិញបាទ អត់ច្បាស់។

**ស៖** តើត្រឹមត្រូវទេ នៅពាក់កណ្តាលខែកុម្ភៈ ៧៧ ដល់ដើមខែមិថុនា ៧៧ មានយុទ្ធជនប្រមាណ៧៧នាក់ មកពីកងពល៣១០ ត្រូវបានចាប់ខ្លួន តើលោកបានដឹងទេ?

**ឆ៖** ខ្ញុំបាទសូមជម្រាបអង្គតុលាការ។ ខ្ញុំបាទពុំបានដឹងទេ។

**ស៖** គឺនៅពេលដែលមេ ក-៤ ត្រូវបានចាប់ខ្លួន សមាជិកដទៃទៀតនៃអង្គភាព ក-៤ ក៏ត្រូវបានចាប់ខ្លួន គឺបួននាក់មកពី ក-៤ ផ្សេងទៀតក្រៅពីមេបញ្ជាការក៏ចាប់ខ្លួនដែរ។ គឺឯកសារ E3/2592 ត្រង់លេខរៀងទី៩ ឈ្មោះ សាត សឿន ហៅ វឿន។ តើឈ្មោះនេះ លោកនៅនឹកឃើញដែរទេ?

[១៤:១៥:៤៤]

**ផ៖** ខ្ញុំបាទមិនបានចាំទេ។

**ស៖** ចុះលេខរៀងទី១០ ឈ្មោះ គុំ ជឿន ហៅ ហាន តើ -- គុំ ហឿន ហៅ ហាន តើយុទ្ធជនម្នាក់នេះមកពី ក-៤ ដែរទេ?

**ផ៖** បាទ មកពី ក-៤។

**ស៖** គុំ ហឿន ត្រូវបានចាប់ខ្លួននៅថ្ងៃទី១៨ មេសា ៧៧ គឺរយៈពេល៦អាទិត្យក្រោយពីគេចាប់ខ្លួនមេបញ្ជាការរបស់គាត់។ តើការចាប់ខ្លួននេះ វាជាសេចក្ដីសម្រេចចិត្តរបស់លោកឲ្យគេចាប់ខ្លួនអ្នកទាំងនេះ ឬក៏អត់ទេ?

**ផ៖** ខ្ញុំបាទសូមជម្រាបជូនអង្គតុលាការ សូមមេត្តាជ្រាប។ មិនមែនខ្ញុំបាទជាអ្នកសម្រេចឲ្យគេចាប់ទេ គឺមានខាងភូមិភាគនិរតីគេមកចាប់ គេហៅឈ្មោះចាប់របស់គេ បាទ។ គ្រាន់តែឲ្យយើងប្រជុំជួរហើយគេហៅចាប់។

[១៤:១៧:២០]

**ស៖** បាទ មិនជាថ្វីទេ ក៏ប៉ុន្តែអ្នកទាំងនេះត្រូវបានចាប់ខ្លួននៅពេលដែលលោកជាប្រធាន ក-៤។ មិនអ៊ីចឹងអ្ហ៎?

**ផ៖** គេចាប់អ្នកទាំងនេះទៅ ក្នុងនាមខ្ញុំជាថ្នាក់ដឹកនាំ គ្មានសិទ្ធិនិយាយជាមួយគេទេ ព្រោះគេថាភូមិភាគឧត្តរសុទ្ធតែជាអ្នកក្បត់ អស់ឯងកូនចៅអ្នកក្បត់។ ដូច្នេះគេក៏ចាប់ គេចង់ចាប់ពេលណា គឺគេមកឲ្យយើងតម្រង់ជួរ ហើយគេហៅឈ្មោះអ្នកដែលត្រូវចាប់។ នេះសូមអង្គតុលាការមេត្តាជ្រាប។

**ស៖** ចុះលេខរៀងទី១៨ ឈ្មោះ ជួន គឿន ហៅ ហ៊ែន គឺចាប់ខ្លួននៅថ្ងៃទី១៤ ខែមីនា ឆ្នាំ១៩៧៧ ខាងផ្នែកភស្តុភានៅ ក-៤។ ពេលខ្ញុំអានឈ្មោះ ជួន គឿន ហៅ ហ៊ែន នេះ តើលោកនៅចាំឈ្មោះនេះទេ ពេលអានឈ្មោះឲ្យលោកស្តាប់ហើយ?

**ផ៖** ខ្ញុំបាទស្គាល់ឈ្មោះ ហ៊ែន។

**ស៖** តើឈ្មោះ ហ៊ែន ត្រូវបានចាប់ខ្លួនគឺរយៈពេលប្រហែលជាមួយសប្តាហ៍ៗក្រោយពីគេតែងតាំងលោកឲ្យទៅជាមេបញ្ជា ក-៤ នេះ។ តើអ៊ីចឹងឬក៏អត់ទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំទាន់អាលឆ្លើយតប!

អញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ!

[១៤:១៩:២៨]

**លោក វីណ្ឌៀម ស្មីត៖**

ខ្ញុំយល់មិនច្បាស់លោកប្រធាន។ មិនដឹង គឺអ៊ីចេះខ្ញុំឃើញ មេធាវីការពារក្ដីគឺថាផ្ដល់ព័ត៌មាន បញ្ចុកព័ត៌មានទៅឲ្យសាក្សីឆ្លើយ។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំរីករាយនឹងពន្យល់ចំណុចនេះ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** គាត់បានឆ្លើយថាគាត់ក្លាយទៅជាប្រធាន ក-៤ ហ្នឹងគឺក្រោយថ្ងៃទី០៤ -- គឺ១០ថ្ងៃក្រោយពីគាត់ឡើងជាប្រធាន នៅថ្ងៃទី១៤ ខែ៣ ៧៧ គឺ១០ថ្ងៃក្រោយគាត់ឡើងជា – សាក្សីឡើងជាប្រធានអង្គភាព ក-៤។ គឺឈ្មោះ ហ៊ែន នេះត្រូវបានចាប់ខ្លួននៅរយៈពេល១សប្ដាហ៍ ឬ២សប្ដាហ៍ក្រោយលោកក្លាយទៅជាប្រធាន ក-៤។ តើអ៊ីចឹងមែនទេលោកសាក្សី ដែលថាឈ្មោះ ហ៊ែន នេះត្រូវបានចាប់ខ្លួននៅពេលដែលលោកឡើងជាប្រធាន ក-៤ តែក្នុងរយៈពេល១សប្ដាហ៍?

[១៤:២០:៣៥]

**លោក កែវ លឿ៖**

**ឆ៖** ខ្ញុំសូមជម្រាបជូនអង្គតុលាការ។ រឿងខ្ញុំបាទឡើងទទួលតំណែងនេះ គឺក្រោយចាប់ តាហ៊ែន ក្រោយចាប់ តាទី, តាហ៊ែន រួចហើយ មិនមែនឡើងមុន១សប្ដាហ៍ ដូចមេធាវីបានចោទសួរខ្ញុំបាទនោះទេបាទ។ សូមមេត្ដាទានជ្រាប។

**ស៖** តើរយៈពេលប៉ុន្មានគិតពីខែមីនា ៧៧? តើលោកនៅធ្វើជាមេបញ្ជាការ ក-៤ ហ្នឹងបានរយៈពេលប៉ុន្មាន?

**ឆ៖** ខ្ញុំបាទសូមជម្រាបជូនអង្គតុលាការ សូមមេត្ដាទានជ្រាប។ ខ្ញុំបាទបានឡើងទទួលតំណែងបានកន្លះខែ ខ្ញុំបាទត្រូវបានដកខ្លួនឲ្យទៅនៅលត់ដំ នៅឃ្នញ កប់ស្រូវ នៅអង្គភាព៣១៧។

**ស៖** ទោះបីជាលោកបដិសេធថា មិនដែលធ្លាប់ធ្វើជាអនុបញ្ជាការកងវរសេនាធំក៏ដោយ ក៏ប៉ុន្តែនៅក្នុងពាក់កណ្ដាលឆ្នាំ១៩៧៧ តើវាពិតទេ ថាលោកនៅតែធ្វើជាប្រធានអង្គភាព ក-៤ ដដែលរហូតដល់ពាក់កណ្ដាលឆ្នាំ១៩៧៧?

**ឆ៖** ខ្ញុំបាទសូមឆ្លើយជូនអង្គតុលាការ សូមមេត្តាជ្រាប ខ្ញុំបាទជាប្រធានអង្គភាព ក-៤ ក្រោយ

ពេលដែលចាប់ តាទឹ, តាហ៊ែន ហើយទេ ហើយបានតែកន្លះខែ ខ្ញុំបាទត្រូវគេដកខ្លួនទៅលត់ដំ។

[១៤:២៣:១២]

**សៈ** តើគេមានពន្យល់ប្រាប់លោកទេ លើកទី១ ហេតុម៉េចបានជាគេតែងតាំងលោកឱ្យធ្វើជាប្រធានអង្គភាព ក-៤ ហើយក្រោយមកទៅជាដកលោកវិញ? តើគេមានពន្យល់មូលហេតុនេះទេ?

**ឆៈ** ខ្ញុំបាទសូមជម្រាបជូនអង្គតុលាការ គេមិនបានប្រាប់ហេតុផលទេ គ្រាន់ប្រកាសចាត់តាំងបណ្ដោះអាសន្ន នាពេលដែលចាប់មេបញ្ជាការអស់។ បាទនេះសូមមេត្តាទានជ្រាប។

**សៈ** តើលោកមានបាននិយាយអ្នកណាដែលគ្រប់គ្រងពីលើលោកនោះ ថាហេតុអ្វីបានជាលោកបញ្ជូនខ្ញុំទៅឲ្យលត់ដំ ព្រោះរយៈពេល២សប្ដាហ៍មុននេះ លោកតែងតាំងខ្ញុំឲ្យទៅជាមេបញ្ជាការ ហើយទើបតែបាន២សប្ដាហ៍លោកបញ្ជូនខ្ញុំលត់ដំ? លោកមានសួរសំណួរហ្នឹងទៅកាន់ថ្នាក់លើរបស់លោកទេ?

**ឆៈ** ខ្ញុំបាទបានសួរទៅថ្នាក់ដឹកនាំថា មូលហេតុអីបានជាដកខ្ញុំទៅនៅលត់ដំ នេះគឺពិតប្រាកដមែន។

**សៈ** ហើយចុះគេឆ្លើយថាម៉េច?

**ឆៈ** ពួកអ្នកទាំងនោះ គេឆ្លើយថា ខ្ញុំបាទទទួលនិន្នាការពីមេដឹកនាំ ពួកក្បត់ មេឯងក្បត់ហើយឯងគេឲ្យធ្វើការបណ្ដោះអាសន្ន ហើយនិងគេឲ្យទៅនៅលត់ដំ កសាងខ្លួនសាជាថ្មី។

[១៤:២៥:១៩]

**សៈ** ខ្ញុំនឹងត្រឡប់មកសួរចំណុចនេះនៅពេលក្រោយបន្តិច។ ឥឡូវនេះខ្ញុំសួរសំណួរផ្សេងវិញម្ដង។ នៅពេលលោកក្លាយជាប្រធានអង្គភាព ក-៤ នៅខែមីនា ១៩៧៧ តើលោកដឹងទេថាមានកម្លាំងកងទ័ព ឬមានកងទ័ពប៉ុន្មាននាក់ពីកងពល៣១០ ធ្វើការនៅព្រលានយន្តហោះកំពង់ឆ្នាំង?

**ឆៈ** សូមបញ្ជាក់សំណួរ។

**សៈ** លោកក្លាយទៅជាមេបញ្ជាការអង្គភាព ក-៤ នៅខែមីនា ឆ្នាំ៧៧ លោកដឹងទេ តើមានកងទ័ពមកពីកងពល៣១០ ប៉ុន្មាននាក់ដែលធ្វើការនៅឯព្រលានយន្តហោះកំពង់ឆ្នាំងចាប់ពីខែមីនាទៅ?

**ឆៈ** ខ្ញុំបាទពុំបានដឹងទេ មុននឹងទៅ។

**សៈ** តើលោកដឹងសមាជិកនៃកងពលដទៃទៀត ដែលធ្វើការនៅព្រលានយន្តហោះកំពង់ឆ្នាំងនៅដើមឆ្នាំ១៩៧៧ លោកដឹងថាមានកម្លាំងប៉ុន្មានមកពីកងពលផ្សេងទេ? ហើយលោកចាំឈ្មោះណាម្នាក់ដែលបានធ្វើការនៅទីនោះរួចទៅហើយ តើលោកមាននៅចាំទេ?

**ឆ៖** ខ្ញុំបាទសូមឆ្លើយជូនអង្គតុលាការ។ ខ្ញុំបាទពុំបានដឹងថា ទៅពីអង្គភាពណាមានគ្នាប៉ុន្មាននាក់ទេ សូមមេត្តាជ្រាប។

[១៤:២៧:២៥]

**ស៖** លោកប្រធានឯកសារ E3/849 ERN ជាភាសាអង់គ្លេស 00183056, បារាំង 008--

**អ្នកបកប្រែ៖**

លោកប្រធានសុំៗអនុញ្ញាត ញាប់ពេក តាមអត់ទាន់ លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

លោក វ៉ិចទ័រ កូប៉េ បញ្ជាក់ឯកសារ និងលេខ ERN សាឡើងវិញ ព្រោះ -- ហើយសូមកុំញាប់ពេក ពីព្រោះអ្នកបកប្រែបកប្រែមិនទាន់ទេ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

បាទ លោកប្រធានគឺ E3/849 ERN ភាសាអង់គ្លេស 00183956, បារាំង 00334995, ខ្មែរ 00052319។ នេះជាស្ថិតិរួមរបស់កងទ័ពបដិវត្តន៍កម្ពុជាចុះខែមីនា-មេសា ១៩៧៧ គឺឯកសារនេះគឺបាន -- ខ្ញុំមិនដឹងថាបានបកប្រែទៅជាភាសាបារាំងហើយ គឺពាក់ព័ន្ធទៅនឹងកងពល៣១០ ដែលនៅពេលនោះមានកងទ័ពទាំងអស់៦០៩៦នាក់ មានកម្លាំងរបស់ខ្លួនធ្វើការនៅព្រលានយន្តហោះកំពង់ឆ្នាំង។ ដូច្នេះ ជាង ១/៦ នៃកងកម្លាំងកងពល៣១០ទាំងមូលហ្នឹង គឺត្រូវបញ្ជូនទៅធ្វើការនៅព្រលានយន្តហោះកំពង់ឆ្នាំង។ តើលោកដឹងពីចំណុចនេះទេ លោកសាក្សី?

[១៤:២៩:៤៤]

**លោក កែវ លឿ៖**

**ឆ៖** ខ្ញុំបាទពុំបានដឹងថាចំនួនប៉ុន្មានទេ គឺដឹងថាៗខ្លួនទៅធ្វើរួមជាមួយនឹងគេនៅពេលនោះ។

**ស៖** ប៉ុន្តែលោកដឹងមូលហេតុទេថា ហេតុអ្វីបានជាកងពលរបស់លោកនេះត្រូវបានគេ -- ជាច្រើនត្រូវបានគេបញ្ជូនទៅធ្វើការនៅខែមីនា ឆ្នាំ១៩៧៧ រួចទៅហើយនៅឯកំពង់ឆ្នាំង?

**ឆ៖** នៅឆ្នាំ១៩៧៧ ធ្វើព្រលានកំពង់ឆ្នាំង ខ្ញុំពុំបានដឹងទេអង្គាល់ណោះបាទ។

**ស៖** ប៉ុន្តែមានកងទ័ពមកពីកងពល៣១០នេះ ចំនួន១១២៧នាក់ ទៅធ្វើការនៅឯព្រលានយន្តហោះកំពង់ឆ្នាំងរួចទៅហើយ។ គឺតើចំនួនកងទ័ពទាំង១១២៧នាក់ពីកងពល៣១០ទៅធ្វើទីហ្នឹង ជាភារកិច្ចកងទ័ពក្នុងការទៅធ្វើអ៊ីចឹង ឬដោយសារគេដាក់វិន័យ?

**លោក វីល្លៀម ស្មីត៖**

លោកប្រធាន ខ្ញុំជំទាស់ទៅនឹងសំណួរនេះដោយសាក្សីបានឆ្លើយហើយថា គាត់មិនបានដឹងអ្នកណាធ្វើការនៅទីនោះខ្លះទេ។ គាត់មិនដឹងកម្លាំងកងពលណាក្រៅតែពីអង្គភាពផ្ទាល់របស់គាត់តែប៉ុណ្ណោះ។ ហើយការដែលសួរថា តើកម្លាំងកងពល៣១០ចំនួនប៉ុននេះ ទៅធ្វើការនៅកំពង់ឆ្នាំងដោយសារអីចេះ ដោយសារអីចុះ គឺថាសាក្សីឆ្លើយថាគាត់មិនដឹងទេ។

[១៤:៣១:៤៥]

**លោក វ៉ិចទ័រ កូប៉េ៖**

តាមដែលខ្ញុំដឹងសាក្សីរូបនេះ គឺជាមេបញ្ជាការម្នាក់នៅក្នុងកងពលមួយ ដែលមានកម្លាំងជាង ៦.០០០នាក់។ គាត់មិនអាចមិនដឹងថា សមមិត្តរបស់គាត់ទៅធ្វើការនៅកំពង់ឆ្នាំងនោះទេ។ អ៊ីចឹងយ៉ាងណាក៏ដោយខ្ញុំកែសំណួររបស់ខ្ញុំឡើងវិញ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** តើលោកដឹងថា មានអ្នកណាម្នាក់មកពីកងពល៣១០ទៅធ្វើការនៅកំពង់ឆ្នាំងរួចទៅហើយទេ នៅខែមីនា ១៩៧៧ នៅពេលដែលគេបញ្ជូនលោកទៅធ្វើការនៅទីនោះ?

**លោក កែវ លឿ៖**

**ឆ៖** សូមបំភ្លឺ។

**ប្រធានអង្គជំនុំ៖**

សាក្សីសុំយ៉ាងម៉េចសាក្សី? ស្តាប់សំណួរមិនបាន សូមឲ្យសួរសាជាថ្មីម្តងទៀត ឬយ៉ាងម៉េច?

**លោក កែវ លឿ៖**

**ឆ៖** ខ្ញុំបាទសូមការអនុញ្ញាតលោកតុលាការ សូមឲ្យសាកសួរម្តងទៀត ព្រោះឆ្លើយ -- ស្តាប់មិនបានទាន។

[១៤:៣៣:១៩]

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី ខ្ញុំនឹងរៀបសំណួរឡើងវិញ។ ភស្តុតាងបង្ហាញថា នៅខែមីនា ៧៧ កងទ័ពមកពីកងពល៣១០ រាប់ពាន់នាក់ទៅធ្វើការនៅព្រលានយន្តហោះកំពង់ឆ្នាំងរួចទៅហើយ។ សំណួរខ្ញុំសួរថា តើលោកមានស្គាល់អ្នកណាម្នាក់ក្នុងចំណោមកម្លាំងជាង១.០០០នាក់ពីកងពល៣១០ ទៅធ្វើការនៅ

ទីនោះ? ហើយសំណួររបស់ខ្ញុំក៏សួរថា តើអ្នកដែលគេបញ្ជូនទៅធ្វើការកំពង់ឆ្នាំងនេះ គេបញ្ជូនទៅដោយសារតែភារកិច្ចជាកងទ័ព ឬក៏គេបញ្ជូនទៅក្នុងគោលបំណងទៅឲ្យលត់ដំ?

**លោក កែវ លឿ៖**

**ឆ៖** ខ្ញុំបាទសូមឆ្លើយបំភ្លឺអង្គតុលាការ។ នៅពេលដែលទ័ពទៅនេះ ខ្ញុំបាទពុំបានដឹងទេ។ ខ្ញុំបាទដឹងតែពីរឿងធ្វើស្រែនៅអង្គភាព ក-៤។ ដល់ពេលខ្លួនទៅបានដឹងថា ខ្លួននេះត្រូវគេឲ្យទៅធ្វើព្រលានយន្តហោះនៅកំពង់ឆ្នាំង។ ត្រង់ទ័ពដែលបញ្ជូនទៅមុន ខ្ញុំបាទពុំបានដឹងទេទានប្រុស សូមមេត្តាអធ្យាស្រ័យ។

**ប្រធានអង្គជំនុំ៖**

មេធាវីតាំងសំណួររបស់លោកទី២ ព្រោះលោកសំណួរលោកវែង ហើយសាក្សីមិនចងចាំនូវសំណួររបស់លោកទេ។ សំណួរទី១ គឺលោកសាក្សីឆ្លើយរួចហើយ តាំងសំណួរទី២ សាជាថ្មីម្តងទៀត។ ហើយលើកក្រោយគប្បីអង្កន់សំណួរឲ្យបានខ្លីៗ ដើម្បីឲ្យសាក្សីស្តាប់យល់ ហើយនិងអាចឆ្លើយតបបានពេញលេញ ត្រឹមត្រូវ។

[១៤:៣៥:០៧]

**លោក វ៉ិចទ័រ កូប៉េ៖**

បាទ លោកប្រធាន ខ្ញុំនឹងបំបែកសំណួរតូចៗ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី ភស្តុតាងបង្ហាញថានៅខែមីនា ឆ្នាំ១៩៧៧ មានកម្លាំងទ័ពរាប់ពាន់នាក់មកពីកងពល៣១០ ធ្វើការនៅព្រលានយន្តហោះកំពង់ឆ្នាំងរួចទៅហើយ។ សំណួរខ្ញុំសួរថា តើលោកមានបានដឹងកងទ័ពណាម្នាក់ក្នុងចំណោមកងទ័ពជាង១.០០០នាក់ ដែលទៅធ្វើការនៅកំពង់ឆ្នាំង នៅខែមីនា ១៩៧៧នេះ ពេលដែលលោកទៅដល់ហ្នឹង លោកស្គាល់កម្លាំងណាខ្លះក្នុងចំណោមនេះទេ?

**លោក កែវ លឿ៖**

**ឆ៖** ខ្ញុំបាទសូមឆ្លើយជូនអង្គតុលាការ។ នៅពេលដែលខ្ញុំបាទបានធ្វើដំណើរទៅដល់កំពង់ឆ្នាំង គឺមានស្គាល់ខ្លះបាទ។

**ស៖** សំណួរខ្ញុំសួរ មិនសួរដើមដំបូងទេ សួរចំពេលវេលាតែម្តង គឺខែមីនា ៧៧។ កម្លាំងរាប់ពាន់នាក់មកពីកងពល៣១០ ធ្វើការនៅព្រលានយន្តហោះកំពង់ឆ្នាំងរួចទៅហើយ អ៊ីចឹងសំណួរខ្ញុំសួរថា ពេល

លោកទៅដល់ លោកស្គាល់កម្លាំងនេះខ្លះទេ?

[១៤:៣៦:៤១]

**ប្រធានអង្គជំនុំ៖**

គាត់ឆ្លើយរួចហើយ។ សាក្សីមិនបាច់ឆ្លើយតបសំណួរដដែលៗនេះទេ។ បើចង់សួរបញ្ជាក់បន្ថែម អាចសួរបាន។ បាទសំណួរនេះឆ្លើយច្បាស់លាស់ហើយ។

**លោក វ៉ិចទ័រ កូប៉េ៖**

គាត់ឆ្លើយ គាត់ហាក់បីដូចជាឆ្លើយខែមករា ឆ្នាំ១៩៧៨ នៅពេលដែលគាត់ទៅព្រលានយន្តហោះកំពង់ឆ្នាំង។ ខ្ញុំសួរពេលវេលា១០ខែមុនខែមករា ៧៨។

**ប្រធានអង្គជំនុំ៖**

គាត់បានឆ្លើយថា ពេលដែលគាត់មិនទៅ គាត់មិនដឹងទេ។ គាត់ដឹងពេលដែលគាត់ទៅ។

**លោក វ៉ិចទ័រ កូប៉េ៖**

បាទ លោកប្រធាន ខ្ញុំព្យាយាមសួរសំណួរផ្សេងវិញម្តង។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកក្លាយទៅជាមេបញ្ជាការ ក-៤ នៅខែមីនា ១៩៧៧ ក្នុងខែដដែលនេះកម្លាំងកងពល ៣១០ ជាច្រើនបានធ្វើការនៅព្រលានយន្តហោះកំពង់ឆ្នាំងរួចទៅហើយ។ នៅក្នុងពេលដែលលោកជាមេបញ្ជាការនៅ ក-៤ នេះ តើលោកមានដឹងទេថា កម្លាំងរាប់ពាន់នាក់របស់កងពល៣១០ ទៅធ្វើការនៅកំពង់ឆ្នាំង? លោកដឹងទេ ហើយលោកស្គាល់អ្នកណាខ្លះទេ?

[១៤:៣៨:២៣]

**លោក កែវ លឿ៖**

**ឆ៖** ដូចខ្ញុំបាទបានឆ្លើយជម្រាបជូនអង្គតុលាការថាខ្ញុំបាទពុំបានដឹងទេ គឺនៅធ្វើស្រែនៅអង្គភាព ក-៤ នេះ។

**ស៖** ខ្ញុំមានសំណួរផ្សេងទៀត ប៉ុន្តែខ្ញុំមើលម៉ោងទៅ ដូចជាដល់ម៉ោងសម្រាកហើយ។ លោកប្រធាន បើបន្តទៅទៀតខ្ញុំនឹងបង្ហាញឈ្មោះសាក្សីមួយទៀត គាត់គឺជាសមាជិកមកពី ក-៤ ដែរ។ ឯកសារ E3/5274 ខ្ញុំមិនលើកចំឈ្មោះសាក្សីនេះទេ ខ្ញុំគ្រាន់តែបង្ហាញឈ្មោះទៅ តើសាក្សីនៅស្គាល់នៅចាំឈ្មោះសាក្សីម្នាក់នេះទេ គឺសាក្សី 2-TCW-911?

**ប្រធានអង្គជំនុំ៖**

លោកផ្តល់ឯកសារទៅឲ្យសាក្សី ទើបសាក្សីអាចពិនិត្យមើលបាន។ បើសួរអ៊ីចឹង គាត់ម៉េចដឹងរហស្សនាមសាក្សីណា ព្រោះមានតែភាគី និងអង្គជំនុំជម្រះទេស្គាល់អត្តសញ្ញាណដោយប្រើរហស្សនាម។

[១៤:៤០:២៧]

**លោក វ៉ិចទ័រ កូប៉េ៖**

បាទ លោកប្រធាន ដើម្បីជាឯកសារយោងផងដែរ។ ត្រូវការពេលវេលាប្រហែលជា២០វិនាទី ឬក៏ទៅ១នាទី គួរណាស់តែសម្រាកសិនលោកប្រធាន។ ខ្ញុំមានហើយលោកប្រធាន។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សីអានឈ្មោះដាច់ទេ?

**លោក កែវ លឿ៖**

**ឆ៖** ខ្ញុំមើលមិនឃើញទេ បាទ។ អក្សរតូចៗពេក មើលមិនឃើញ។

**ប្រធានអង្គជំនុំ៖**

មន្ត្រីរដ្ឋបាលទៅអានឲ្យគាត់ស្តាប់ ដោយខ្សឹបៗ កុំឲ្យឮដើម្បីឲ្យគាត់ ដើម្បីអាចសួរថាគាត់ស្គាល់ ឬក៏មិនស្គាល់។ ហើយសាក្សី ដល់ពេលមេធាវីសួរ កុំបាច់បង្ហាញនូវឈ្មោះ គ្រាន់តែថាស្គាល់ ឬក៏មិនស្គាល់ទៅបានហើយ។

[១៤:៤២:៤៧]

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សីចាំឈ្មោះនេះទេ?

**លោក កែវ លឿ៖**

**ឆ៖** បាទ ឈ្មោះនេះ ខ្ញុំបាទនៅចាំបាន។

**ស៖** តើឈ្មោះនេះជាសមាជិកអង្គភាព ក-៤ ដែរឬក៏អត់ទេ?

**ឆ៖** បាទ គាត់នៅក្នុងអង្គភាព ក-៤។

**ស៖** នៅទំព័រទី៤ ERN ជាភាសាអង់គ្លេស 00292864, ខ្មែរ 00282959, បារាំង 00483994។ សមាជិក ក-៤ រូបនេះបានឆ្លើយប្រាប់អ្នកស៊ើបអង្កេតរបស់សាលាក្តីថា នៅខែតុលា ១៩៧៧ នៅខែច្រូតស្រូវខែ១១ ឆ្នាំ៧៧ គេឲ្យខ្ញុំទៅសមរភូមិមុខដើម្បីប្រយុទ្ធជាមួយកងទ័ពវៀតណាម។

តើលោកនៅចាំបានទេ ថាសមមិត្តមកពី ក-៤ នេះត្រូវបញ្ជូនទៅប្រយុទ្ធជាមួយវៀតណាម នៅក្នុងតុលា ១៩៧៧ គឺទៅប្រយុទ្ធជាមួយកងទ័ពវៀតណាម លោកចាំទេ?

[១៤:៤៤:២៧]

**ឆ៖** ខ្ញុំបាទនៅចាំបាន។ នៅពេលនោះ នៅក្នុងអង្គភាពពិការ ក-៤ គេជ្រើសរើសរកអ្នកដែលមានដៃល្អ ជើងល្អ អាចនឹងទៅចូលសមរភូមិវិញបាន គេឲ្យទៅ។ ហើយចំណែកពួកខ្ញុំអ្នកដែលមិនអាចដើរទៅបាន គឺឲ្យនៅធ្វើការដដែល។ អ្នកដែលបាក់ជើងគឺនៅដដែល។

**ស៖** លោកដឹងមូលហេតុទេ ហេតុអ្វីបានជាគេបញ្ជូនគាត់ទៅសមរភូមិមុខ? តើដោយសារមូលហេតុអី ព្រោះគាត់ជាសមាជិកនៅ ក-៤ ដែរ?

**ឆ៖** ខ្ញុំបាទសូមជម្រាបអង្គតុលាការ។ នៅពេលនោះគេត្រូវបំបែកទ័ពទៅសមរភូមិ ខ្ញុំបាទពុំបានដឹងអំពីទិសដៅគេទេ គ្រាន់តែគេជ្រើសរើស ថាអ្នកណាអាចនឹងចង់ទៅធ្វើទ័ពទៀត គេឲ្យទៅ ហើយអ្នកដែលទៅនេះ គឺស្ម័គ្រចិត្ត លើកដៃទៅខ្លួនឯង។

**ស៖** ហើយតើលោកចាំទេ មានកម្លាំងប៉ុន្មាននាក់? តើកម្លាំងទាំង២៨៨នាក់នៅក-៤ហ្នឹង លើកដៃស្ម័គ្រចិត្តទៅសមរភូមិមុខ ឬក៏អត់ទេ?

**ឆ៖** ខ្ញុំបាទពុំបានចាំទេ គ្រាន់តែគេប្រាប់ថាអ្នកណាខ្លះចង់ទៅជួរខាងមុខ ទៅទ័ពវិញ គេឲ្យទៅអង្គុយមួយកន្លែង។ ឯត្រង់ចំនួន ខ្ញុំបាទពុំបានដឹងទេបាទ។

[១៤:៤៦:៤៦]

**ស៖** តើកម្លាំងដែលឲ្យទៅអង្គុយម្ដុំហ្នឹងមានចំនួនប៉ុន្មាន? មានចំនួនតិច ឬក៏ច្រើន ពាក់កណ្ដាលនៃចំនួនទាំង២៨៨នាក់ ឬក៏យ៉ាងណា? សូមលោកបញ្ជាក់ចំនួនឲ្យបានច្បាស់លាស់បន្តិចបានទេ។

**ឆ៖** ខ្ញុំបាទពុំបានចាំច្បាស់ទេ។ បើតាមការប៉ាន់ប្រមាណថាជិតពាក់កណ្ដាល។ ហើយនៅតែអ្នកធ្ងន់ៗទេ ដែលមិនអាចទៅមុខនឹងគេបាន។

**ស៖** វាជាសំណួរពិបាកបន្តិច ពីព្រោះស្មានទៅ -- ពាក់ព័ន្ធទៅនឹងតួលេខ។ ចុះបើសិនណាជាលោកវិញ លោកលើកដៃស្ម័គ្រចិត្តទៅ តើគេឲ្យលោកទៅដែរអត់ទេ កាលក្នុងឆ្នាំ៧៧ហ្នឹង ឲ្យលោកទៅប្រយុទ្ធវិញទេ មើលទៅ?

**ប្រធានអង្គជំនុំ៖**

សាក្សីមិនបាច់ឆ្លើយតបនឹងសួរឧបមានវិធីទេ។ សំណួរប្រភេទនេះ អង្គជំនុំជម្រះមិនអនុញ្ញាតឲ្យ

ប្រើទេ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** តើនៅពេលហ្នឹងគេហាមឃាត់មិនឲ្យលោកលើកដៃ ឬក៏យ៉ាងម៉េច នៅខែតុលា ១៩៧៧?

[១៤:៤៨:២៨]

**លោក កែវ លឿ៖**

**ឆ៖** ខ្ញុំបាទសូមឆ្លើយជូនអង្គតុលាការ។ ឲ្យខ្ញុំបាទលើកដៃយ៉ាងម៉េច បើដើរអត់ទាំងត្រង់ផង រហូតមកដល់សព្វថ្ងៃនេះ ដើរអត់ទាំងត្រង់ផង បាទ។ នៅពេលនោះគឺឈឺ នៅឈឺនៅឡើយ មិនអាច។

**ស៖** ខ្ញុំយល់ហើយ នេះជាសំណួរចុងក្រោយមុនពេលឈប់សម្រាក។ តើពិតទេ ដែលថាក្នុងខែតុលា ១៩៧៧ លោកក៏នៅតែជាកងទ័ពម្នាក់នៃកងទ័ពបដិវត្តន៍ប្រជាជនកម្ពុជាផងដែរ តើអ៊ីចឹងឬអត់ទេ?

**ឆ៖** ខ្ញុំបាទសូមជម្រាបជូនអង្គតុលាការមេត្តាជ្រាប។ នៅក្នុងអង្គភាព ក-៤ ក៏គេហៅថា ទ័ពនៅក្នុងកងពល៣១០ដែរ។ គ្រាន់តែបែងចែកជាអង្គភាពអ្នកពិការ និងអ្នកដែលមិនពិការ។

**ស៖** បាទ ខ្ញុំយល់ហើយ ក៏ប៉ុន្តែតើលោកនៅតែជាកងទ័ពបដិវត្តន៍កម្ពុជាដដែលឬ នៅខែតុលា ១៩៧៧?

**ឆ៖** ខ្ញុំបាទបានឆ្លើយជូនអង្គតុលាការហើយថា នៅខែតុលា ឆ្នាំ១៩៧៧ ខ្ញុំបាទនៅក្នុងអង្គភាពពិការនៅក្នុងកងពល៣១០ នេះឯងបាទ។

[១៤:៥០:៣០]

**ស៖** ខ្ញុំយល់ហើយ។ និយាយជាគោលការណ៍ តើគេនៅតែចាត់ទុកលោកថា ជាកងទ័ពដែលអាចនឹងមានលទ្ធភាពទៅប្រយុទ្ធនៅសមរភូមិដដែលឬ?

**ឆ៖** ខ្ញុំបាទពិបាកឆ្លើយនឹងសំណួរនេះណាស់។

**ស៖** តាមដែលខ្ញុំយល់ចម្លើយរបស់លោកលើកមុន គឺថាលោកលែងនៅជាកងទ័ពទៀតហើយ។ មិនដឹងថា លោកជាអ្វីទេ តែលោក -- អ៊ីចឹងតើពិតទេថា ចាប់ពីខែតុលា ៧៧ មកក្រោយៗមកទៀតមក លោកនៅតែជាកងទ័ពម្នាក់នៃកងទ័ពបដិវត្តន៍កម្ពុជាដដែល តើអ៊ីចឹង ឬក៏អត់ទេ?

**ឆ៖** ខ្ញុំបាទសូមជម្រាបជូនអង្គតុលាការ។ ចាប់ពីពេលនោះ មកខ្ញុំបាទនៅក្នុងកងទ័ព តែជាអ្នកពិការ មានអង្គភាពនៅដោយឡែកៗពីគ្នា ដូចខ្ញុំបាទបានជម្រាបជូនខាងដើមហើយ។

**ប្រធានអង្គជំនុំ៖**

បាទ ចម្លើយតបច្បាស់លាស់ហើយ។ ហើយឥឡូវនេះ ដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងបីនិងដប់នាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី និងអ្នកជំនាញ ដល់សាក្សីរូបនេះ នៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្តល់សក្ខីកម្មក្នុងបន្ទប់សវនាការនេះ នៅក្នុងវេលាម៉ោងបី និងដប់នាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៥២ នាទី ដល់ម៉ោង ១៥:១១ នាទី)*

[១៥:១១:២៥]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ និងផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក នួន ជា ដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណ លោកប្រធាន។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី មុនពេលឈប់សម្រាក យើងនិយាយគ្នាអំពីសមមិត្តរបស់លោកនៅ ក-៤ ដែលស្ម័គ្រចិត្តទៅសមរភូមិវិញ។ ឧបមាថា នៅខែ -- ក-៤នោះគឺមាន២៨៨នាក់ លោកថាជាងពាក់កណ្តាលស្ម័គ្រចិត្តទៅវិញ ទៅសមរភូមិវិញ។ តើអាចថាសមាជិកក-៤ ១៤៤នាក់ស្ម័គ្រចិត្តទៅសមរភូមិវិញ ប្រយុទ្ធជាមួយវៀតណាមនៅខែតុលា ៧៧ បើថាអ៊ីចឹង តើត្រឹមត្រូវដែរទេ?

**លោក កែវ លឿ៖**

**ឆ៖** បាទ។

[១៥:១២:៥៣]

**ស៖** កងទ័ពវៀតណាមបានដកចេញពីកម្ពុជាវិញនៅថ្ងៃទី០៦ មករា ៧៨ តើលោកនៅចាំទេ សមាជិកនៅ ក-៤ ប៉ុន្មាននាក់ដែលស្ម័គ្រចិត្តទៅសមរភូមិហ្នឹង ហើយក្រោយមកកងទ័ពវៀតណាមបាន ដកវិញទៅ សមាជិកទាំងនោះត្រឡប់មកប៉ុន្មាននាក់វិញ មក ក-៤ វិញ?

**ឆ៖** ខ្ញុំអត់យល់សំណួរនេះ។

**ស៖** ប្រហែលជាកងទ័ពចេញពីក-៤ ១៥០នាក់ បានស្ម័គ្រចិត្តទៅប្រយុទ្ធជាមួយកងទ័ពវៀត-ណាមនៅសមរភូមិមុខ។ កងទ័ពវៀតណាមដកចេញទៅវិញនៅថ្ងៃទី០៦ មករា ១៩៧៨។ សំណួរខ្ញុំ សួរថាកងទ័ពដែលស្ម័គ្រចិត្តទៅប្រយុទ្ធនៅសមរភូមិឡើងវិញនោះ ពីក-៤នោះបានត្រឡប់មក ក-៤វិញ ប៉ុន្មាននាក់ដែរ?

**ឆ៖** ខ្ញុំបាទសូមជម្រាបអង្គតុលាការ មិនដែលឃើញអ្នកដែលសមរភូមិហើយ វិលមកវិញទេ។

**ស៖** ដូច្នេះចម្លើយរបស់លោកឆ្លើយថា កងទ័ពស្ទើរតែទាំង១៥០នាក់ហ្នឹង គឺថាត្រូវបានទទួល - - គឺថាត្រូវស្លាប់នៅក្នុងសមរភូមិទាំងអស់ ឬក៏យ៉ាងម៉េច?

[១៥:១៤:៤៧]

**ឆ៖** កងទ័ពទាំងអស់ដែលដកចេញពី ក-៤ ទៅសមរភូមិនេះ មិនដឹងជាគេស្លាប់ មិនដឹងជាគេ រស់ បើបែកបាក់គ្នាអស់ហើយ ខ្ញុំអត់ដឹងបាទ។

**ស៖** កាលពីថ្ងៃសុក្រ លោកបានឆ្លើយថា លោកនិងសមាជិកដទៃទៀត មិនមានសិទ្ធិកាន់អាវុធ ទេ។ តើលោកអាចជម្រាបអង្គជំនុំជម្រះបានទេ ដើម្បីឲ្យវាស៊ីចង្វាក់គ្នា ថាវាស៊ីចង្វាក់គ្នាជាមួយនឹង កងទ័ពរបស់លោកជាងពាក់កណ្តាលស្ម័គ្រចិត្តទៅសមរភូមិមុខវិញ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ!

**លោក វីល្លៀម ស្មីត៖**

នេះគ្រាន់តែជាការបញ្ជាក់ទៅលោកប្រធាន។ មេធាវីការពារក្តីគួរតែបញ្ជាក់ពេលវេលាឲ្យបាន ច្បាស់លាស់ ពីព្រោះសាក្សីឆ្លើយថា នៅពេលដែលគាត់ទៅព្រលានយន្តហោះកំពង់ឆ្នាំងហ្នឹង គេមិន អនុញ្ញាតឲ្យគាត់កាន់អាវុធទេ ដោយសារស្ថានភាពវាប្រែប្រួលពីពេលមួយទៅពេលមួយ។ គួរសួរពី

ពេលវេលាឲ្យបានច្បាស់លាស់។

[១៥:១៦:១៤]

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ខ្ញុំនឹងរៀបចំសំណួរខ្ញុំឡើងវិញ។ លោកសាក្សី លោកបានឆ្លើយថារូបលោកក៏ដូចជាកងទ័ពដទៃទៀតនៅក្នុងអង្គភាពរបស់លោកហ្នឹង គឺមិនអនុញ្ញាតឲ្យកាន់កាំភ្លើងទេ។ រយៈពេលដែលគេមិនឲ្យកាន់កាំភ្លើងហ្នឹង តើរយៈពេលណាមួយ? សូមលោកបញ្ជាក់បន្តិចមើល។

**លោក កែវ លឿ៖**

**ឆ៖** ខ្ញុំបានសូមជម្រាបអង្គសវនាការឲ្យបានជ្រាប។ នៅពេលដែលចប់សង្គ្រាមឆ្នាំ១៩៧៥ នៅពេលនោះ គឺដកកាំភ្លើងទាំងអស់គ្នា គេដកកាំភ្លើង។

**ស៖** ដូច្នេះការដកកាំភ្លើងនេះ គឺមិនពាក់ព័ន្ធទៅនឹងការងារដែលលោកធ្វើនៅកំពង់ឆ្នាំងនោះទេ គឺតាំងពីឆ្នាំ១៩៧៥ មកម្ល៉េះ។ អ៊ីចឹងមែនទេ?

**ឆ៖** ដកកាំភ្លើងគឺមុនខ្ញុំទៅ ក៥ -- ទៅកំពង់ឆ្នាំង។

[១៥:១៧:៣៦]

**ស៖** ខ្ញុំយល់ហើយ ប៉ុន្តែទាហានប្រហែល១៥០នាក់ គឺថាគេស្ម័គ្រចិត្តទៅសមរភូមិមុខវិញ។ តើទាហានរបស់លោកទាំង -- កងទ័ពរបស់លោកទាំង១៥០នាក់ហ្នឹង ទៅប្រយុទ្ធជាមួយវៀតណាមហ្នឹង គេឲ្យកាន់កាំភ្លើងទេ ឬក៏ទៅប្រើដៃទទេវាយជាមួយវៀតណាម?

**ឆ៖** ខ្ញុំបាទសូមជម្រាបជូនអង្គតុលាការ នៅពេលដែលគេដកចេញពី ក-៤ ទាំងអស់ ទ័ពដែលស្ម័គ្រចិត្តទៅនេះ គេបំពាក់អាវុធយ៉ាងម៉េច គឺខ្ញុំអត់បានដឹងបាទ។

**ស៖** តើក្នុងនាមលោកក៏ជាកងទ័ពម្នាក់ដែរ តើសមមិត្តរបស់លោក ដែលៗមានគេបញ្ជូនកងទ័ពឲ្យទៅប្រយុទ្ធជាមួយខ្មាំងដោយអត់មានអាវុធទេ ប្រយុទ្ធដៃទទេទេ?

**ឆ៖** ដូចខ្ញុំបាទបានជម្រាបហើយអម្បាញ់មិញថា អ្នកដែលគេបញ្ជូនទៅសមរភូមិ គេឲ្យកាន់កាំភ្លើង ឬមិនឲ្យកាន់ ខ្ញុំបាទពុំបានដឹងទេ ព្រោះគេដកចេញពីអង្គភាពក-៤ហើយ។ នេះសូមអង្គតុលាការមេត្តាជ្រាប។

[១៥:១៩:១៤]

**ស៖** បើដូច្នេះខ្ញុំរៀបសំណួរឡើងវិញ។ រយៈពេលប្រហែលជា៧ឆ្នាំ រួមទាំងរយៈពេលមួយ

សប្តាហ៍ពីរសប្តាហ៍ ដែលលោកក្លាយទៅជាមេបញ្ជាការនៅ ក-៤។ អ៊ីចឹងរយៈពេលប្រហែល៧ឆ្នាំនេះ លោកដែលជួបបទពិសោធន៍ណាមួយ ដែលគេបញ្ជូនកងទ័ពទៅឲ្យប្រយុទ្ធជាមួយកងទ័ពវៀតណាមដៃទទេ ទៅដៃទទេ ប្រយុទ្ធជាមួយសុទ្ធតែកាំភ្លើងយន្ត ដែរទេ?

**ឆ៖** ខ្ញុំបាទសូមជម្រាបជូនអង្គតុលាការ អ្នកដែលប្រយុទ្ធមិនដែលពីណាឲ្យទៅប្រយុទ្ធដៃទទេ។

**ស៖** បាទ ខ្ញុំក៏គិតអ៊ីចឹងដែរលោកសាក្សី។ ខ្ញុំសូមសួរសំណួរបន្ថែមទាក់ទងទៅនឹងពេលដែលលោកចូលរួមជាមួយកងទ័ពបដិវត្តន៍នៅឆ្នាំ១៩៧០ រហូតដល់លោកក្លាយមកជាមេបញ្ជាការនៅអង្គភាព ក-៤។ ក្នុងរយៈពេលនុ៎ងប្រហែលជា៧ឆ្នាំ លោកដែលបានទទួលបញ្ជាបែបនេះទេ?

**ឆ៖** ចាប់តាំងពីខ្ញុំបាទចូលជួរកងទ័ពមិនដែលបានទទួលបទបញ្ជាបែបនេះទេ។

**ស៖** ប្រហែលជាមានបញ្ហាដោយសារការបកប្រែភាសា។ តើលោកដែលបដិសេធមិនគោរពតាមបទបញ្ជាទេ លោកក្នុងរយៈពេល៧ឆ្នាំនេះ?

[១៥:២១:១៧]

**ឆ៖** ខ្ញុំបាទសូមឆ្លើយជូនអង្គតុលាការមេត្តាជ្រាប ទ័ពមិនប៊ិានជំទាស់បញ្ជាអំពីមេបញ្ជាការទេ។

**ស៖** ប៉ុន្តែខ្លួនលោកផ្ទាល់គឺជាមេបញ្ជាការ តើលោកដែលបញ្ជាទៅកងទ័ពរបស់លោកផ្ទាល់ទេ?

**ឆ៖** ខ្ញុំបាទសូមជម្រាបជូនអង្គតុលាការ នៅពេលមានការងារដែលត្រូវធ្វើគឺបញ្ជាដូចតែគ្នា។

**ស៖** អ៊ីចឹងមានន័យថា ទោះបីការបញ្ជានោះវាខុសច្បាប់ក៏ដោយក៏ត្រូវតែអនុវត្តតាមដែរ។ អ៊ីចឹងមែនទេ?

**ឆ៖** ខ្ញុំបាទសូមជម្រាបជូនអង្គតុលាការ។ ខ្ញុំបាទនៅអង្គភាពនេះមិនដែលអ្នកណាបញ្ជាកិច្ចការងារដែលក្រៅលក្ខខណ្ឌដែលត្រូវធ្វើទេ។

**ស៖** ក្នុងរយៈពេលពីរបីសប្តាហ៍ដែលលោកធ្វើជាមេបញ្ជាការនៅ ក-៤ តើកម្លាំងរបស់លោកពេលសម្រាន្តហ្នឹងមានមុង កន្ទេល ខ្នើយ ភួយ មានដំបូលអីត្រឹមត្រូវទេ?

**ឆ៖** ខ្ញុំសូមជម្រាបជូនអង្គតុលាការ។ នៅក្នុងអង្គភាពក-៤ គឺគេធ្វើជាផ្ទះវែងសម្រាប់សម្រាកតែពុំមានកន្ទេលក្រាលទេ មុងក៏គ្មានដែរបាទ។

[១៥:២៣:៤៨]

**ស៖** ដូច្នេះ នៅពេលដែលលោកជាមេបញ្ជាការនៅក-៤ គឺថាស្ថានភាពវាដូចតែគ្នាទេនៅពេលដែលលោកធ្វើការនៅក-៤ ដែរ ប៉ុន្តែក-៤ នៅពេលដែលគេបញ្ជូនលោកទៅកំពង់ឆ្នាំង។ ស្ថានភាពវាដូច

តែគ្នាអ៊ីចឹង ឬក៏អត់ទេ?

**ឆ៖** ខ្ញុំបាទសូមជម្រាបជូនអង្គតុលាការមេត្តាជ្រាប នៅអង្គភាពក-៤ ក៏ដូចជាទៅនៅកំពង់ឆ្នាំង គឺដូចគ្នា។

**ស៖** នៅពេលដែលលោកជាមេបញ្ជាការនៅក-៤ លោកមានបើកប្រាក់ខែឲ្យកងទ័ពរបស់លោកទេ?

**ឆ៖** ខ្ញុំបាទសូមជម្រាបជូនអង្គតុលាការ ទ័ពគ្មានប្រាក់ខែទេ។

**ស៖** ដូច្នេះគឺមានន័យថា មិនមានអ្វីខុសគ្នាទេ នៅពេលដែលលោកធ្វើការនៅអង្គភាព ក-៤ ក៏ដូចជានៅព្រលានយន្តហោះកំពង់ឆ្នាំង គឺថាកិច្ចការដែលលោកធ្វើហ្នឹង គឺអត់មានបានប្រាក់ខែទេ តើអ៊ីចឹង ឬក៏អត់ទេ?

**ឆ៖** បាទ ពិតមែន។

[១៥:២៥:២៨]

**ស៖** ពេលលោកជាមេបញ្ជាការនៅក-៤ តើអនាម័យនៅ ក-៤ យ៉ាងម៉េចដែរ? លោកមានផ្តល់សម្ភារៈសម្រាប់ដេកពួនឲ្យកម្លាំងរបស់លោកទេ?

**ឆ៖** ខ្ញុំបាទសូមជម្រាបជូនអង្គតុលាការ សូមមេត្តាជ្រាប នៅអង្គភាពក-៤ ផ្នែកអនាម័យ វាអត់មាន សូម្បីតែខ្ញុំបាទផ្ទាល់ក៏អត់មានមុង មានភួយដណ្តប់ដែរបាទ។

**ស៖** ដូច្នេះតើត្រឹមត្រូវទេ នៅពេលដែលលោកជាមេបញ្ជាការ គឺស្ថានភាពនៅ ក-៤ ក៏មិនខុសគ្នាពីស្ថានភាពនៅព្រលានយន្តហោះដែរ គឺដូចតែគ្នាទេ? បើខ្ញុំនិយាយអ៊ីចឹងតើត្រឹមត្រូវ ឬក៏អត់ទេ?

**ឆ៖** បាទ ត្រឹមត្រូវ។

**ស៖** ខ្ញុំសួរសំណួរផ្សេងវិញ។ សូមលោកជួយពន្យល់អំពីស្ថានភាពការងារសម្ភារៈ ឧបករណ៍ផ្សេងៗដែលគេផ្តល់មកឲ្យនៅពេលដែលលោកជាមេបញ្ជាការនៅ ក-៤ និងនៅពេលដែលលោកធ្វើការនៅព្រលានយន្តហោះកំពង់ឆ្នាំង ក្នុងនាមលោកជាសមាជិក ក-៤ ដដែលនោះ តើវាមានលក្ខណៈខុសគ្នាទេ?

[១៥:២៧:០៨]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំទាន់អាលឆ្លើយតប!

សូមអញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ!

**លោក វីណ្ឌៀម ស្មីត៖**

ខ្ញុំសូមជំទាស់លោកប្រធាន ដោយសារភាពពាក់ព័ន្ធនៃការតាំងសំណួរនេះ គឺថាសាក្សីគាត់ថា គាត់ជាមេបញ្ជាការនៅ ក-៤ ប្រហែលជា២សប្តាហ៍ទេ នៅឆ្នាំ៧៧។ ហើយនៅពេលមួយគាត់និយាយថា គាត់ហើយនិងអង្គភាពរបស់គាត់ត្រូវគេបញ្ជូនទៅឲ្យលត់ដំប្រហែលជា៥ខែ។ អ៊ីចឹងបានជា ខ្ញុំឆ្ងល់ថា ការសួរទៅឲ្យប្រៀបធៀបស្ថានភាពនៅ ក-៤ ដែលមានរយៈប្រហែលជា២សប្តាហ៍ និងរយៈពេលដែលគាត់បញ្ជាក់ភស្តុតាងហើយថា គាត់និងអង្គភាពរបស់គាត់គេបញ្ជូនទៅឲ្យលត់ដំប្រហែលជា៥ខែ មុនគេបញ្ជូនទៅកំពង់ឆ្នាំង។ បើសិនណាជាគំនិតយោបល់នោះ មិនមានការ សួរថាតើមិនមានការរើសអើងអីទេនៅកំពង់ឆ្នាំង ហើយនិងនៅពេលលោកជាមេបញ្ជាការនៅ ក-៤ ប្រហែលជាប្រសើរជាជាងគឺសួរប្រៀបធៀបគ្នារយៈពេលដែលធ្វើការនៅកន្លែងលត់ដំ ហើយនិង ក-៤វិញ។

[១៥:២៨:៤៥]

**លោក វ៉ិចទ័រ កូប៉េ៖**

ឥឡូវខ្ញុំទុកចំណុចលត់ដំនេះមួយដុំចុះ។ ខ្ញុំធ្វើការប្រៀបធៀបរវាងពេលវេលាដែលគាត់ធ្វើជាមេបញ្ជាការនៅ ក-៤ ប្រហែលជាក្នុងខែមីនា ១៩៧៧ និងស្ថានភាពការងារនៅឆ្នាំ១៩៧៨ នៅព្រលានយន្តហោះកំពង់ឆ្នាំង ដែលដីកាបញ្ជូនរឿងទៅជំនុំជម្រះថា ជាការងារមួយដូចទាសករនៅកំពង់ឆ្នាំង។ អ៊ីចឹងហើយខ្ញុំថា ជាការត្រឹមត្រូវហើយក្នុងការស្វែងយល់រកឲ្យឃើញថា ស្ថានភាពការងារនៅកន្លែងណាមួយដែលវាមានលក្ខណៈជាការងារបែបទាសករនោះ តើមានការប្រើប្រាស់កងទ័ពនៅអង្គភាពក-៤ និងនៅកំពង់ឆ្នាំង មានការឲ្យកងទ័ពធ្វើការងារដូចទាសករមែនឬក៏អត់?

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

តើជាការជំទាស់ ឬក៏យ៉ាងម៉េច លោកសហព្រះរាជអាជ្ញារងអន្តរជាតិ?

**លោក វីណ្ឌៀម ស្មីត៖**

ត្រឹមត្រូវហើយ គឺជាការកត់សម្គាល់ច្រើនជាងលោកស្រីចៅក្រម។

[១៥:២៩:៥២]

**លោក វ៉ិចទ័រ កូប៉េ៖**

បាទខ្ញុំសូមអរគុណចំពោះការកត់សម្គាល់របស់លោក។

**សួរដោយលោក វិចទ័រ កូប៉េះ**

**ស៖** លោកសាក្សី សូមលោកផ្តល់ឧទាហរណ៍មួយឲ្យបានច្បាស់លាស់ទាក់ទងទៅនឹងស្ថានភាពការងារពេលម៉ោងការងារ សម្ភារៈធ្វើការងារនៅក្នុងសប្តាហ៍ ឆ្នាំ១៩៧៧នៅក-៤ និងរយៈពេលដែលលោកនៅព្រលានយន្តហោះកំពង់ឆ្នាំង។ តើលក្ខណៈខុសគ្នារវាងកន្លែងទាំងពីរ ពេលវេលាទាំងពីរវាខុសគ្នាយ៉ាងដូចម្តេចដែរ?

**លោក កែវ លឿ៖**

**ឆ៖** ខ្ញុំបាទសូមឆ្លើយជូនអង្គតុលាការ មេត្តាជ្រាប។ នៅកន្លែង ក-៤ មានស្ថានភាព និងរបស់ប្រើប្រាស់ គឺមានគេបើកចប កាំបិត និងគោសម្រាប់ធ្វើស្រែ ខុសពីទៅនៅកំពង់ឆ្នាំង។ ទៅនៅកំពង់ឆ្នាំងគេបើកចបឲ្យម្នាក់មួយសម្រាប់កាប់ជីកស្មៅ និងកាប់រណ្តៅតាមឫស ហើយនិងស្ថានភាពការងារនៅ ក-៤ ព្រឹកម៉ោងប្រាំមួយ គឺយើងចេញទៅតាមធម្មតា។ ម៉ោងដប់មួយសម្រាក ម៉ោងមួយគឺយើងចុះធ្វើស្រែរហូតដល់ម៉ោងប្រាំ។ តែនៅកំពង់ឆ្នាំង គឺម៉ោងបួន គឺហៅប្រជុំជួរចេញដំណើរទៅការដ្ឋានរហូតដល់ម៉ោងដប់មួយថ្ងៃត្រង់។ ហើយម៉ោងមួយចូលធ្វើការរហូតដល់ម៉ោងប្រាំមួយយប់ក៏មាន ប្រាំពីរយប់ក៏មាន។ ជួនកាលមានដល់ទៅម៉ោងប្រាំបួនយប់ ដប់យប់ក៏មាន។ នេះសូមអង្គតុលាការមេត្តាជ្រាប។

[១៥:៣២:០២]

**ស៖** បាទ ខ្ញុំយល់ហើយ ក៏ប៉ុន្តែនៅពេលដែលលោកនៅព្រលានយន្តហោះកំពង់ឆ្នាំង នៅថ្ងៃទី ១៥ មករា ១៩៧៨ តើមានការប្រាស្រ័យទាក់ទងជាគ្នាជាបន្ទាន់ណាមួយរវាងលោក និងអ្នកដទៃទៀតទាក់ទងទៅនឹងសង្គ្រាមជាមួយវៀតណាមដែរឬទេ? គឺរយៈពេលជាច្រើនខែមុនខែមករា ១៩៧៨ មានកងទ័ពវៀតណាមឆ្លងកាត់ព្រំដែន តើគេមានបញ្ជាថា ឲ្យបញ្ចប់ការងារនៅកំពង់ឆ្នាំងឲ្យបានឆាប់រហ័សហើយមានទំនាក់ទំនងគ្នារឿងបញ្ហាជាមួយកងទ័ពវៀតណាមទេ?

**ឆ៖** ខ្ញុំបាទសូមជម្រាបជូនអង្គតុលាការ។ នៅពេលដែលខ្ញុំបាទនៅកំពង់ឆ្នាំង មិនដែលឮសួរនរណានិយាយអំពីវៀតណាមឆ្លងកាត់ទៅណាមកណា គឺអត់ដែលឮសួរនរណានិយាយទេ។ ខ្ញុំបាទរស់នៅក្រុមណាគឺធ្វើការនៅក្រុមនោះតាមធម្មតាៗ។

**ស៖** ខ្ញុំសូមរៀបសំណួរឡើងវិញ។ លោកចាប់ផ្តើមធ្វើការនៅព្រលានយន្តហោះកំពង់ឆ្នាំង នៅថ្ងៃទី១៥ មករា ៧៨។ ៩ថ្ងៃមុននេះ មុនខែមករា ៧៨ គឺលោកមានចាំថា នៅពេលនោះគឺថាសង្គ្រាមបញ្ចប់ហើយ ឬក៏ថាកងទ័ពវៀតណាមបានដកទៅវិញ លោកមាននៅចាំចំណុចនេះទេ?

**ឆ៖** ខ្ញុំបាទពុំបានដឹងទេ។

[១៥:៣៣:៥៩]

**ស៖** លោកមកពីភូមិភាគឧត្តរ ជាអ្នកដែលមានប្រភពមកពីភូមិភាគឧត្តរ មានទំនប់៦មករា នៅភូមិភាគឧត្តរ។ អ៊ីចឹងលោកមានដឹងទេថា នៅភូមិភាគឧត្តរហ្នឹង ម៉េចគេហៅទំនប់មួយហ្នឹងហៅថា ទំនប់៦មករា?

**ឆ៖** ខ្ញុំបាទពុំបានដឹង ព្រោះមិនដែលឃើញផងបាទ។

**ស៖** លោកក៏បានឆ្លើយផងដែរថា រយៈពេលមុនពេលលោកទៅដល់កំពង់ឆ្នាំង លោកត្រូវបាន គេបញ្ជូនមកភ្នំពេញ ដើម្បីមករៀនសូត្រ៣ខែ ដើម្បីឲ្យទៅជាអ្នកវាស់វែងដីធ្លី។ តើគេមានប្រាប់លោក ថា ហេតុអ្វីបានជាគេជ្រើសរើសរូបលោកឲ្យទៅចូលវគ្គរៀនសូត្រក្លាយទៅជាអ្នកវាស់ដី៣ខែនេះទេ?

**លោក វីណ្ឌៀម ស្មីត៖**

ខ្ញុំសូមជំទាស់គឺថា ២ខែក្រោយពេលគាត់ទៅដល់កំពង់ឆ្នាំង ទើបគេជ្រើសរើស។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** បាទ សូមកែប្រែ២ខែ។ តើគេមានប្រាប់លោកទេ ថាហេតុអ្វីបានជាគេជ្រើសរើសរូប លោកឲ្យមករៀនសូត្រនៅភ្នំពេញ ធ្វើជាអ្នកវាស់វែងដីធ្លីហ្នឹង?

**លោក កែវ លឿ៖**

**ឆ៖** សំណួរនេះ ខ្ញុំបាទដូចជាឆ្លើយពីថ្ងៃសុក្រម្ល៉េះ ចប់អស់ហើយ ហើយសួរនេះសួរសាដែលៗ វិញ។ ហើយខ្ញុំបាទសូមឆ្លើយជូនអង្គតុលាការសាជាថ្មីម្តងទៀតថា នៅពេលនោះគឺមានម្នាក់គេឈ្មោះ បងហាន បានស្គាល់ខ្ញុំ ហើយសូមឲ្យខ្ញុំទៅរៀនផ្នែកខាងបច្ចេកទេសនេះ ដូចខ្ញុំបាទបានឆ្លើយពីថ្ងៃសុក្រ រួចហើយ។

[១៥:៣៦:០៩]

**ស៖** ខ្ញុំដឹងហើយថាលោកបានឆ្លើយ។ ហាន នៅកងពល៥០២ លោកនៅកងពល៣១០ តើ មេបញ្ជាការផ្ទាល់របស់លោកមានបានប្រាប់លោកថា ហេតុអ្វីគេជ្រើសរើសលោកឲ្យមករៀនសូត្រនៅ ភ្នំពេញ ៣ខែនេះទេ?

**ឆ៖** មុនដំបូងគេធ្វើប្រវត្តិរូប ហើយដល់ធ្វើប្រវត្តិរូប គេថាគួរអាចឲ្យទៅរៀនបាន ព្រោះវាមាន ចំណេះវិជ្ជាគ្រាន់បើ។

**ស៖** តើមេបញ្ជាការរបស់លោកមានប្រាប់លោកថា គេសម្រេចជ្រើសរើសលោកឲ្យទៅជា -- ឲ្យទៅរៀនសូត្រផ្នែកខាងផ្នែកបច្ចេកទេស បញ្ហាពាក់ព័ន្ធនឹងសន្តិសុខនៅព្រលានយន្តហោះនេះដែរទេ?

**ឆ៖** ខ្ញុំពុំបានដឹងពីមូលហេតុទេ។ គ្រាន់គេប្រាប់ថា "ឯងត្រូវទៅរៀននៅភ្នំពេញ យកចំណេះនេះមកប្រើនៅទីនេះវិញ"។ នេះខ្ញុំបាទបានដឹងប៉ុណ្ណេះ។

**ស៖** តែលោកបានឆ្លើយថាលោកធ្លាប់ធ្វើជាមេបញ្ជាការនៅ ក-៤ ហើយក្រោយមកថាត្រូវគេបញ្ជូនទៅឲ្យលត់ដំ ហើយក្រោយមកទៀត គេបែរទៅជាជ្រើសរើសលោកឲ្យមករៀនសូត្រ៣ខែ។ តើគេមានប្រាប់លោកថា ហេតុអ្វីបានជាគេកែប្រែដោយសារថា មុនដំបូងគេយល់ថា លោកគឺគេមិនទុកចិត្ត ហើយក្រោយមកគេមានប្រាប់លោកទេ ថាលោកក្លាយទៅជាកម្មាភិបាលគួរឲ្យទុកចិត្តវិញអ៊ីចឹង?

[១៥:៣៨:៣២]

**ឆ៖** សំណួរនេះខ្ញុំពិបាកនឹងឆ្លើយជូន។ តែខ្ញុំៗបាទ គ្រាន់តែសូមរៀបរាប់អំពីសំណួរដែលលោកមេធាវីការពារក្តីចោទសួរខ្ញុំនេះ ថាមូលហេតុអីបានជាគេដកសេចក្តីទុកចិត្ត ហើយទុកចិត្ត។ អ៊ីចឹងទេខ្ញុំបាទសូមជម្រាបថា ខ្ញុំបាទ ក្រោយពីការចាប់មេៗនៅកងពល ក-៤ អស់ ខ្ញុំបាទត្រូវដកទៅនៅលត់ដំ៥ខែ។ ក្រោយនោះមកគេបញ្ជូនខ្ញុំបាទទៅកំពង់ឆ្នាំង។ ទៅកំពង់ឆ្នាំងបាន២ខែ ហ្នឹងគេឲ្យខ្ញុំបាទមករៀនខាងថ្លឹងដី។ នេះខ្ញុំបាទជម្រាបជូនពីថ្ងៃសុក្ររួចមកហើយ។

**ស៖** ខ្ញុំសួររបៀបផ្សេងវិញ។ នៅពេលគេឲ្យលោកក្លាយទៅជាអ្នកថ្លឹងដី អ្នកវាស់វែងដី តើខ្លួនលោកយល់ឃើញថា ជាការទម្លាក់បុណ្យស័ក្តិ ឬក៏ជាការដំឡើងបុណ្យស័ក្តិ?

**ឆ៖** ខ្ញុំបាទសូមជម្រាបជូនអង្គតុលាការមេត្តាជ្រាប នៅខាងវាស់វែងដី ថ្លឹងដី មិនមែនជាតួកម្មាភិបាលទេ គឺជាយុទ្ធជនទាំងអស់គ្នាអ្នកធ្វើការនៅកន្លែងនោះ។ មានមេក្រុម មេពួក គេត្រួតត្រាពីលើមក។

**ស៖** បាទ ខ្ញុំសូមបន្តទៀតលោកសាក្សី។ គ្រាន់តែមុននឹងបន្ត លោកនិយាយថា លោកជាកម្មា-ភិបាលបដិវត្តន៍ ស្មោះត្រង់រហូតដល់ឆ្នាំ១៩៧៩។ តើខ្ញុំនិយាយយ៉ាងដូច្នេះ ត្រឹមត្រូវដែរឬទេ គឺលោកជាកម្មាភិបាលបដិវត្តន៍ស្មោះត្រង់រហូតដល់ឆ្នាំ១៩៧៩?

**ឆ៖** ខ្ញុំបាទសូមជម្រាបជូនអង្គតុលាការ សំណួរនេះសួរសាចុះសាឡើង ហើយដូចជាមិនមានអង្គហេតុណាមួយដែលធ្វើឲ្យខ្ញុំបាទឆ្លើយបាន។ សំណួរនេះហាក់ដូចជាសួរដើម្បីបង្វែងដាន។ ខ្ញុំសូមលោកប្រធានជួយសម្រួល។

[១៥:៤១:២១]

**ប្រធានអង្គជំនុំ៖**

សាក្សីដោយសារនៅតុលាការ នេះយើងប្រើពាក្យមួយគេហៅថា "សួរដេញដោលសាក្សី"។ អ៊ីចឹងនីតិវិធីសួរនៅតុលាការវាដោយផ្សេង មានចរិតផ្សេងពីសួរធម្មតា។ ដូច្នេះសាក្សីព្យាយាមឆ្លើយតបទៅនឹងសំណួរ ហើយក្នុងករណីសាក្សីភ្លេច សាក្សីមិនចាំ ឬក៏មិនដឹង គឺឆ្លើយថាមិនដឹង។ ចំពោះសំណួរច្រំដែល សំណួរដែលហាមឃាត់នោះគឺអង្គជំនុំជម្រះបានជម្រាបជូនភាគីរួចហើយ។ ហើយមធ្យោបាយដែលដោះស្រាយបញ្ហានេះមានពីរ ទី១ លោកស្ដាប់ហើយ ភាគីម្ខាងៗសុទ្ធតែមានសិទ្ធិជំទាស់ទៅនឹងការតាំងសំណួរមិនច្បាស់លាស់ សំណួរច្រំដែល ឬក៏ប្រភេទសំណួរណាដែលច្បាប់ហាមឃាត់។ ទី២ អង្គជំនុំជម្រះក៏មានសិទ្ធិខ្លួនឯង នៅក្នុងការសម្រេចលើការហាមឃាត់មិនឲ្យសាក្សីឆ្លើយតបដែរ។

ដូច្នេះសំណួរនេះ គឺអង្គជំនុំជម្រះមិនបានហាមមិនឲ្យលោកឆ្លើយតបទេ ហើយភាគីដទៃទៀតក៏មិនមានការជំទាស់ដែរ។ មានន័យថា ជាការសំណួរបែបគេហៅថា "ដេញដោល"។ ដូច្នេះលោកសាក្សីព្យាយាមឆ្លើយតបរាល់សំណួរដែលភាគី ឬក៏ចៅក្រមនៃអង្គជំនុំជម្រះសួរចំពោះលោក។ បើលោកចាំលោកអាចឆ្លើយតប បើលោកមិនចាំទេ លោកអាចសុំឲ្យមេធាវីការពារក្ដីតាំងសំណួរចុងក្រោយនេះឡើងសាជាថ្មីម្ដងទៀត។

[១៥:៤២:៥៧]

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ខ្ញុំនឹងសួរសំណួរខ្ញុំឡើងវិញម្ដងទៀតលោកប្រធាន។ បាទជាការត្រឹមត្រូវដែរឬទេ គឺថាលោកជាកម្មាភិបាលស្មោះត្រង់រហូតដល់ឆ្នាំ១៩៧៩ ហើយលោកមិនដែលត្រូវបានយកទៅអប់រំកែប្រែ ឬក៏លត់ដំអ្វីនោះទេ?

**លោក កែវ លឿ៖**

**ឆ៖** ខ្ញុំបានសូមឆ្លើយជូនអង្គតុលាការ។ ថាតាំងពីឆ្នាំ៧០ មកទល់៧៥ ខ្ញុំបាទនៅជាទ័ព មិនដែលមានបញ្ហាអ្វី។ តែក្រោយ៧៥ នៅឆ្នាំ៧៧ ដែលខ្ញុំបានជម្រាបថា គេយកទៅលត់ដំ គឺនៅជាយុទ្ធជនលត់ដំគឺយុទ្ធជនទាំងអស់គ្នាបាទ។

**ស៖** សូមអរគុណ ខ្ញុំសូមបន្តទៀត។ តើលោកដឹងដែរឬទេ ថាហេតុអ្វីបានជាកងពល៣១០ -- ប្រធានកងពល ៣១០, អឿន នោះត្រូវបានគេចាប់ខ្លួន? តើលោកដឹងមូលហេតុនៃការចាប់ខ្លួនរបស់

អឿន នេះទេ?

**ឆ៖** ខ្ញុំបាទសូមជម្រាបជូនអង្គតុលាការ ខ្ញុំបាទពុំបានដឹងទេ ដឹងនៅពេលណាដែលហៅទៅឲ្យរៀន ហើយស្តាប់នូវខ្សែអាត់ ដូចដែលខ្ញុំបានជម្រាបខាងដើម។

[១៥:៤៤:៥៣]

**ស៖** បាទ ខ្ញុំយល់ហើយ។ ក៏ប៉ុន្តែប្រហែលជាមានការភ័ន្តច្រឡំមួយ ទាក់ទងនឹងកាលបរិច្ឆេទនៃការចាប់ខ្លួន គាត់ចាប់ ត្រូវបានគេចាប់ខ្លួននៅថ្ងៃទី០៤ ខែមីនា ឆ្នាំ១៩៧៨ ឬក៏គាត់ត្រូវបានគេចាប់ខ្លួនមុនហ្នឹង?

**ឆ៖** ខ្ញុំបាទពុំបានដឹងថ្ងៃខែទេបាទ។

**ស៖** តើខែកុម្ភៈ មីនា ឆ្នាំ១៩៧៧ ឬក៏ឆ្នាំ១៩៧៨?

**ឆ៖** សូមបញ្ជាក់ម្តងទៀត ខ្ញុំបាទស្តាប់អត់បាន។

**ស៖** អឿន ជាប្រធានកងពល៣១០ ដែលលោកនៅក្នុងចំណុះរយៈពេល៩ឆ្នាំនោះ តើគាត់ត្រូវបានគេចាប់ខ្លួននៅថ្ងៃទី -- នៅខែកុម្ភៈ មីនា ឆ្នាំ១៩៧៧ ឬក៏ឆ្នាំ១៩៧៨?

**ឆ៖** នៅពេលដែលគេចាប់ តាអឿន, តាគីម នេះគឺនៅឆ្នាំ១៩៧៧។

**ស៖** បាទ លោកប្រធានគឺឯកសារ E3/1993 និយាយថា អឿន ហ្នឹងត្រូវបានគេចាប់ខ្លួននៅថ្ងៃទី០៤ មីនា ឆ្នាំ១៩៧៨។ អ៊ីចឹងសូមឲ្យកត់ចូលប្រតិចារឹក ហើយ តាគីម ហើយនិងម្នាក់ទៀតដែលជាអនុប្រធានសេធិការហ្នឹងក៏អ៊ីចឹងដែរ ត្រូវចាប់ខ្លួននៅពេលនោះដែរ។

[១៥:៤៦:១៨]

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកចៅក្រម ឡាវ៉ែន!

**ចៅក្រម ហ្សង់ម៉ាក ឡាវ៉ែន៖**

លោកមេធាវី កូប៉េ ខ្ញុំមិនដឹងថាលោកកំពុងតែនិយាយអំពីឯកសារអ្វីនោះទេ ដើម្បីឲ្យកត់ចូលទៅក្នុងប្រតិចារឹកសវនាការនេះ ខ្ញុំសូមជម្រាបជូនថា នៅក្នុងបញ្ជីអ្នកទោសនៅមន្ទីរស-២១ គឺឯកសារ E3/342 ពីទំព័រ៣៩១។ ហើយនៅលេខ៩៦៧ ការចាប់ខ្លួននោះគឺនៅថ្ងៃទី១៧ កុម្ភៈ ឆ្នាំ១៩៧៧ ហើយមាននៅក្នុងសំណុំរឿងនូវចម្លើយសារភាពរបស់ ស្បូវ ហៅ អឿន គឺឯកសារ E3/1891។ ចម្លើយសារភាពចុះនៅថ្ងៃទី២០ កុម្ភៈ ទៅដល់១៤ ខែ៣ ឆ្នាំ១៩៧៨។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំដូចជាវង្វេង ព្រោះថាខ្ញុំមានឯកសារ E3/1993 គឺជាបញ្ជីអ្នកទោសធ្ងន់។ គឺជាឯកសារទាក់ទងនឹងសាលក្រមរបស់ ប៉ុល ពត, អៀង សារី នៅឆ្នាំ១៩៧៩ ហើយដែលនិយាយថា អឿន ហ្នឹង ត្រូវបានចាប់ខ្លួននៅឆ្នាំ១៩៧៨។ អ៊ីចឹងហើយបានខ្ញុំសូមការបំភ្លឺ។ បាទ អ៊ីចឹងខ្ញុំសូមអរគុណលោកចៅក្រម។

[១៥:៤៩:០៩]

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ខ្ញុំចោទសំណួរលោកទាក់ទងនឹង តាគីម។ តើ តាគីម នេះជាមនុស្សតែមួយហៅ សៅ គីម ហ្នឹងឬក៏យ៉ាងម៉េច? តែមួយទេ តាគីម ហើយ សៅ គីម នេះ?

**លោក កែវ លឿ៖**

**ឆ៖** តាគីម គឺឈ្មោះតែមួយបាទ។

**ស៖** អ៊ីចឹងឈ្មោះពេញរបស់គាត់ហ្នឹង សៅ ឃួន ឬក៏ សៅ គីម?

**ឆ៖** ខ្ញុំបាទសូមជម្រាបជូនអង្គតុលាការ។ នាមត្រកូលពុំបានស្គាល់ទេ ស្គាល់តែ តាគីមៗ គេហៅ តាគីម ក៏ តាគីម តាមគ្នាទៅ។

**ស៖** លោកសាក្សី តើលោកដឹងថា មានទំនាក់ទំនងរវាង អឿន, រឿង, គីម និង កុយ ធួន ទេ រវាងអ្នកប៉ុន្មាននាក់ដែលខ្ញុំរៀបរាប់ហ្នឹង កុយ ធួន មានទំនាក់ទំនងរវាងគាត់ទាំងអស់គ្នាហ្នឹងទេ?

**ឆ៖** ខ្ញុំបាទសុំឆ្លើយជូនអង្គតុលាការ ទំនាក់ទំនងរវាងមេៗទាំងអស់នេះ ខ្ញុំបាទពុំបានដឹងទេ។

[១៥:៥០:៤៤]

**ស៖** កុយ ធួន ត្រូវបានគេចាប់ខ្លួនដោយសារគាត់រៀបផែនការធ្វើរដ្ឋប្រហារនៅខែមករា ឆ្នាំ ១៩៧៧។ គេមិនបាននិយាយអំពីបញ្ហានេះនោះទេ តើលោកមានដឹងថាគេ -- មានដែលធ្លាប់ឮគេនិយាយពីរឿងការរៀបចំធ្វើរដ្ឋប្រហារនេះទេ?

**ឆ៖** ខ្ញុំបាទពុំបានដឹងទេ។

**ស៖** តើលោកធ្លាប់ឮគេនិយាយថា កុយ ធួន ហ្នឹងគាត់ទៅពឹងពាក់កងពល៣១០ ដើម្បីរៀបផែនការធ្វើរដ្ឋប្រហារហ្នឹងដែរឬទេ?

**ឆ៖** ខ្ញុំបាទពុំបានដឹងទេ។

**ស៖** កាលពីព្រឹកមិញ លោកបាននិយាយអំពីអាវុធដែលត្រូវបានដឹកយកមក។ ហើយដល់ពេលលោកឃើញគេដឹកអាវុធមកអ៊ីចឹង លោកសួរគេ ហើយលោកសួរគេ គេថាកុំចេះដឹងរឿងហ្នឹង។ ហើយគេអាវុធនោះហ្នឹងគឺនៅឆ្នាំ៧៧។ លោកមានចាំអ្វីលោកនិយាយព្រឹកមិញហ្នឹងទេ?

**ឆ៖** ខ្ញុំបាទនៅចាំបាន ព្រោះនៅពេលនោះ ខ្ញុំបាទសួរគេអ្នកដឹកកាំភ្លើង ខ្ញុំថា "គេដឹកកាំភ្លើងទៅណា ចប់សង្គ្រាមហើយ"។ គេថា "ឯងកុំចេះដឹងអី ឯងពិការដើរមិនរួច នៅឲ្យស្ងៀមទៅ"។

[១៥:៥២:៤៣]

**ស៖** មុនខែមករា ឆ្នាំ១៩៧៧ រដ្ឋប្រហារធម្មតាត្រូវរៀបចំនៅខែមករា ឆ្នាំ១៩៧៧។ អ៊ីចឹងបានន័យថា អាវុធហ្នឹងត្រូវបានគេបញ្ជូនមកមុនខែមករា ឆ្នាំ៧៧ ហ្នឹងបន្តិចបន្តួច ឬក៏យ៉ាងណា?

**លោក វីយ្លៀម ស្មីត៖**

បាទ ខ្ញុំមើលទៅឃើញថាជាសំណួរនាំមុខ។ តើលោកមេធាវី គាត់មានមូលដ្ឋានអីដើម្បីចោទសំណួរនេះទៅសាក្សី?

**លោក វ៉ិចទ័រ កូប៉េ៖**

បាទបញ្ជា លោកប្រធាន គឺថានៅត្រង់ថាជាព័ត៌មានរបស់ ប៉ែន យៀវនិន ដែលនិយាយអំពីរដ្ឋប្រហារនេះហ្នឹង គឺត្រូវបានរៀបចំឡើងនៅថ្ងៃទី១៧ ខែមករា ឆ្នាំ១៩៧៧ ប្រឆាំងនឹងរបប ប៉ុល ពតនេះ។ បាទ ប៉ុន្តែខ្ញុំសូមបន្តចោទសំណួរទៀតដោយសារពេលវេលាកាន់តែខើចទៅហើយ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សីខ្ញុំដឹងថា លោកស្គាល់ខេត្តមួយនៅខាងជើងប្រទេសកម្ពុជា គឺខេត្តសៀមរាប។ តើលោកធ្លាប់មានកាន់មុខតំណែងអីនៅខេត្តសៀមរាបដែរឬទេ?

**លោក កែវ លឿ៖**

**ឆ៖** ខ្ញុំបាទមិនដែលមានតំណែងអ្វីនៅខេត្តសៀមរាបទេ សូមអង្គតុលាការមេត្តាជ្រាប។

[១៥:៥៤:១៩]

**ស៖** ប៉ុន្តែកិច្ចសម្ភាសន៍របស់លោកជាមួយនឹងមជ្ឈមណ្ឌលឯកសារកម្ពុជា លោកនិយាយថាលោកធ្លាប់ទៅសៀមរាបក្នុងឋានៈជាយោធា នៅចន្លោះឆ្នាំ១៩៧០ និង៧៥។ តើជាការត្រឹមត្រូវដែរឬទេថាលោកធ្លាប់បានទៅសៀមរាបនៅចន្លោះឆ្នាំ៧០ និង៧៥?

**ឆ៖** ខ្ញុំបាទសូមឆ្លើយបំភ្លឺអង្គតុលាការ ដែលខ្ញុំបាទបានទៅសៀមរាបគឺបានទៅពិតមែន តែនៅ

ដើមឆ្នាំ១៩៧៣ មិនបាន៧៥ ដូចលោកមេធាវីលោកបានចោទសួរទេ។ សូមអង្គតុលាការមេត្តាជ្រាប។

**ស៖** បាទសូមអរគុណ។ តើលោកដឹងអំពីអ្វីដែលកើតមានឡើងនៅថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ១៩៧៦ ដែរឬទេ?

**ឆ៖** ខ្ញុំបាទពុំបានដឹងអ្វីទេ។

**ស៖** តើលោកធ្លាប់ឮគេនិយាយអំពីរបាយការណ៍ទាក់ទងនឹងការបះបោររបស់យោធា ហើយ និងការទម្លាក់គ្រាប់បែកនៃយន្តហោះចម្បាំងនៅខេត្តសៀមរាបដែរឬទេ? តើលោកធ្លាប់ឮគេនិយាយអំពីអ្វីដែលកើតឡើងនៅសៀមរាបដែរឬទេ នៅខែមករា -- កុម្ភៈ ឆ្នាំ១៩៧៦?

**ឆ៖** នៅឆ្នាំ១៩៧៦ ខ្ញុំបាទពុំបានដឹងទេ នៅខេត្តសៀមរាប។

**ស៖** តើលោកធ្លាប់ឮគេនិយាយអំពីចម្បាំងដ៏ក្ដៅគគុកនៅក្នុងឆ្នាំ១៩៧៦ ប្រហែលជានៅម្ដុំសៀមរាប នៃកងទ័ពបដិវត្តន៍ដែរឬទេ មានការប្រយុទ្ធគ្នានៅសៀមរាប?

**ឆ៖** ខ្ញុំបាទពុំដែលដឹងទេ។

**ស៖** បាទ ឥឡូវខ្ញុំសូមត្រឡប់មកនិយាយទាក់ទងនឹងអ្វីដែលលោកបានលើកឡើង ទាក់ទងនឹងអាវុធដែលគេបានដឹក។ បាទជាថ្មីម្ដងទៀត សូមលោកព្យាយាមចងចាំអំពីអ្វីដែលគេបាននិយាយទៅកាន់លោក នៅពេលដែលគេនិយាយប្រាប់លោកថា កុំគិតរឿងគេ គិតតែរឿងខ្លួនឯងបានទៅហើយ។ តើលោកអាចរៀបរាប់ជូនតុលាការបានដែរឬទេ ថាលោកចងចាំអ្វីខ្លះ? ពេលណាដែរ?

**ឆ៖** ខ្ញុំបាទសូមឆ្លើយជូនអង្គតុលាការ នៅថ្ងៃខែឆ្នាំ ខ្ញុំបាទពុំបានចាំទេ តែនៅពេលនោះ ខ្ញុំបាទឃើញគេដឹកកាំភ្លើងទៅហើយ ឈប់មុខកន្លែងខ្ញុំបាទនៅ។ រួចហើយខ្ញុំបាទ សួរគេថា "កាំភ្លើងនេះគេដឹកទៅណា?" គេថា "កុំចេះ ឯងអ្នកពិការ បន្តិចទៀតគេដឹកទៅក្រោយអស់ហើយអស់ឯង"។ នេះជាពាក្យព្រមានរបស់អ្នកដឹក។

[១៥:៥៨:២៤]

**ស៖** តើលោកដឹងដែរឬទេ ថាបន្ទាប់ពីហ្នឹងមកហ្នឹងប៉ុន្មានខែនៅពេលដែលគេតែងតាំងលោកឲ្យក្លាយជាប្រធាន ក-៤ នេះ? ពេលដែលលោកឃើញគេដឹកអាវុធដឹកអីហ្នឹង ខ្ញុំសួរថា រយៈគម្លាតគ្នាប៉ុន្មានបានគេតែងតាំងលោកធ្វើជាប្រធាន ក-៤?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ!

**លោក វីណ្ឌៀម ស្មីត៖**

អស់លោក លោកស្រីចៅក្រមជាទីគោរព ខ្ញុំគិតថា គួរតែសួរថា តើមុនពេលដែលគាត់ត្រូវបានគេតែងតាំងជាប្រធាន ក-៤ ហ្នឹងរយៈពេលប៉ុន្មានខែ ឬក៏ក្រោយពេលហ្នឹងប៉ុន្មានខែ ដើម្បីឲ្យច្បាស់។

**លោក វ៉ិចទ័រ កូប៉េ៖**

បាទ ឥឡូវខ្ញុំអាចរៀបសំណួរឡើងវិញបាន។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** តើលោកក្លាយជាប្រធាន ក-៤ នុំងប៉ុន្មានខែហើយ បានលោកឃើញគេដឹកអាវុធមកហ្នឹង ហើយពេលដែលលោកនិយាយទៅគេថា គិតតែរឿងខ្លួនឯងទៅបានហើយ?

**លោក កែវ លឿ៖**

**ឆ៖** ខ្ញុំបាទសូមជម្រាបជូនអង្គតុលាការ។ ពុំបានចាំខែថ្ងៃទេ ព្រោះយូរហើយ។

[១៦:០០:០៥]

**ស៖** ប្រហែលជាខ្ញុំច្រឡំទេមើលទៅ។ ក៏ប៉ុន្តែតួនាទីរបស់លោកជាមេក-៤នោះ ប្រហែលជាទាក់ទងទៅនឹងការចាប់ខ្លួននឹងមេចាស់ផង អតីតមេក-៤នេះ។ នៅពេលដែលលោកក្លាយជាប្រធានក-៤នោះ តើវាអាចមានទំនាក់ទំនងអ្វីមួយនឹងការដឹកអាវុធចូលមកដែរឬទេ? តើលោកអាចព្យាយាមរំឭកឡើងវិញអំពីអ្វីដែលកើតឡើងនៅថ្ងៃដែលគេប្រាប់ឲ្យលោក -- គេប្រាប់លោកថា កុំចេះដឹងរឿងគេនេះ?

**ឆ៖** ខ្ញុំបាទសូមឆ្លើយជូនអង្គតុលាការ នៅពេលដែលគេនិយាយថា "ឯងកុំចេះ" គេប្រើរយៈពេលវែង បានខ្ញុំបាទបានទទួលឋានៈជាប្រធានគ្រប់គ្រងអង្គភាពក-៤ គឺយូរបាទ វាខុសពេលវេលាគ្នាបាទ។

**ស៖** ឥឡូវខ្ញុំសូមជួយរំឭកលោក។ មានភស្តុតាងដែលធ្វើឲ្យយើងយល់ថា អតីតមេ ក-៤ – ប្រធាន ក-៤ នេះមានវត្តមាននៅក្នុងកិច្ចប្រជុំទូទៅមួយនៅខែតុលា ឆ្នាំ១៩៧៦ ហើយគាត់បាត់ខ្លួន ត្រូវបានគេចាប់នៅឆ្នាំ១៩៧៧។ គេប្រាប់លោកថា កុំឲ្យចេះដឹងនៅក្នុងឆ្នាំ១៩៧៧ តើអ៊ីចឹងមែនទេ?

**ឆ៖** ខ្ញុំបាទពុំបានចាំទេ។

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន ខ្ញុំមើលទៅឃើញថាម៉ោងបួនហើយ តើៗសមល្មមនឹងសម្រាកឥឡូវ ឬក៏យ៉ាងណា?

[១៦:០២:២០]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយសវនាការនៅថ្ងៃនេះ ដល់ពេលឈប់សម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ សវនាការលើកទៅបន្តធ្វើនៅថ្ងៃស្អែក ថ្ងៃអង្គារ ទី១៦ ខែមិថុនា ឆ្នាំ២០១៥ ដោយចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹកទៅ។ សវនាការនៅថ្ងៃស្អែកនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការបន្តស្តាប់សក្ខីកម្មសាក្សី កែវ លឿ បញ្ចប់។ ហើយអង្គជំនុំជម្រះក៏សូមជម្រាបជូនដំណឹងដល់ភាគី និងសាធារណជនឲ្យបានជ្រាបផងដែរថា សាក្សីដែលត្រូវមកផ្តល់សក្ខីកម្មបន្ទាប់ គឺសាក្សីដែលមានរហស្សនាម 2-TCW-901។ ប៉ុន្តែដោយសារតែមានបញ្ហាទាក់ទងនឹងការរៀបចំ អង្គជំនុំជម្រះអាចនឹងស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-830 សម្រាប់អង្គហេតុទំនប់១មករា មុនការស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-901។ ហេតុដូច្នេះ សូមភាគីជ្រាប និងរៀបចំខ្លួនសម្រាប់ធ្វើសវនាការស្តាប់សក្ខីកម្មសាក្សីឲ្យបានទាន់ពេលវេលា។

អង្គជំនុំជម្រះសូមអរគុណ លោក កែវ លឿ ដំណើរការសវនាការស្តាប់សក្ខីកម្មរបស់លោកក្នុងឋានៈជាសាក្សី នៅមិនទាន់ចប់នៅឡើយទេ។ អង្គជំនុំជម្រះកោះអញ្ជើញលោក ឲ្យមកបន្តផ្តល់សក្ខីកម្មនៅព្រឹកថ្ងៃស្អែកទៀត ដែលនឹងចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹកទៅ ហើយសវនាការស្តាប់សក្ខីកម្មរបស់លោកនៅថ្ងៃស្អែកនេះទំនងមិនដល់មួយព្រឹកទេ។ ឥឡូវនេះលោកអាចសម្រាកបានហើយ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយបុគ្គលិកនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនសាក្សី កែវ លឿ វិលត្រឡប់ទៅកាន់កន្លែងដែលគាត់ស្នាក់នៅវិញចុះ និងឲ្យអញ្ជើញគាត់ត្រឡប់មកចូលរួមសវនាការនៅក្នុងបន្ទប់សវនាការនេះវិញ នៅព្រឹកថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួន។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ នួន ជា និង ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ និងបង្គាប់ឲ្យនាំខ្លួនពួកគាត់ទាំងពីររូបត្រឡប់ចូលរួមសវនាការ នៅថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួនព្រឹក។

សម្រាកចុះ៕

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ១៦:០៤ នាទី)*